# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំ ទី ២៩ លេខ១១ ខែវិច្ឆិកា ព.ស. ២៥០០ គ.ស. ១៩៥៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* បញ្ជីរឿង ទំព័រ

–ពុទ្ធបិតុបរិនិព្វាន ព្រះមហា ធូ–សុទ្ធ រៀបរៀង . . . . . . . . . . . ៩៦៣

–ពុទ្ធគុណ លោក ប៊ូ–ប៉ូ រៀបរៀង . . . . . . . . . . . . . . ៩៧៥

–សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់ . . . លោក រ៉ាយ–ប៊ុក រៀបរៀង . . . ៩៨០

*ផ្នែកអក្សរសាស្ត្រ*

–សុភាសិតឈាវ លោក រ៉ាយ–ប៊ុក ដកស្រង់រៀបរៀង . . . . . . . . . . ៩៧៣

–រឿងទេវន្ទះបស់អម្រិតក្សត្រី ម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ . . . . . ៩៨៧

–រឿងសាមពុក (តមក) ឧកញ៉ា នូ-កន ប្រែ រៀបរៀង . . . . . . . ១០០៧

–រឿងហង្សឱត (តមក) លោក រ៉ាយ-ប៊ុក ប្រែ រៀបរៀង . . . . . . . . ១០១៨

*ផ្នែកកំណត់នៃប្រវត្តិការណ៍*

–ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះតេជព្រះគុណព្រះពោធិវង្ស (តមក)
លោក ង៉ា-ទន់ រៀបរៀង . . . . . . ១០២៣

–ព្រះរាជដំណើរសម្ដេចព្រះឧបយុវរាជ.ទៅកាន់កោះ សិរីលង្កា ក្នុងពិធីបុណ្យ
ពុទ្ធជយន្តិ (តមក) លោក រ៉ាយ-ប៊ុក រៀបរៀង. . ១០២៩

–សន្និសីទនៃ បណ្ឌិត-វិស្វាទ (អេភ្លិត) ធ្វើនៅ-ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត (តមក)
លោក រ៉ាយ-ប៊ុករៀបរៀង . . . . . . . . . ១០៣៦

–វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាងខាត់ រៀបរៀង . . . . . ១០៤៤

–សេចក្ដីផ្ដួចផ្ដើមអំពីទស្សនាវដ្ដី កម្ពុជសុរិយាឆ្នាំ ១៩៥៨

មួយឆ្នាំមាន ១២ សៀវភៅ ជាថ្លៃ ២៣០៛០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

## *TABLE DES MATIÈRES*

### *PARTIE RELIGIEUSE:*

-Bouddhaparinibbana par Vén. *THOU-SOTH* . . . . . . . . . . . .963
-Bouddhaguna par *M. BOU-PO* . . . . . . . . . . . . . . . . . . . .975
-Réflexion d'un bouddhiste par *M. RAY-BUC* . . . . . . . . . . . .980

### *PARTIE LITTÉRAIRE:*

-Recueil de proverbes laotiens par *M. RAY-BUC* . . . . . . . . . .983
-Histoire de Devanda de *M. MOK* (suite)
revue et corrigée par *M. NHOK-THEM* . . . . . . . .987
-Histoire de Samkok (suite) traduit par *M. NOU-KAN* . . . . . . . . 1007
-Histoire de Zadig (suite et fin) traduit par *M. RAY-BUC* . . . 1018

### *NOTES ET CHRONIQUES :*

-Voyage du Vénérable HUOT-TAT aux
U. S. A. (suite) par *M. CHEA-TON* . . . . . . . 1023
-Voyage de Samdach Préah Upayuvareach à Ceylan lors de la fête du
Buddha Jayanti (suite et fin) par *M. RAY-BUC* . . 1029
-Conférence du Dr. RICHARD A. GARD au Lycée Buddhique
Preah Suramarit (suite et fin) par *M. RAY-BUC* . . 1036
-Dictionnaire khmèr-Sanskrit- (suite) par Vén. *PANG-KHAT* . . . 1041
-Avis de la Revue Kambujasuriya 1958.

---

Prix d'abonnement annuel (comprenant 12 numéros): 230$00

# ផ្នែកសាសនា

## ពុទ្ធបិតុបរិនិព្វាន

បរិច្ឆេទទី ២២ នៃពុទ្ធប្រវត្តិ

ព្រះមហា ឃួរ-សុទ្ធ សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ទេសនា

នៅថ្ងៃសុក្រ ១៧ ខែឧសភា ២៥០០/១៩៥៧

ក្នុងឱកាសបុណ្យ ព.ស. ២៥០០

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ បំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ។

ពេលនេះ ជារាត្រីថ្ងៃទី ៦ នៃពិធីបុណ្យ ព.ស.២៥០០, ដែលកើតឡើងយ៉ាងមហោឡារិកអស្ចារ្យ ដោយកម្លាំងសទ្ធា នឹងសេចក្ដីជ្រះថ្លាយ៉ាងមោះមុត នៃពុទ្ធបរិស័ទគ្រប់ភាគៈ ។

ខ្ញុំព្រះករុណា អាត្មាភាពសំដែង " អតីតដំណើរបរិច្ឆេទនៃពុទ្ធបិតា" ត្រង់បរិច្ឆេទទី ២២ នៃពុទ្ធប្រវត្តិ ដូចតទៅនេះ ៖

### ជីវប្រវត្តិនៃពុទ្ធបិតា

ព្រះពុទ្ធបិតា គឺព្រះបាទសិរីសុទ្ធោទនសក្យរាជ ព្រះចៅក្រុងកបិល-ពស្តុ ក្នុងប្រទេសឥណ្ឌា ដែលសព្វថ្ងៃមានឈ្មោះថា "នេបាលរដ្ឋ" មានព្រះនាងមហាមាយាទេវី ជាព្រះរាជអគ្គមហេសី ។ ព្រះអង្គជាធម្មិក.

មហារាជ ទ្រង់គ្រប់គ្រងប្រជាពលរដ្ឋប្រកបដោយទសពិធធម៌ទាំង ១០ ប្រការឥតឃ្លៀងឃ្លាត ។ ទាំងក្រោយមក, ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាមថា "សិទ្ធត្ថ" ។ កាលព្រះរាជកុមារបានព្រះជន្មាយុ ១៦ ព្រះវស្សាហើយ ទ្រង់អភិសេកឲ្យគ្រងរាជសម្បត្តិជំនួសព្រះអង្គ ។

លុះកន្លងមក ១៣ ឆ្នាំ, ក្រោយពេលដែលព្រះរាជបុត្រលះបង់រាជសម្បត្តិ ចេញទ្រង់ព្រះផ្នួសហើយ; ការគ្រប់គ្រងក្រុងកបិលពស្តុ ក៏បានធ្លាក់មកលើព្រះអង្គម្តងទៀត ។

តាំងពីព្រះរាជបុត្រទ្រង់ចេញព្រះផ្នួសមក ទ្រង់ពុំដែលបានដំណឹងអ្វីពិតប្រាកដពីព្រះអង្គសោះ, លុះកន្លងមក ៧ ឆ្នាំ ទើបបានជ្រាបដំណឹងពិតថា "ព្រះរាជបុត្របានត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងលោកហើយ, ឥឡូវ ទ្រង់ប្រថាប់នៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ" ។ ដំណឹងនេះធ្វើឲ្យទ្រង់ត្រេកអរជាអនេក បានចាត់ព្រះរាជបំរើ ឲ្យទៅនិមន្តព្រះសាស្តាជាច្រើនលើក ទើបបានសម្រេចដូចព្រះបំណង ។ ក្នុងឱកាសដែលព្រះសាស្តាស្តេចយាងទៅសំដែងធម៌ប្រោសព្រះពុទ្ធបិតា ព្រមទាំងព្រះញាតិទាំងឡាយក្នុងព្រះរាជធានីកបិលពស្តុ, ថ្ងៃទី១ ព្រះពុទ្ធបិតាបានសម្រេចលោកុត្តរភិ-សម័យ ថ្នាក់សោតាបត្តិផល ដោយព្រះពុទ្ធភាសិតថា "ឧត្តិដ្ឋេ នប្បមជ្ជេយ្យ" ដូច្នេះជាដើម; តមក បានសម្រេចសកទាគាមិផល ដោយព្រះពុទ្ធភាសិតថា "ធម្មញ្ចរេ សុចរិតំ" ដូច្នេះជាដើម ។

ថ្ងៃក្រោយមកទៀត ទ្រង់បានសម្រេចដល់ថ្នាក់អនាគាមិផល ដោយទ្រង់ព្រះសណ្តាប់នូវធម្មបាលជាតក ។ តពីនេះទៅ ទ្រង់ពុំទាន់បានសម្រេច

នូវគុណធម៌អ្វីដទៃទៀតនៅឡើយ ហេតុដល់ជរាភាពចូលមកដល់ ធ្វើព្រះសព្វាង្គកាយរបស់ទ្រង់ ឲ្យដល់នូវការទ្រុឌទ្រោមទុព្វលភាពថមថយចុះទៅជាលំដាប់ ។

កាលនោះ ព្រះសម្ពុទ្ធជាម្ចាស់ បានត្រាស់ដឹងឡើងក្នុងលោកអស់រយៈកាល ៥ ព្រះវស្សាហើយ, ក្រោយដែលព្រះអង្គស្តេចយាងទៅកាន់ញាតិសមាគម ក្រុងកបិលពស្តុជាលើកដំបូង; ដើម្បីសំដែងធម៌ប្រោសញាតិទាំងឡាយ មានព្រះពុទ្ធបិតាជាដើម, ព្រះអង្គព្រមទាំងភិក្ខុសង្ឃជាបរិវារ ស្តេចយាងនិមន្តទៅកាន់វេឡុវនារាម ក្រុងរាជគ្រឹះវិញ ។ លុះដល់វស្សាទី ៥ ទើបទ្រង់យាងចេញពីក្រុងរាជគ្រឹះ ទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ដើម្បីអនុគ្រោះដល់វេនេយ្យសត្វ ក្នុងទីនោះ ។

គ្រានោះ ព្រះបាទសុទ្ធោទនមហារាជ ជាពុទ្ធបិតា ស្តេចទ្រង់ប្រឈួនជាទម្ងន់ ដោយព្រះរោគជរា ។ ព្រះរោគនេះ បានចាក់ដោតចុកសៀតក្នុងព្រះអង្គ ធ្វើឲ្យទ្រង់ទទួលទុក្ខវេទនា ដល់នូវការឈឺចាប់យ៉ាងខ្លាំង ។ សក្យរាជទាំងឡាយ បានខ្នះខ្នែងស្វែងរកពេទ្យនិងឱសថ មកព្យាបាលរម្ងាប់ព្រះរោគនោះណាស់ដែរ ប៉ុន្តែ ពុំបានលទ្ធផលសោះ ។ ព្រះរោគាពាធ នៅតែបន្តសកម្មភាព ឈឺចាប់ចាក់ដោត ក្នុងព្រះអង្គចំរើនទ្វេឡើងជាលំដាប់ ។ ពេលនោះ ដោយកម្លាំងទុក្ខវេទនាគ្របសង្កត់ខ្លាំងពេក បណ្តាលឲ្យទ្រង់ផ្ទំបរះនទៀលប្រែចុះប្រែឡើង លើសិរិសយនា ទ្រង់នឹករលឹកដល់ព្រះសាស្តាដោយព្រះតម្រិះថា " រោគាពាធដែលចាក់

ដោត ក្នុងសពាង្គកាយអាត្មាអញក្នុងគ្រានេះ មានឥទ្ធិពលខ្លាំងក្លាណាស់ ពុំអាចស្វែងរកឱសថពិសេសណាមួយ មកជួយបន្ទាបឲ្យស្ងប់ស្ងាប់បានទេ, បើប្រសិនជាបានព្រះសាស្តា មកស្ទាបព្រះសិរសា, ព្រះអានន្ទត្ថេរ នឹងព្រះខន្ធដ៏មានអាយុ មកស្ទាបអង្អែលព្រះផាសុកា គឺឆ្អឹងជំនីរទាំងសងខាង ព្រះរាហុលជាព្រះរាជនត្តា មកស្ទាបអង្អែលព្រះបាទ នៃអាត្មាអញឥឡូវនេះ សង្ឃឹមថា ទុក្ខវេទនា ទាំងពោះពោងទាំងអស់នេះ នឹងបានជាសះស្បើយពុំខាន ។

ពេលនោះ, ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់គង់នៅឆ្ងាយដាច់ស្រយាលពីព្រះរាជបិតា របស់ព្រះអង្គក៏ពិតមែន, ប៉ុន្តែ ហាក់ដូចជាទ្រង់ប្រថាប់នៅកៀកកើយជិតទ្រង់ដែរ, ព្រោះព្រះអង្គមានព្រះញាណពិសេសជាសព្វ-វិទូបុគ្គល ទ្រង់ជ្រាបច្បាស់ឥតរើសទាក់ នូវព្រឹត្តិការណ៍គ្រប់យ៉ាងដែលកើតមានឡើងក្នុងលោក ។ តស្មឹ ខណេ បច្ចូស សមយេ ដូចជាក្នុងបច្ចូសសម័យថ្ងៃនោះ, ព្រះអង្គទ្រង់ប្រមើលមើលនូវឧបនិស្ស័យនៃសត្វ-លោក ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង គឺទ្រង់ផ្សាយនូវសេចក្តីដឹងសព្វរបស់ព្រះអង្គ ដើម្បីពិនិត្យមើលនូវគតាគម្មរបស់វេនេយ្យសត្វក្នុងសាកលលោកទាំងមូល ឲ្យដឹងថា តើសត្វពពួកណាខ្លះ ដែលមានបុព្វូប-និស្ស័យវាសនា គួរឲ្យព្រះអង្គយាងទៅទាក់ទង ប្រោសយកក្នុងវេលាព្រឹកនេះ ។ ខណៈនោះ ព្រះអង្គទ្រង់ជ្រាបច្បាស់ដោយព្រះបរោបរិយ-ញ្ញាណថា " ព្រះពុទ្ធបិតាទ្រង់ប្រឈួនជាទម្ងន់ ហើយទ្រង់នឹកជាខ្លាំងដល់ព្រះអង្គ ព្រមទាំងព្រះសង្ឃជាសាវក" ទើបទ្រង់ព្រះតម្រិះថា "ព្រះ

ពុទ្ធបិតាទ្រង់ប្រឈួនក្នុងគ្រានេះ មានទម្ងន់ខ្លាំងណាស់ គួរតែជាគតទៅ
កាន់សំណាក់ព្រះអង្គ ក្នុងកាលឥឡូវនេះ ដោយពិត" ។ លុះទ្រង់ព្រះ
តម្រិះដូច្នេះហើយ ទើបត្រាស់ហៅព្រះអានន្ទត្ថេរមកហើយ ទ្រង់ត្រាស់
ថា "អានន្ទ! ឥឡូវនេះ ព្រះពុទ្ធបិតាស្តេចទ្រង់ប្រឈួនជាទម្ងន់ណាស់,
ចូរអ្នកចេញទៅឲ្យដំណឹងដល់ព្រះសង្ឃ ឲ្យបានដឹងគ្រប់គ្នា ហើយប្រាប់
ទៀតថា "យើងនឹងទៅកាន់សំណាក់ព្រះអង្គក្នុងកាលឥឡូវនេះ" ។
ព្រះអានន្ទ, ក្រោយដែលបានទទួលព្រះពុទ្ធដីកាហើយ, ក៏បានផ្សាយ
ដំណឹងនោះដល់ភិក្ខុសង្ឃទាំងពួង តាមព្រះពុទ្ធតម្រាស់ ។

នៅពេលដែលព្រះសង្ឃទាំង ៥០០ អង្គ មកជួបអស់ហើយ ទើប
ព្រះសាស្តាទ្រង់នាំព្រះសង្ឃទាំងនោះហោះឆ្ពោះទៅតាមអាកាសវេហាស៍
ដែលមានល្បឿនដូចផ្លេកបន្ទោរ ឆ្ពោះទៅកាន់ក្រុងកបិលពស្តុបុរី ចុះ
នៅនាព្រះលាននៃព្រះរាជនិវេសន៍ ។ ដល់ហើយទ្រង់នាំព្រះសង្ឃចូល
ទៅកាន់ព្រះរាជមន្ទីរ ទតឃើញព្រះរាជា ទ្រង់ប្រឈួនមានព្រះកាយ
ទុព្វលភាព ដួសកស្តើងលើព្រះសេយ្យា ក្នុងកណ្តាលចំណោមព្រះញាតិ
ទាំងឡាយ ដែលកំពុងខ្វល់ខ្វាយបំរើ នឹងព្យាបាលព្រះរោគនេះ
ដោយសេចក្តីក្រៀមក្រំ; ទើបព្រះសាស្តាទ្រង់ប្រថាប់ ជិតព្រះពុទ្ធបិតា
ហើយពិនិត្យមើលអាការរោគនោះ ក៏បានជ្រាបដោយសព្វគ្រប់ ប៉ុន្តែ
ទ្រង់សាកសួរព្រះអង្គថែមទៀត ដើម្បីបន្ធូរសេចក្តីតានតឹងព្រះហឫទ័យអំពី
ទុក្ខវេទនាថា "បពិត្រមហារាជ! ព្រះរោគាពាធក្នុងព្រះអង្គល្មមអត់ធន់
បានដែរឬទេ? ព្រះពុទ្ធបិតាទ្រង់តបថា "ព្រះរោគាពាធក្នុងសព្វាង្គកាយ

របស់ខ្ញុំព្រះអង្គ ក្នុងពេលនេះធ្ងន់ណាស់ ពុំអាចនឹងអត់ធន់បានទេ" ។ ក្នុងខណៈនោះ ព្រះសាស្តាទ្រង់សណ្តូកព្រះហស្តាធ្វើសច្ចាធិដ្ឋានថា "តថាគតតាំងពីបានទទួលនូវពុទ្ធព្យាករណ៍ក្នុងសំណាក់ព្រះពុទ្ធទីបង្ករមក បានកសាងអភិនីហារបំពេញសមត្តិសបារមី អស់បួនអសង្ខេយ្យ នឹងមួយសែនកប្ប ដើម្បីប្រយោជន៍ពីរយ៉ាង :

មួយគឺ ប្រយោជន៍នៃការត្រាស់ដឹងរបស់តថាគត ។

មួយទៀត ប្រយោជន៍គឺការពង្រីក ផ្សព្វផ្សាយសេចក្តីសុខស្ងប់ដល់សត្វលោកទូទៅ ដោយធម្មទេសនា, ឥឡូវនេះ តថាគតនៅមានកិច្ចត្រូវបំពេញតែប្រយោជន៍ ទីពីរនេះទៀតទេ ហើយយកព្រះហស្តស្តាំស្ទាបអង្អែលយ៉ាងថ្នមៗ លើព្រះសិរសានៃព្រះភិក្ខុ ដោយព្រះហឫទ័យប្រកបដោយសេចក្តីករុណាយ៉ាងធំទូលាយ ។ ខណៈនោះ ព្រះរោគាពាធ ក្នុងព្រះសិរកើតអន្តរធានបាត់អស់ទៅ ។ តមក ព្រះអានន្ទត្ថេរ ក្រោយដែលបានខមស្ការព្រះសាស្តា ក៏ធ្វើសច្ចាធិដ្ឋានទាក់ទងដល់គុណធម៌ ដែលខ្លួនបានបំពេញមក អស់កាលដ៏យូរហើយ, ក៏យកព្រះហស្តស្ទាបព្រះផាសុកខាងស្តាំ ។ ការឈឺចាប់ត្រង់កន្លែងនោះ ក៏វិនាសបាត់អស់ទៅមួយរំពេច ។ បន្ទាប់មក ព្រះអានន្ទដ៏មានអាយុ ថ្វាយបង្គំព្រះសាស្តា ហើយធ្វើសច្ចាធិដ្ឋានថា " ខ្ញុំព្រះអង្គតាំងពីបានឧបសម្បទមក បានទទួលប្រតិបត្តិគ្រប់ប្រការ របស់ព្រះសាស្តា ដោយឥតខ្ចោះប្រហែសឡើយ, នេះជាសេចក្តីពិតរបស់ខ្ញុំព្រះអង្គ" ហើយលើកព្រះហស្តស្តាំស្ទាបអង្អែលព្រះផាសុកខាងឆ្វេង ។ ព្រះរោគាពាធត្រង់កន្លែងនោះ ក៏វិនាស

បាត់អស់ទៅ ៗ តពីនោះមក ព្រះរាហុលបានថ្វាយបង្គំព្រះសាស្តារួច ហើយធ្វើសច្ចាធិដ្ឋានថា "កាលពីអតីតជាតិ ខ្ញុំព្រះអង្គបានកើតជាកុមារ ឈ្មោះជាលី ព្រះមហាមុនីទ្រង់ពេញព្រះទ័យ ទឹងព្រះរាជទានខ្ញុំព្រះអង្គ ឲ្យទៅសម្រាប់យាចករូបអាក្រក់ម្នាក់ឈ្មោះ ជូជកព្រាហ្មណ៍ កាលនោះ ខ្ញុំព្រះអង្គក៏ពុំបានអាក់អន់តូចចិត្តអ្វីនឹងព្រះអង្គទេ, បេះតែខំស៊ូអត់សង្កត់ចិត្ត ក្នុងការទទួលរងទុក្ខ ទឹងទណ្ឌកម្មគ្រប់យ៉ាង នៅពេលដែលព្រាហ្មណ៍បណ្តើរចេញទៅ ដើម្បីជាកម្លាំងក្នុងការជួយបំពេញបារមីរបស់ព្រះអង្គ ឲ្យបានពេញលេញ នេះជាសេចក្តីពិត ក្នុងអតីតកាលរបស់ខ្ញុំព្រះអង្គ" ហើយស្ទាបអង្អែលព្រះបិដ្ឋព្រះអយ្យកោ ដោយព្រះហស្តខាងស្តាំ ៗ ការបាក់ដោតបុកសៀត ត្រង់កន្ទ្រង់នោះ ក៏សាបសូន្យអស់ទៅ ៗ

គ្រានោះ ព្រះសិរីសុទ្ធោទនមហារាជ បានជាសះស្បើយពីព្រះរោគាពាធ ទ្រង់មានបីតិសោមនស្សរីករាយ ទឹងសុខភាពជាអនេកប្រការ ទ្រង់ក្រោកពាក់សិរីសយនា ធ្វើអញ្ជលីកម្មថ្វាយបង្គំព្រះសាស្តា ព្រមទាំងព្រះសង្ឃជាសាវ័ក ៗ ប៉ុន្តែ ព្រះពុទ្ធទ្រង់ជ្រាបថា "សុខភាពរបស់ព្រះពុទ្ធបិតា បិតនៅក្នុងអនិច្ចតាធម៌ មិនបានតាំងនៅបិតថេរចិរកាលប៉ុន្មានឡើយ គឺទ្រង់គង់នៅតែ ៧ ថ្ងៃទៀតទេ ទឹងបរិនិព្វានហើយ ឥឡូវនេះ ទ្រង់ពុំទាន់បានសម្រេចលោកុត្តរធម៌ជាន់ខ្ពស់ គឺព្រះអរហត្តផលនៅឡើយ" ទើបព្រះអង្គទ្រង់សំដែងធម៌ ដែលទាក់ទងដោយព្រះត្រៃលក្ខណ៍ តម្រូវតាមបុព្វនិស្ស័យរបស់សន្តាននៃព្រះរាជា ដោយព្រះពុទ្ធដីកាជាដើមថា "បពិត្រព្រះមហារាជ! នាមរូប អនិច្ចំ នាមរូបមិនទៀងទេ

តែងប្រែប្រួលឬបែកជាធម្មតា នាមរូបំ ទុក្ខំ នាមរូបជាទុក្ខ" គឺតែងជួបប្រទះនឹងសេចក្ដីលំបាកវេទនា ដែលកើតពីការប្រែប្រួលនៃសង្ខារជាធម្មតា នាមរូបំ អនត្តា "នាមរូបនេះសោះសូន្យ គ្មានខ្លឹមសារ គ្មានឥស្សរភាព គ្មានអំណាចអាចឃាត់ ក៏ឲ្យប្រែប្រួលដូច្នោះបាន" ។ បន្ទាប់មកទ្រង់សំដែង សាមុក្កំសិកធម្មទេសនា គឺអរិយសច្ច ៤ មានទុក្ខសច្ចជាដើម ដែលអាចទាញមនោសញ្ចេតនា នៃព្រះពុទ្ធបិតាឲ្យយល់ច្បាស់ថា "លោកទាំងមូលជាទុក្ខ, ការកកើតឡើងនៃលោក ការប្រែប្រួលនៃលោក, ការប្រេះឆាបែកធ្លាយទៅនៃលោក ក៏ជាទុក្ខ , មូលហេតុនៃគំនរទុក្ខទាំងនោះ គឺតណ្ហា, កាលបើលះចោលនូវតណ្ហាចេញបាន សេចក្ដីទុក្ខគ្រប់យ៉ាង នឹងរលាយបាត់ទៅដែរ; ឧបាយ ឬ មាគ៌ាសម្រាប់បញ្ជូនចិត្តទៅរកទីរលត់ទុក្ខ គឺមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម" ។ ទីបំផុតនៃធម្មទេសនា ព្រះរាជាបានសម្រេចលោកុត្តរធម៌ជាន់លើ គឺព្រះអរហត្តផលជាតួសេចក្ដីបរិសុទ្ធ នឹងសេចក្ដីសុខស្ងប់ក្នុងសន្តាន ដែលអាចជំរុះចោលនូវសំយោជនក្កិលេស នឹងគ្រឿងសៅហ្មងគ្រប់យ៉ាងជាសមុច្ឆេទប្បហាន ។

លុះដល់ថ្ងៃទី ៧ ទ្រង់ជ្រាបថា "ទីអវសាននៃអាយុសង្ខារ របស់ព្រះអង្គចូលមកដល់ហើយ" ទើបក្រាបទូលព្រះសាស្ដាថា "អាយុសង្ខារនៃខ្ញុំព្រះអង្គនេះតិចណាស់ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលា នឹងបរិនិព្វានក្នុងថ្ងៃនេះហើយ, ទោសកំហុសណា ដែលកើតពីសេចក្ដីភាំងភ្លាត់ ដោយកាយ វាចា ចិត្ត សូមទ្រង់អភ័យទោសនោះ ដល់ខ្ញុំព្រះអង្គ ។ គ្រានោះសក្យរាជទាំងឡាយដែលមកប្រជុំគ្នាក្នុងទីនោះ កាលបើទ្រង់ព្រះសណ្ដាប់

ការទូលលានៃព្រះពុទ្ធបិតាដូច្នោះ ហើយ ក៏សំដែងបរិទេវនាការខ្សឹកខ្សួល អាឡោះអាល័យ ស្តាយព្រះអង្គ ដោយប្រការផ្សេងៗ ។ ព្រះបាទសិរីសុទ្ធោទនមហារាជ, ក្រោយដែលបានថ្វាយបង្គំលាព្រះសាស្តារួចហើយ, ទ្រង់ទំរេតព្រះកាយទ្រៀយចុះលើព្រះសេយ្យា ផុតខ្យល់អស្សាសប្បស្សាសៈ រំលត់ខន្ធជាអបុទ្ទិភេទ គឺបរិនិព្វានជាអវសាននៃអាយុសង្ខារក្នុងគ្រានោះឯង, ក្នុងព្រះជន្មាយុជាគំរប់ ៨៧ ឆ្នាំគត់ ហាក់ដូចជាប្រទីប ដែលរលត់ទៅដោយអស់ប្រឆេះនិងប្រេងដូច្នោះ ។ សក្យជនទាំងឡាយក្នុងព្រះរាជធានីទាំងមូល បានសំដែងសេចក្តីសោកស្តាយទន្ទឹះខ្សឹកខ្សួលគ្រប់ៗគ្នា ។ ព្រះសាស្តាទ្រង់សំដែងធម៌បន្ទោបង់នូវសេរ គឺសេចក្តីសោកសៅ នៃសក្យជនទាំងឡាយនោះហើយ ទ្រង់បង្គាប់ព្រះមហាកស្សបត្ថេរឲ្យពិនិត្យមើលទីបូជាព្រះបរមសព ។ ព្រះមហាកស្សបត្ថេរ ក្រោយដែលបានទទួលព្រះពុទ្ធដីកាហើយ, បានចេញទៅពិចារណាមើលភូមិឋានដ៏សមគួរដល់ការធ្វើឈាបនកិច្ចជាមួយសក្យជនទាំងឡាយ ។ លុះកំណត់យកឈាបនដ្ឋានមួយកន្លែងបានហើយ ទើបហៅជាងជំនាញៗ ជាច្រើនរូប ដែលថ្នឹក ក្នុងវិជ្ជាហត្ថកម្ម ឲ្យចាត់តែងធ្វើព្រះមេរុកូដាគារ ប្រដាប់ដោយកំពូល ៥០០ ពិចិត្រដោយក្បាច់ក្បូររចនា និងមាលាកម្ម លតាកម្ម ដោយឈើក្រអូបផ្សេងៗ យ៉ាងទាន់សម័យ តាក់តែងធ្វើជាចិតកធាន (ជើងថ្ករ) ដើម្បីនឹងដំកល់ព្រះបរមសព ។ (ក្នុងគម្ពីរប្រាប់ថា); ក្នុងកាលនោះ ទេវតាទាំងឡាយក្នុងលោកធាតុទាំងមួយម៉ឺន មានសក្កទេវរាជជាប្រធាន បានចូលមកជួយឧបត្ថម្ភយ៉ាងម៉ឺងម៉ាត់ក្នុងរឿងនេះ

ផ្កាបផល់បានសម្រេចជាព្រះមេរុមានលំអយ៉ាងត្រកាល ហាក់ដូចជាទេព
និម្មិត ដ៏សមគួរដល់ព្រះបរមសពនៃព្រះពុទ្ធបិតា ។ លុះសម្រេចហើយ
ទើបព្រះមហាកស្សបត្ថេរ ចូលទៅក្រាបបង្គំទូលព្រះសាស្តា ឲ្យទ្រង់
ជ្រាប ។ ព្រះសម្ពុទ្ធជាម្ចាស់, ដើម្បីសំដែងកតញ្ញូភាព ជាកិត្តិយសចំពោះ
ព្រះបរមសព ទ្រង់លើកព្រះសិរសានៃព្រះបិតាដោយព្រះហស្ត រួចទ្រង់
ស្រោចស្រពដោយព្រះសុគន្ធវារី, ព្រះធម្មសេនាបតីក៏ជួយស្រោះព្រំដោយ
ទឹកក្រអូប, ទើបព្រះបរមសម្ពុទ្ធទ្រង់ត្រាស់ថា " ម្នាលសារីបុត្រ!
បុគ្គលណាមួយ ប្រាថ្នាពោធិញ្ញាណ ចូរសំដែងកតញ្ញូតាធម៌ជាដើម
ចំពោះមាតាបិតា ឲ្យដូចតថាគតធ្វើក្នុងគ្រានោះចុះ ទើបបានសម្រេចពុំ
ខាន ព្រោះថា សេចក្តីកតញ្ញូនេះ ជាប្រធាននៃកុសលទាំងពួង " លុះ
ត្រាស់ដូច្នេះហើយ ទ្រង់លើកព្រះបរមសព ដាក់ក្នុងព្រះមឈូសរ័ត្ន ហើយ
លើកព្រះមឈូសដោយព្រះអង្គឯង នាំទៅដាក់លើជើងថ្ករ ដើម្បីធ្វើ
ឈាបនកិច្ចថ្វាយព្រះភ្លើង ។ គ្រានោះ ពួកព្រះញាតិ ក្នុងនគរទាំង ៦
មាននគរកបិលព័ស្តុ និងនគរទេវទហៈជាដើម ដែលធ្លាប់មានចិត្តស្វាមីភក្តិ
យ៉ាងជ្រាលជ្រៅ បានមកជួបជុំគ្រៀបគ្រា ដើម្បីធ្វើការប្រទក្សិណ សំដែង
គារវកិច្ច សុំខមាទោសចំពោះព្រះបរមសព តាមគន្លងប្រពៃណីគ្រប់ៗ
គ្នា ។ ពេលនោះ សក្កទេវរាជបាននាំយកកែវមណីជោតិ ដើម្បីថ្វាយព្រះ
ភ្លើង, ប៉ុន្តែ ព្រះសម្ពុទ្ធទ្រង់ឃាត់ថា "បពិត្រមហារាជ ! កិច្ចថ្វាយព្រះភ្លើង
ក្នុងគ្រានេះ ជាភារៈរបស់តថាគតទេ, ទើបទ្រង់ទទួលយកកែវមណីជោតិ

ពីព្រះឥន្ទ្រាធិរាជ មកបូជាដោយព្រះអង្គឯង ។ អណ្ដាតភ្លើងក៏ផុះផុល ចេញពីផ្នួនកែវពិសេសនោះ ឆេះព្រះបរមសព ព្រមទាំងដើនចក្រព្រោន ព្រោតពណ្ណរាយ ។ តមក ទើបទេវតាទាំងឡាយ មានសក្កទេវរាជជាដើម ព្រមទាំងសក្យជនទាំងឡាយ នាំគ្នាហាយព្រះភ្លើងតាមក្រោយ ។ លុះសម្រេចឈាបនកិច្ចហើយ ព្រះពុទ្ធទ្រង់បង្គាប់ ឲ្យសាងព្រះចេតិយ អញ្ជើញព្រះបរមធាតុព្រះពុទ្ធបិតា ទៅបញ្ចុះទុកជាទីសក្ការបូជាតទៅ ។

ការសំដែងមកអំពីដំណើរបរិនិព្វាន នៃព្រះពុទ្ធបិតា ក៏ល្មមសមគួរដល់កាលវេលា នឹងបញ្ចប់ត្រឹមប៉ុណ្ណេះឯង ។

ដោយអំណាចនៃធម្មទាននេះ, សូមឲ្យពុទ្ធសាសនារុងរឿងចំរើន នឹងផ្សព្វផ្សាយទៅក្នុងសាកលលោក !

សូមឲ្យព្រះករុណា ជាម្ចាស់ជីវិតទាំងពីរព្រះអង្គ នឹងសម្ដេចព្រះឧប. យុវរាជ បានប្រកបដោយសុខសួស្ដីសិរីវឌ្ឍិភាព ក្នុងសិរីរាជសម្បត្តិ សមតាមព្រះរាជបំណង !

សូមអស់លោក អ្នកជាពុទ្ធសាសនិកគ្រប់ឋានៈ ដែលអញ្ជើញមកពីទីជិតឆ្ងាយ បានសម្រេចនូវឥដ្ឋមនុញ្ញផលវិបុលសុខ សមតាមចេតនាបំណងរៀង ៗ ខ្លួន កុំបីឃ្លាត ! ជាពិសេស, សូមប្រជានិករក្នុងសាកលលោកទាំងមូល រាប់រកគ្នាតាមផ្លូវសន្តិភាព ចាប់តាំងពីពេលនេះតទៅ !

សទា ទិប្បតុ សទ្ធម្មោ សម្មាសម្ពុទ្ធទេសិតោ
ធរេន្តោ សព្វលោកស្ស ឧត្តមត្ថំ វិសុទ្ធិយា ។

សូមព្រះធម្ម ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងទុកមក ជាធម៌

បង្ហាញនូវមាគ៌ាដ៏ត្រង់ ទៅរកសេចក្តីបរិសុទ្ធិ ដល់សត្វលោកទាំងអស់ រុងរឿងចំរើនឡើងសព្វ ៗ កាលទៅហោង !

ចប់ ។

ឯវំ អយំ ធម្មទេសនា សង្ខេបេន សមត្តា

ព្រះធម្មទេសនាក្នុងរឿង "ពុទ្ធបិតុបរិនិព្វានខេះ" សន្មតជាចប់ដោយសង្ខេប ឯវំ ។

សេចក្តីប្រារព្ធ

ព្រះបាទសុទ្ធោទនមហារាជ
ត្រើសទ្រង់អំណាចត្រង់រដ្ឋ
លុះទ្រង់សណ្តាប់ធម៌ទេសនា
នៃព្រះសាស្តាអង្គជិនស្រី ៗ
ទ្រង់បានសម្រេចអរហត្តផល
លះបង់កន្លល់ក្នុងភពបី
បានប្រាំពីរថ្ងៃ និព្វានទៅ
ពស៍កៅសិបប្រាំពីរឆ្នាំ

ស្រី - អ៊ូ

## ពុទ្ធគុណ

ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ រៀបរៀង

ក្នុងគម្ពីរ មានសេចក្តីថា គុណរបស់ព្រះសម្មាសម្ពុទ្ធច្រើនណាស់ រាប់មិនអស់ទេ ដូចមានបទបាលីថា:

ពុទ្ធោបិ ពុទ្ធស្ស ភណេយ្យ វណ្ណំ
កប្បម្បិ ចេ អញ្ញមភាសមានោ
ខីយេថ កប្បោ ចិរទីឃមន្តរេ
វណ្ណោ ន ខីយេថ តថាគតស្ស ។

សូម្បីព្រះពុទ្ធទ្រង់សំដែងតែអំពីគុណនៃព្រះពុទ្ធផងគ្នា មិនសំដែងពីរឿងអ្វីដទៃសោះ រហូតអស់មួយកប្ប កប្បដ៏យឺនយូរវែងឆ្ងាយ ក៏នឹងអស់ទៅទេ ក្នុងចន្លោះនោះ ឯគុណនៃព្រះពុទ្ធមិនអស់ទៅផងឡើយ ។

សហស្សសីសេបិ ចេ ហោសេ
សីសេ សីសេ សតំ មុខា
មុខេ មុខេ សតំ ជិវ្ហា
ជីវកប្បេ មហិទ្ធិកោ
ន សក្កោតិ ច វណ្ណេតុំ
និស្សេសំ សត្ថុនោ គុណំ ។

ប្រសិនបើ មានបុរសម្នាក់ មានក្បាលមួយពាន់, ក្នុងក្បាលមួយមានមាត់មួយរយ, ក្នុងមាត់មួយ មានអណ្តាតមួយរយ, បុរសនោះអាយុវែងចំនួនមួយកប្ប មានឫទ្ធិច្រើន ក៏មិនអាចនឹងរៀបរាប់គុណ នៃព្រះសាស្តាឲ្យអស់រលីង គ្មានសេសសល់បានឡើយ ។

ប៉ុន្តែ គុណនៃព្រះពុទ្ធ ទោះបីច្រើនដល់ម៉្លោះក៏ដោយ គង់លោកសង្គ្រោះចូលក្នុងគោលធំបំផុត ៣ យ៉ាង គឺ

១- វិសុទ្ធិគុណ,

២- បញ្ញាគុណ,

៣- ករុណាគុណ ។

អធិប្បាយ: (១)

សូម្បីព្រះនាមទាំង៩ តាំងពី អរហំ ដល់ ភគវា ក៏សង្គ្រោះចូលក្នុងពុទ្ធគុណ ដែលជាគោលធំបំផុតទាំង៣ នោះដែរ គឺ អរហំ ជាគ្រឿងប្រកាសព្រះវិសុទ្ធិគុណ ។ សម្មាសម្ពុទ្ធោ ១ វិជ្ជាចរណសម្បន្នោ ១ សុគតោ ១ លោកវិទូ ១ ទាំង ៤ នេះ ជាគ្រឿងប្រកាសព្រះបញ្ញាគុណ ។ អនុត្តរោ បុរិសទម្មសារថិ ១ សត្ថា ទេវមនុស្សានំ ១ ពុទ្ធោ ១ ភគវា ១ ទាំង ៤ នេះ ជាគ្រឿងប្រកាសព្រះករុណាគុណ ។ ព្រះនាមទាំង៩ មានបទបាលី ក្នុងនវហរគុណ និងសេចក្តីប្រែដូចតទៅនេះ ៖

១- អារកត្តា កិលេសេហិ សវាសនេហិ សោ មុនិ
សព្វបូជារហត្តា ច វិទិតោ អរហំ ឥតិ ។

ព្រះមុនីអង្គនោះ លោកហៅព្រះអង្គថា « អរហំ » ព្រោះព្រះអង្គឆ្ងាយចាកកិលេស ព្រមទាំងវាសនា ១ ព្រោះព្រះអង្គគួរទទួលសក្ការបូជារបស់មហាជនទូទៅ ១ ។

២- សម្មា សាមញ្ច សច្ចានិ ពុទ្ធោ ច អញ្ញាពោធនោ

---

១) ច្បាប់ពុទ្ធគុណបរិយាយ របស់ពុទ្ធសាសនបណ្ឌិត្យលេខ ម.៨ ទំព័រ១៩៣ ។

ពោធេស សម្មាសម្ពុទ្ធោ សព្វធម្មេសុ ចក្ខុមា ។

ព្រះអង្គត្រាស់ដឹងអរិយសច្ចទាំងឡាយ ដោយប្រពៃចំពោះព្រះអង្គ ១ ទ្រង់ដឹកនាំអ្នកដទៃឲ្យត្រាស់ដឹងតាម ១ ព្រោះហេតុនោះ ព្រះអង្គមានចក្ខុក្នុងធម៌ទាំងពួង ទើបទ្រង់ព្រះនាមថា "សម្មាសម្ពុទ្ធោ" ។

៣- វិជ្ជាហិ ចរណេហេស សម្ពុទេវ សមាគតោ
វិជ្ជាចរណសម្បន្នោ ឧត្តមោ ទេវមានុសេ ។

ព្រះអង្គប្រកបដោយវិជ្ជា ៣ និងចរណៈ ១៥ ដោយប្រពៃ ទើបទ្រង់ព្រះនាមថា "វិជ្ជាចរណសម្បន្នោ" ព្រះអង្គខ្ពស់ក្នុងពួកទេវតា និងមនុស្ស ។

៤- សព្វត្ថសប្បហានេន គតោ សោ សុគតោ មុនិ
សម្មា គមាយេន ភាចាយ មនសា សុគតោ គតោ ។

ព្រះមុនីអង្គនោះស្តេចទៅ ដោយការលះបង់កិលេសទាំងពួង (មួយទៀត) ឈ្មោះថា ទ្រង់យាងទៅប្រពៃ ដោយកាយ, វាចា ចិត្ត ទើបទ្រង់ព្រះនាមថា "សុគតោ" ទ្រង់យាងទៅប្រពៃ ។

៥- លោកំ វិទូ គតោ សព្វំ ញាណេនាញាសិ សព្វថា
ជាថោ លោកស្ស សម្មា តេន លោកវិទូ ជិនោ ។

ព្រះជិនៈអង្គនោះជាទីពឹងរបស់លោក ទ្រង់ជ្រាបលោកទាំងអស់ យ៉ាងជាក់ច្បាស់គ្រប់ប្រការ ដោយព្រះញាណដ៏ប្រពៃ ហេតុនោះ ទើបទ្រង់ព្រះនាមថា "លោកវិទូ" ព្រះអង្គទ្រង់ជ្រាបលោកជាក់ច្បាស់ ។

៦- សារថោ នរទម្មានំ អក្កុបប្បាយ វិមុត្តិយំ

តតោ អនុត្តរោ ជាតោ បុរិសទម្មសារថិ ។

ព្រះអង្គទ្រង់ដឹកនាំអ្នកដែលគួរទូន្មានបាន ឲ្យធ្វើដំណើរទៅកាន់វិមុត្តិដ៏មិនកម្រើក ព្រោះហេតុនោះ ព្រះអង្គជាលោកនាថ ទើបទ្រង់ព្រះនាមថា "អនុត្តរោ បុរិសទម្មសារថិ" ព្រះអង្គជាសារថីទូន្មានបុរសពុំមានអ្នកណាប្រៀបផ្ទឹមស្មើបាន ។

៧- លោកិយេហិ ច អត្ថេហិ អថោ លោកុត្តរេហិ ច

សត្ថា ទេវមនុស្សានំ សាសិតា ទេវមានុសេ ។

ព្រះអង្គទ្រង់ប្រៀនប្រដៅទេវតានឹងមនុស្ស ដោយលោកិយប្រយោជន៍ នឹងលោកុត្តរប្រយោជន៍ ទើបទ្រង់ព្រះនាមថា "សត្ថា ទេវមនុស្សានំ" ព្រះអង្គជាសាស្តារបស់ទេវតានឹងមនុស្សទាំងឡាយ ។

៨- សម្ពុជ្ឈិតា ច សព្វានិ ក្លេសនិទ្ទា បពុជ្ឈិតា

សព្វសោ គុណវិកាសរ – មូលេតា ពុទ្ធោ នរុត្តមោ ។

ព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយផង ទ្រង់តើនចាកកិលេសនិទ្រាផង ព្រះអង្គរីកពេញដោយព្រះគុណគ្រប់យ៉ាង ទើបទ្រង់ព្រះនាមថា "ពុទ្ធោ" ព្រះអង្គត្រាស់ដឹង ខ្ពង់ខ្ពស់ជាងនរជនទាំងឡាយ ។

៩- ភាគ្យេន ភគធម្មេហិ សមង្គី ធាតុលោ មុនិ

គរុគារវយុត្តោ ច វិស្សុតោ ភគវា ឥតិ ។

ព្រះអង្គប្រកបព្រមដោយជោគជ័យ នឹងភគធម៌ ៦ ប្រការ គ្មានអ្នកណាប្រៀបស្មើបាន ទើបទ្រង់ជាទីគោរពរបស់គ្រូអាចារ្យផង លោកថ្វាយព្រះនាមថា "ភគវា" ព្រះមានព្រះភាគ ។ (ចប់សូត្រមន្ត) ។

ព្រះនាមទាំង៩នេះ ជាព្រះគុណនេមិត្តកនាម ព្រោះជាប់មកតាមហេតុគឺគុណវិសេស មានអរហំជាដើម ដែលមានក្នុងសន្តាននៃព្រះពុទ្ធអង្គ ឥតអ្នកណាថ្វាយឡើយ ស្រាប់តែលេចឮល្បីខ្ចរខ្ចាយឡើងឯង១ តែម្តង ជាមួយនឹងសព្វញ្ញុតញ្ញាណ ដែលព្រះអង្គបានក្បែរគល់ព្រះមហាពោធិព្រឹក្ស ។ ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់មានព្រះគុណនេមិត្តកនាមទាំង ៩ នេះ ដូចៗគ្នា ឥតប្លែកពីគ្នាឡើយ ។

ប៉ុន្តែ ក្នុងគម្ពីរវជិរសារ លោកញែក អនុត្តរោ ជាព្រះនាម១ បុរិសទម្មសារថិ ជាព្រះនាម១ រួមជា ១០ ព្រះនាម មានបទគាថា ថា:

យស្ស ទសក្ខរា អ-សំ-វិ-សុ-លោ អ បុ ស-ពុ-ភ
វចសា បគុណា ភូតោ មនសា សោ សុខំ លភេ ។

អក្ខរៈទាំង១០តួ គឺ អ សំ វិ សុ លោ អ បុ ស ពុ ភ ក្តី សេចក្តីអធិប្បាយ (នៃអក្ខរៈទាំង ១០ តួនោះ) ក្តី គឺបុគ្គលឯណាមួយ ទោះជាគ្រហស្ថក្តី ជាបព្វជិតក្តី បានធ្វើឲ្យចាំស្ទាត់ដោយវាចាចិត្តហើយ គ្រហស្ថនឹងបព្វជិតទាំងនោះ ទៀងតែបាននូវសេចក្តីសុខ ។

ឯអក្ខរៈទាំង ១០ តួនោះ ជាអាទិសង្កេត គឺ អ - អរហំ ។ សំ - សម្មាសម្ពុទ្ធោ ។ វិ - វិជ្ជាចរណសម្បន្នោ ។ សុ - សុគតោ ។ លោ - លោកវិទូ ។ អ - អនុត្តរោ ។ បុ - បុរិសទម្មសារថិ ។ ស - សត្ថា ទេវមនុស្សានំ ។ ពុ - ពុទ្ធោ ។ ភ - ភគវា ។

ព្រះពុទ្ធគុណសង្ខេបប៉ុណ្ណេះ ។

សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់

## លោក ភិយ-ប៊ុក រៀបរៀង

### ១ - អំពីរឿងហែសព

មានកាលថ្ងៃមួយ ខ្ញុំបានទៅហែសពមិត្រម្នាក់ ៗ ក្នុងពេលដែលធ្វើដំណើរទៅតាមវិថីក្រុង ឃើញទិដ្ឋភាពពីរប្រការគឺ

ក) បុត្រ, ធីតា, ញាតិសាច់សាលោហិត ខ្លះស្លៀកពាក់ស, ខ្លះកោរក្បាល យំដើរពីក្រោយក្ដារមឈូសដែលតម្កល់សព, សោកសង្រេង អាឡោះអាល័យសព ដោយពាក្យទំនួញ, ជំនួញសព្វគ្រប់ប្រការ ៗ ក្នុងមជ្ឈដ្ឋាននេះ ជាទុក្ខ, សោក, ជាទីចង្អៀតចង្អល់ ជាទីខ្មៅងងឹត, គ្មានសង្ឃឹម ៗ សូម្បីតែធម៌ត្រៃលក្ខណ៍ ដែលព្រះភិក្ខុសំដែងថា រូបំ អនិច្ចំ, រូបំ ទុក្ខំ, រូបំ អនត្តា, ក៏គិតមិនឃើញទេ ក្នុងពេលនោះ ព្រោះមនុស្សទាំងនោះ ត្រូវទុក្ខមកគ្របសង្កត់ស្ទើរតែបាត់វិញ្ញាណស្មឿងឈឹង ៗ ទុក្ខមានអានុភាពខ្លាំងពន់ពេក, មិនអាចឱ្យអ្នកទាំងនេះពិចារណាធម៌បាន ៗ គិតទៅស្រមៃបាក់ដូចឃើញតែសព, ដំណើរស្បូវសំដីជាដើម, ដល់បាត់រូបនោះទៅ, ចង់ឃើញរូបនោះវិញ តែមិនឃើញសោះ, ក៏តាំងតែស្រែកយំ អួលអាក់សោកស្ដាយ ៗ បើចិត្តជ្រមុជទៅក្នុងសាគរទុក្ខទៅហើយ, បានអ្វីមកគិតពីធម៌ ដែលជាឧបាយរំលត់ទុក្ខនោះបាន ព្រោះហេតុដូច្នេះ បានជាគ្រូបាអាចារ្យទូន្មានប្រដៅថា "ធម៌នេះ ត្រូវគិតទុកជាមុន, ត្រូវពិចារណាទុកសេចក្ដីស្លាប់នេះជាមុនថា: អញមុខជានឹងស្លាប់ថ្ងៃណាមួយមិនខាន, ការស្លាប់ទៀង ការស្លាប់ជាធម៌ពិតប្រាកដ ការស្លាប់គ្មានអ្នកណាចៀសរួច ជាដើម" ៗ លុះពិចារណា

ជាមុន, គិតគូរមុន, ទម្លាប់ចិត្តឲ្យត្រិះរិះហេតុផលជាមុន, ទើបស្គាល់ធម៌ស្លាប់នោះច្បាស់លាស់ ដល់សេចក្ដីស្លាប់មកដល់ មិនស្លុតតក់ស្លុតនឹងសេចក្ដីស្លាប់ពេក ៗ បើឃើញបិតាមាតា ឬ ស្វាមី ភរិយា បុត្រ ធីតា ទទួលមរណភាព, មិនសូវជាសោកស្ដាយពន់ពេក ដោយគិតថា "សេចក្ដីស្លាប់មានពិតប្រាកដ, គ្រាន់តែមួយស្លាប់មុន, មួយស្លាប់ក្រោយ" ឬ គិតថា: "កាលគេមកកើត ក៏គេមិនបានមកសូមអញ កាលគេស្លាប់ទៅវិញ, ក៏គេមិនបានលាអញ, តើអញសោកស្ដាយធ្វើអ្វី?" ។ កាលបើបុគ្គលបានពិចារណានូវសេចក្ដីស្លាប់រឿយ ៗ, ការពិចារណានោះនឹងទៅជាមរណានុស្សតិកម្មដ្ឋាន; អ្នកណាបានពិចារណាមរណានុស្សតិកម្មដ្ឋាន, អ្នកនោះឈ្មោះថាមិនប្រមាទ ជាហេតុនាំឲ្យកើតសេចក្ដីសង្វេគ, ជ្រះថ្លាក្នុងការកុសល ឈ្មោះថា ញុំាងចិត្តឲ្យតាំងនៅក្នុងកុសលធម៌ ធ្វើចិត្តឲ្យប្រាសចាកនីវរណធម៌ នឹងបានលុះក្នុងឈានណាមួយមិនខាន ព្រោះមានពុទ្ធភាសិត ក្នុងគម្ពីរធម្មបទត្រង់ចិត្តវគ្គថា:

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ប្រែថា: ការទូន្មានចិត្តដែលគេសង្កត់សង្កិនបានដោយក្រ ធម្មតារហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ជាគុណឲ្យសំរេចប្រយោជន៍ ព្រោះចិត្តដែលគេទូន្មានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

## ១ – អ្នកដែលហែសព

ភរិយាអ្នកដែលហែសព មិនមានសភាពខុសគ្នាពីបុត្រ, ធីតា, ញាតិ

សាលោហិតសពនោះទេ ព្រោះថា គ្រប់ពេញអាកប្បកិរិយា ជាអ្នកទទួលទុក្ខជាមួយនឹងបុត្រ, ធីតា, ញាតិសាលោហិតនោះដែរ គឺត្រូវធ្វើទឹកមុខស្រងូត, ស្រងាត់ ធ្វើដំណើរស្ងប់ស្ងៀម ; អាកប្បកិរិយាសមរម្យទៅតាមមរណកាល ចិត្តនឹករលឹកដល់មរណានុស្សតិកម្មដ្ឋាន ឬអសុភកម្មដ្ឋាន ឬកាយគតាសតិកម្មដ្ឋាន ដើម្បីនឹងញុំាងចិត្តឲ្យសង្វេគ, ឲ្យជ្រះថ្លាក្នុងការកុសល ។ ត្រូវគិតថា ការស្លាប់, ជាធម៌ទៀង, ខ្លួនអញក៏ស្លាប់ ខ្លួនអញចៀសពន់នូវសេចក្តីស្លាប់មិនបាន ត្រូវតែស្លាប់. សត្វណាកើតហើយ សត្វនោះតែងតែស្លាប់ មានសេចក្តីស្លាប់ជាបរិយោសាន ខុសគ្នាតែមួយស្លាប់មុន មួយស្លាប់ក្រោយ ដូចមានពុទ្ធភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយថា:

អចិរំ វតយំ កាយោ ឋវឹ អធិសេស្សតិ
ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ប្រែថា កាយនេះមិនយូរប៉ុន្មាន តែមានវិញ្ញាណទៅប្រាសហើយ ត្រូវបោះបង់ចោល ដេកសន្ធឹកលើផែនដី ដូចបំណាក់ឈើឥតប្រយោជន៍គ្មានខ្លឹម ។

បើបានពិចារណាយ៉ាងនេះជាដើម ក្នុងពេលដែលដើរហែសព មុខជានឹងកើតសេចក្តីសង្វេគពុំខាន ។

ក្នុងពេលដែលដើរហែសព ពុំគួរប្រើកិរិយាមុខស្រស់ស្រាយ ធ្វើអាកប្បកិរិយាកក្រើកសើចខ្ចាកខ្ចាយ និយាយដាក់គ្នាញុញញឹមញញែមសើចក្អាកក្អាយដែលជាហេតុមិនសមរម្យដល់ការហែសពឡើយ ។ (មានត)

# ផ្នែកអក្សរសាស្ត្រ

## សុភាសិតលាវ

### លោក រ៉ាយ-ប៊ុក ដកស្រង់ហើយរៀបរៀង

១- កាលណាគេឮ ត្រូវតែគេមើលថែម, កាលណាគេឃើញ គេត្រូវតែយកចិត្តមកត្រិះរិះទៀត ។

២- ត្រូវជឿតែត្រចៀកមួយ ទុកត្រចៀកមួយទៀតសម្រាប់ត្រិះរិះ ។

៣- ត្រីមួយត្រក, ស្អុយតែមួយ ស្អុយទាំងអស់,

៤- ការសេពគប់នឹងពួកល្អ ចំហាយល្អតែងជិតជាមជាប់ពណ៌មក ។ ការសេពគប់នឹងពួកអាក្រក់, ចំហាយអាក្រក់តែងជិតជាមទូវគ្រឿងស្អុយជាប់មកជាមួយ ។

៥- ចិត្តល្អប្រសើរជាងរូបល្អ ។

៦- ការចេះធ្វើមិនដល់ការពិសោធន៍ ។

៧- បើគេធ្វើកិច្ចការអ្វី ៗ ត្រូវព្យាយាមធ្វើដោយចិត្តមុឺងម៉ាត់ ទោះបីមានគូសត្រាបោកផ្អិនជំនីរមួយពាន់ដងក៏ដោយ, មិនត្រូវធ្វើតាមឡើយ ។

៨- ចូរយើងអត់ទ្រាំកុំយកក់, បើយើងចង់បរិភោគអន្ទង់ ។

៩- សត្វជើងបួនគង់មានភ្លាត់, អ្នកប្រាជ្ញចេះស្ទាត់គង់មានខុស ។

១០- ត្រូវឆ្លងកាត់ខាងលើទន្លេសិន សឹមឲ្យធ្លាក់ទៅខាងក្រោមទន្លេជាក្រោយ ។

១១- ម្ហូបអាហារពេញថាសប្រាក់ មិនស្មើចំណេះវិជ្ជាពេញពោះ ។

១២- ប្រាក់ដប់ស៊ិនបិតនៅត្រើយម្ខាង, អំពីមុខយើង កុំយើងប្រញាប់ប្រញាល់ពេក ប្រាក់តែពីរស៊ិនតែចូលក្នុងដៃយើង, ត្រូវប្រញាប់យកភ្លាម ។

១៣- វាយោបក់ទៅទិសខាងណា, គេត្រូវទៅទិសខាងនោះ ។

១៤- ខ្លះមានចិត្តក្លាហាននៅភូមិ ទៅជាខ្លាចព្រៃ ។

១៥- ចង់ដឹងដំរី ដោយមើលកន្ទុយ, ចង់ដឹងនាងកញ្ញា ដោយមើលមាតា ។

១៦- ឆ្នូតស្នាមមនុស្សបិតនៅខាងក្នុង, ឆ្នូតខ្លាបិតនៅខាងក្រៅ ។

១៧ ខ្លួនខ្សោយ, ចង់គ្របព្រះចន្ទ ។

១៨- ទីទាបបាក់ជ្រោះចេះតែទាបទៅ, ទីខ្ពស់ផុះចេះតែខ្ពស់ឡើង ។

១៩- អ្នកមានចេះតែមាន, អ្នកក្រ ចេះតែក្រ ។

២០- សំឡេងអ្នកក្រគ្មានអ្នកណាឮ ។

២១- អង្កត់មួយសម្លួយកំណាត់ មិនអាចធ្វើភ្លើងឲ្យឆេះបានឡើយ ។

២២- បើគ្មានប្រជារាស្ត្រ កេត្រានៃព្រះអង្គម្ចាស់ មិនអាចត្រាច់ទៅមុខបាន ។

២៣- ខ្លួនជាអន្ទង់, ចង់ស៊ីឈាមក្ដាម ។

២៤- ខ្យល់ព្យុះសង្ក្រា មិនខ្លាំងជាងខ្យល់មាត់ ។

២៥- អ្នកណាបរិភោគអាហារក្តៅ ទើបឃើញពោះខ្លួនចេញចំហាយក្តៅមិនខាន ។

២៦-- ក្របីចាស់ចូលចិត្តស្មៅខ្ចី ។

២៧- បើកាលណាម្ហូបក្តៅ ត្រូវតែទទួលទាន, បើកាលណាស្រវឹង ត្រូវតែកាំ ។

២៨- ជើងហត្ថីយកទៅបិទចំពុះបក្សា ។

២៩- ចំនួនប្រាក់យើង នឹងបានដល់ជាងមួយរយរៀល ដោយហេតុយើងស្រឡាញ់ ហើយសន្សំទុកតាំងពីមួយរៀលឡើងទៅ ។

៣០- អត់ធន់ប្រាំបួនដង នឹងព្យាយាមប្រាំបួនដង នឹងបានប្រាក់ណែនមាស ។

៣១- ការងារជាហេតុឱ្យកើតភោគទ្រព្យ ។

៣២- បើយើងរស់នៅជាមួយពួកត្មាត, យើងទៅជាបាត្មាត ។ បើយើងរស់នៅជាមួយពួកក្អែក, យើងនឹងទៅជាក្អែក ។

៣៣- មាត់ដប់ដែលពោល មិនស្មើនឹងឃើញដោយភ្នែកខ្លួនឯង ។ ភ្នែកដប់ដែលឃើញ មិនស្មើនឹងវត្ថុដែលកាន់ជាប់នៅដៃ ។

៣៤- ស្ថានសួគ៌នៅក្នុងដើមទ្រូង, ស្ថាននរកនៅក្នុងបេះដូង ។

៣៥- ស្អាងប្រាសាទនៅលើអាកាស ។

៣៦- យកដាវកាប់ទឹក ។

៣៧- បើកាលណាក្របីជល់គ្នា, ក៏ខ្ទិចស្មៅ ។

៣៨- ដាក់ទឹកមួយដំណក់ ៗ ទៅក្នុងពាងធំ ។

៣៩- ដបទឹកទទេ ឮសូរខ្លាំង ។

៤០- មាន់ល្អព្រោះរោម, រូបឆោមល្អព្រោះតែង ។

៤១- ចិញ្ចឹមពស់ដើម្បីឱ្យវាចឹកយើង ។

៤២- បើគេផ្លាស់ប្តូរទឹកខ្លួន, គេនឹងខាតទឹកខ្លួន បើគេបោះបង់ចោលគេហដ្ឋាន, គេនឹងបាត់បង់គេហដ្ឋាន ។

៤៣- អ្នកណាលោភហួស, សំណាងរត់ឆ្ងាយ ។

៤៤- មាសធ្លាក់លើដី មិនស្រអាប់ពណ៌សម្បុរទេ ។

៤៥- ទុំបេះទៅ, ត្រីវមក ។

៤៦- ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ។

៤៧- ទឹកត្រជាក់ត្រីរ៉ាកុម, ទឹកក្តៅត្រីទៅអស់ ។

៤៨- ផ្លែឈើមិនដែលជ្រុះឆ្ងាយពីគល់ ។

៤៩- កូនក្មេងមិនស្គាល់ដំរេក, គេមិនស្គាល់ប្រូ ។

៥០- សរសេរដូចមាន់កកាយដី ។

៥១- ទៅភូមិដែលគ្មានមាន់រងាវ ។

៥២- ឈើត្រង់ដូចគេចេះ, ឈើចិត្តដូចខ្ទះបាញ់ ។

៥៣- ដុំឫសនៅជិតត្រចៀកក្របី ។

៥៤- ដាក់អំបុកនៅលើដៃស្វា ។

៥៥- បើកាលណាមនុស្សរលំ, គេមិនដើរកន្លងខ្លួនទេ, បើកាលណាដើមឈើរលំ, គេកន្លងបាន ។

៥៦ មាត់ពោលញាប់នាំមិនឲ្យកុកចិត្ត, ជើងហើសនាំឲ្យរលំដើមឈើ ។

រឿងទេវជ្ជ

ពាក្យកាព្យ

# លោក អម្ពតក្សត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

## លោក ញ៉ុក ថែម ពិនិត្យ

(ទី១)

---

ទាំងបួនកម្មកណ្ណ នុទអគ្គិអគ៌ន្ទ ទូលទៅទៀតថា បពិត្រអ្នកមាន
វិញ្ញាណថ្លៃថ្លា សូមអ្នកមេត្តា សំដែងសុចរិត ។ ដែលអ្នកថ្លែងថា
មានដប់ប្រការ តែកបែរបទបិទ ដូចម្តេចដៀងជាក់ សូមអ្នកគណិត
សំដែងឲ្យពិត ឲ្យពិស្តារទៅ ។ ពោធិសោភ័ណ ប្រាជ្ញាដទៃ តក្ខណប្រាល-
ជ្រៅ ស្តេចបើកព្រះសូរ មធុរក្រអូន សំដែងដោយនូវ បទបាទគាថា។

យេចន៍ សុចរិត សុរសេរិតា ចរិតាន ទសវិធា រ៉ៃសិត្តា
អកុសល ។ បទបន្ទូថា បើអ្នកឯណា បរិវ្ជ័យ មែនមានវិញ្ញាណ
ប្រែប្រាណប្រាសប្រែ ទុច្ចរិត អំពីទុច្ចរិត ។ ទសវិធា ទាំងដប់ប្រការ
វៀរពុំឲ្យជិត ដល់អគ្គិពល់ យកផលសុចរិត នោះមកបាំងបិទ នៃ-
គន្ធិកគា ។ យេចនំ សុចរិត បន្ទូអើយនរណា ប្រាស់ប្រែប្រព្រឹត្ត
នូវសុចរិតា ទាំងដប់ប្រការ ហៅព្រះធម្ម ។ គឺវៀរបាណា វៀរអទិន្នា

មួយវៀរកាមេ វៀរទាំងបីបទ ប្រាកដឯងនឹង ហៅសុចរិត សុចរិត-ដោយកាយ ។ វៀរពាក្យកុហក វៀរពាក្យអាក្រក់ ពុំគួរនិយាយ វៀរពាក្យញុះញង់ ឲ្យបង់ព្រាត់ព្រាយ ញាតិសាច់ទាំងឡាយ នៃអ្នកដទៃ ។ មួយវៀរទ្រគោះ ពាក្យអសុរោះ ឥតសព្វសម័យ ប្រទះប្រទូស្ត រឹងរូសពេកក្រៃ បង្ហិនបង្ហៃ ណាក់នៃអ្នកផង ។ ពុំបេះបន្ទន់ បន្អាប់-ផ្ចាញ់ភ្ចាន់ អាចឲ្យមានទុក្ខ ទាំងប្អូនទះណា អាចារ្យលោកចង យមដោយគន្ថ ហៅពាក្យសុចរិត ។ មួយវៀរលោភា វៀរព្យាបាទា មួយវៀរបោកបិត្ត មិច្ឆាទិដ្ឋិ អប្រិយពេកគិត នេះហៅប្រព្រឹត្ត ដោយ-ព្រះធម្ម ។ គាថាទាំងបីបទ អ្នកប្រាជ្ញសង្ខេត ប្រាកដហៅថា សុចរិត-មនោ វិវេក សត្តនេតា ខប្ដិស្សត្ត ។ អ្នកណាប្រព្រឹត្ត នូវធម៌សុចរិត ទាំងដប់ប្រក្រតី អ្នកនោះនិរទុក្ខ សោយសុខសិរី កៀមគក្កុទក្នុងត្រៃ · ពិធៈសម្បត្តិ ។

បតុយក្ខា អតិវន្នា ថ្វាយជាបរិស័ទ ទើបទូលដណ្ដឹង ទៅវិញទៀតថាត់ បពិត្រមហាក្សត្រ បុរសប្រសើរ ។ អ្នកដែលប្រព្រឹត្ត កាន់ធម៌សុចរិត ទាំងដប់នោះតើ បានមគ្គបានផល ដោយគល់អំពើ អំពីខ្លួនធ្វើ នោះដូចម្ដេចខ្លះ ។

ពន្លកពង្សពោធិ សត្វសេដ្ឋា នរអ្នកបុណ្យក្រាស់ លោកនាថោ បញ្ញាជ្រៅជ្រះ ប្រិមប្រិយបើកព្រះ សូរសំដែងថា ។ អ្នកណាប្រព្រឹត្ត-កាន់ធម៌សុចរិត ទាំងដប់ប្រការ រក្សាសីលទាន វិញ្ញាណធម្មចារ វៀរទុច្ចរិតា ទាំងដប់នោះបង់ ។ អ្នកនោះប្រសើរ ពោះយោបីបើ អ្នក

នោះកើតក្នុង ចតុទ្វីបស្មោះ ប្រឡោះប្រឡង់ នៅពូជសង្សារសោក.
សុខសាន្ត ៗ ពុំដែលចួបចួល ចួបចាប់ត្រកូល អប្បឥតសន្តាន ឥត
សៅឥតសព្ទ ឥតទ្រព្យធនធាន ពុំដែលទីងមាន ទុក្ខទោមនស្ស ៗ
ពុំដែលព្រាត់ប្រាស ព្រាត់ព្រាយវិនាស លែងញាតិកា កើតតែត្រកូល
អម្បូរថ្លៃថ្លា ប្រកបសក្តិតា សម្បត្តិធនធាន ៗ មានរូបល្អក្រៃ លែង
មនុស្សដទៃ កម្រផ្ទឹមបាន មានតាំងស្រះស្រី នៅព្រៃឧទ្យាន សម្រាប់
បិទបាន កាន់ដោយសុចរិត ៗ សម្បត្តិបរបូល កែវកងមិតមូល ពុំបានរិះគិត
អ្នកនេះវិសាល ត្រកាលពេកក្តិត បរិបូណ៌ឯងឥត ថ្លៃថ្លឹងឧបមា ៗ កើត
ជាចក្រពត្តិ ធិរាជមហាក្សត្រ ទោះទៅឋានណា ទេពមនុស្ស ទូទាំង
ទេព្តា ទូអស់មនុស្សម្នា សោតសិង្រ ញ់ ៗ ស្នេហាទុកចិត្ត ដូច
ញាតិដូចមិត្រ ឥតមានមនោម្នេញ ទោះទ្រព្យធនធាន ឥតមានមោះវិញ
ហេតុអ្នកនោះមិញ កាន់ធម៌សុចរិត ៗ ហើយមានតេជះ តេជោតបះ
ទោះបច្ចាមិត្រ ទសទិសបាក់បែ ខ្ទាចខ្ទបក់រែ ចុះចាលចាញ់បិទ បុណ្យ
បារមីមាន ៗ ជាសុខសល់ខ្នាត លុះលង្វែងជាតិ ជាបរិយោសាន
ម្ងាន់រូបស្មោះ អ្នកនោះនៅបាន ទៀងទៅនិព្វាន បរមសុខក្តិត ៗ បូរ
អស់ព្រះស្តែង ប្រុងប្រែលះលែង កុំកាន់ទុច្ចរិត កាន់សុចរិតជា ធម្មា
ពេញពិត ឲ្យបានសម្រិទ្ធ សម្រេចប្រាថ្នា ៗ អស់អង្គព្រះស្តែង នេះ
ហៅវេស្ទ័ន អិតមគ្គា គួរគិតស្វែងស្នាក់ រកអ្នកឯណា មានញាណប្រា.
ជ្ញា បង្ហាញទិសទី ៗ ទៅកាន់បរលោក បៀសបាកទុក្ខសោក បង់បញ្ចូ.

ឥន្ទ្រិយ ប្រែប្រាសលះលោក បៀសបាតអំពី អំពើអវិ - ជ្ជាជាតិជរា ។
ព្រះធម៌នេះគាប់ ប្រសើរជាច្បាប់ ឧត្តមថ្លៃថា ក្រអ្នកណាមាន វិញ្ញាណ-
តែងការ រសធម៌គាថា វិសេសសេដ្ឋ ។ ចូរអស់ក្រុងយក្ខ ចងចាំជៀង
ជាក់ ទុកលើសិរសី ធម៌នេះប្រសើរ ស្មោះស្មើជីវី អម្រឹតធារធំ ដល់បរ-
លោកច្បាស់ ។ ធម៌នេះព្រះពុទ្ធ ប្រពៃបរិសុទ្ធ ព្រះអង្គបានត្រាស់ ទេសន៍
ទូន្មានជន អរហន្តក្រៃក្រាស់ ជ្រុតជ្រាប ជ្រៅជ្រះ ល្អិតល្អក្រៃក្រៃ ។

ពន្ធកសារពេជ្រ សំដែងធម៌ស្រេច ទើបទាំងគពៃ ទេវទូតព្រហ្ម
ទៅព្រឹក្សព្រៃ សឹងអរទៀងជ័យ សត្វសាធុការ ។ ក៏ប្រាក់ក៏មាស ធ្លាក់
មកពេញពាស ដោយដីដាសដា រញ្ជួយព្រឹក្សព្រៃ ពន្ធកអស្ចារ្យ ហេតុ
ដោយសម្ភារ បុរសដ៏ថ្លៃ ។

កុម្ភណ្ឌបួនយល់ ហេតុអស្ចារ្យសល់ សឹងអរទៀងជ័យ សត្វស្រែក
អឺងកង រំពងព្រះព្រៃ សរសើរបុណ្យនៃ ពោធិសត្វ ។ លុតលើកព្រះ
បាទ ព្រះបរមនរនាថ ដាក់លើសិរសា ក្រញ្ញក្រោបបង្គំ ប្រណម្យទូលថា
យើងខ្ញុំនេះជា ខ្ញុំព្រះអង្គហោង ។ ព្រះអង្គសព្វញ្ញា យើងទុកជាគ្រូ ជា
ម្ចាស់យើងផង បំរើបំរុង ព្រះអង្គឥតហ្មង សិរសាក៏វង ទទួលអាសា ។
តោះមានសត្រូវ បៀតព្រះដល់ទៅ ប្រមាថពាធា យើងយកខ្លួនប៉ះ គាង
ព្រះពជា កុំឱ្យអាណា ទៅបៀតព្រះអង្គ ។

កាលណោះពោធិសត្វថ្លៃវីរៈសេសសារពេជ្រពង្ស ពន្ធកពុទ្ធបក្រ
វរលក្ខណ៍វរ -ង្សសក្តិសម -ង្គលកបប្រាជ្ញ ។ ព្រះកន្ត្រស្រស់ស្រួល បើក
ព្រះបន្ទូល មធុរថ្លែងថា យក្ខអើយអញអរ អំណរមហិមា អរទឹងវាចា

ព្រះស្តែងស្រដី ។ ដ្បិតអញកំព្រា ព្រាត់ប្រាសភាព មកនៅបុរី ហេម-ពាន្តសោះសូន្យ នឹងប្អូនមួយស្រី សព្វថ្ងៃតែបី- នាក់នឹងអស្សុត ។ បើទៅពល់គ្នា អាណិតមេត្តា អង្គអញស្មោះសរ ចូរទៅនាំផល នូវផលាករ ទៅឲ្យអញបរិភោគកក្កុសព្វថ្ងៃ ។ យក្ខទូលឆ្លើយថ្លាស បពិត្រអម្ចាស់ កុំព្រួយព្រះទ័យ ណានាយើងខ្ញុំ នឹងនាំផលស័យ នូវផលព្រឹក្សព្រៃ ទៅថ្វាយព្រះអង្គ ។ ជាតិជាភោជន៍កស្ត ប្រសិទ្ធរស នូវព្រះណាមស្រង់ ថ្វាយក្សត្រប្រសើរ បំរើព្រះអង្គ លុះយើងខ្ញុំបង់ ជីវិតកល់គ្នា ។ ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ អញអរចិត្តបា មោះព្រះសុរិយន៍ ទន់តាមសន្ធ្យា អង្គអញសូមលា អស់ព្រះស្តែងទៅ ។ កុម្ភណ្ឌថ្វាយករ អញ្ជើញស្តេចចរ ពន្ស្រុតទុំទៅ ឡើងគង់សេះហោះ ផ្លេកផ្លោះសំដៅ ដល់ទីលំនៅ ប្រាសាទសុវណ្ណា ។

ស្តេចដល់ស្រេចស្រាប់ ឲ្យផ្លែក្រចាប់ ផ្លែបទុមា កញ្ចប់ស្លឹកស្រះ ដល់ព្រះប្អូនក្យា នាងទុនទ្បា ទទួលយកទៅ ។ រឹងកយ័រឹងកិត រឹងគន់រឹងគិត ខ្វាចព្រះចមទៅ ថ្លើកត្រូស្រស់ស្រោយ និយាយមកទៅ ឥតឯហ៊ានសៅ អោះមន្ទិលា ។ ធ្វើតប្រណិប័ត្តិ បម្រើមហាក្សត្រ ដូចសព្វទិព្វ ស្តេចប្រាប់កំណាន ខ្ទុនានយក្ស ទាំងប្អូនបានជា បរិចារព្រះអង្គ ។ កាលក្រោយពោធិ វិលមកទន្ទីរ មណ្ឌលគ្រគង់ សន្សំជួបជួន ទាំងប្អូនយក្ខយន៍ ស្តីថាយើងបង់ គិតបំបែកគ្នា ។ ពីរនាក់ចូរទៅ ក្លែងជាមនុស្ស ទៅ បំរើជា ការក្រែងសត្រូវ កន្ទប់ណ្ណា ក្រែងព្រះអង្គភា — ពាធពុំសុខសាន្ត ។ គ្រាន់ថ្មក្យា តបគុណក្សត្រា ដ្បិតស្តេចស្តែងមាន ព្រះ

គេជព្រះគុណ ដូនពន់ប្រមាណ មួយសោតអស់កាលណា រកផ្លែឈើផង ៗ
ថ្វាយសព្វវេលា ប្រណិប័តក្សត្រា កុំឲ្យមានហ្មង យើងទាំងពីរនាក់ នៅ
រក្សាគ្រង ស្រះស្រីទឹងផង ទឹកទំព្យងថ្លា ៗ កាប់ផ្លូឈូកដក ក្រនុឈូកយក
ក្រចាប់ផលា ទៀនទៅថ្វាយថ្វាត់ មហាក្សត្រសព្វគ្រា សព្វទិនទិវា កុំឲ្យ
ខាតខាន ៗ ជាប្រេបយក្ខពីរ ប្រែប្រាណឥន្ទ្រិយ៍ ជាមនុស្សស្មោះស្មាន
ហៀវហោះទៅដល់ មណ្ឌលក្សត្រក្សត្ត ទនួបប្រេញប្រាណ បត់បាទ
បង្គំ ៗ ទើបទូលទៅថា បពិត្រព្រះមហា-រាជរ៍យើងខ្ញុំ ជាយក្ខនៅស្រះ ខ្ញុំ
ព្រះអង្គអ-ម្ចាប់ថ្ងៃឧត្តម ឥស្សរសិរសា ៗ កៀសប្រាណមកនៅ បំរើ
បមរេហ៍ វិត្ថារទ្វេហា ឲ្យនៅកក្តី ស្រះស្រីរង្គថ្លា ដងព្រះគង្គា បេះផ្លែ
បទុម ៗ ដកយកក្រនុ បេះក្រចាប់នៅ មកថ្វាយអង្គអ-ម្ចាស់ថ្ងៃលើស
លើ រីពីរយើងខ្ញុំ នៅអាយបានបំ-រើកាល់វេលា ៗ មួយទឹងទៅរកផ្លែ
ឈើផងមក ថ្វាយមហាក្សត្រជា សព្វថ្ងៃគ្រាន់សោយ កុំឲ្យព្រះបា-រម្ភ៖
អស់អា-ហារហើយព្រួយប្រាណ ៗ ពោធិ៍សត្វឆ្លើយ ថាហៃយក្ខអើយ
អញអរចិត្តណាណា ដឹងគុណអង្គអញ នោះមិញស្មោះស្មាន មកនៅគ្រាន់
បាន ជាគ្នាសោះស្មាត់ ៗ តាំងពីនោះទៅ យក្ខទាំងពីរនៅ គោរពធ្វើ
វត្ត គ្រប់ពេលវេលា ជាអ្នកប្រយ័ត្ន មិនឲ្យមហាក្សត្រ មានហ្មងព្រះទ័យ
ពោធិ៍ធ្វើដ្ឋាន គង់នៅសុខសាន្ត អម្ពិងប៉ីថ្ងៃ ស្តេចទឹងអស្សត្រ គុំបរ
ទៅព្រៃ រីផ្ទះឈើនៃ យក្ខយកមកថ្វាយ ៗ

រីកាលពេលនោះណា ក្សត្រីចន្ទា ពិតពុំសប្បាយ រំជួលក្នុងចិត្ត

ព្រោះផ្សិតឃ្លាតឆ្ងាយ ពុំបានយល់កាយ យល់កក្រុកស្តា ។ ក្សត្រី ទ្រង់គិត ថាឱព្រះមិត្រ ព្រះមហាស្នេហា សមព្រះអង្គនឹង ទន្ទឹង ប្អូនភ្ងា មិនបាត់លង់ជា បីថ្ងៃទៀតហើយ ៗ ពុំឃើញប្អូនទៅ សម ព្រះបមពៅ ជាទុក្ខពុំស្បើយ គួរឲ្យអាណិត ព្រះមិត្រត្រាណត្រើយ សម សោកឥតល្ហើយ ឥតល្ហែព្រះទ័យ ៗ ធ្វើម្ដេចញុំាងបាន ព្រះរៀមក្សត្រ ក្សាន្ត ស្ដេចចេញទៅព្រៃ ខ្ញុំនូវប្អូនទទឹងបាន ទៅថ្កានក្សត្រថ្ងៃ រួមក្សែមូលមៃ ត្រីក្សត្រនោមឆាយ ៗ ខែនេះហេមន្ត ពុំគឺវស្សន្ត រដូវផ្ទៃស្វាយ គួរអញនឹង ធ្វើអំពើឧបាយ ឲ្យក្សត្រពណ្ណរាយ ស្ដេចចេញទៅព្រៃ ៗ ព្រះរៀមបវរ ស្ដេចជ្រាបជាក្រ ហើយព្រះជេស្ឋជ័យ នឹងប្រើយក្ខទៅ ទៅចាំងក្សត្រថ្ងៃ ព្រោះព្រះមានមៃ ត្រីទ្រង់ករុណា ៗ ស្រេចនូវនៃន្ទា នៃព្រះពង្សពោធិ៍ ទើបទូលទៅថា បពិត្រទេសពល ខ្ញុំយល់សប្តិថា បានផ្លែអម្ពា អំពីហេម ពាន្ត ៗ ហាក់ខ្ញុំគោក្តា ពានសេពសា ក្រៃក្រៃប្រមាណ សូមព្រះហរិវង្ស ស្ដេចទ្រង់ក្រេសប្រាណ ទៅរកឲ្យបាន បំពេខ្ញុំម្ចាស់ចង់ ៗ

សម្ដេចនរិន្ទ នរបតិន្ទ្រ អរិយ៍ពុទ្ធពង្ស ស្ដាប់ព្រះប្អូនទូល ទំនួល ហើយទ្រង់ ត្រាស់ទៅកាន់អង្គ អនុជក្សត្រក្សាន្ត ៗ ប្អូនអើយហេមន្ត ពុំគឺវស្សន្ត រដូវក្រែងគ្មាន ចង់គិតចង់ល្បួង បងក្រែងពុំបាន តែព្រះហេម. ពាន្ត ដើមច្រើនក្រាស់ក្រៃ ៗ តែបងពុំហ៊ាន ឆាទាថាបាន ឲ្យប្អូនមាសមៃ ផ្សិតខែពុំត្រូវ រដូវឡើយនៃ កុំប្អូនថ្ងើមថ្ងៃ អាក់អន់ចិន្ត ៗ បងនឹង ទៅរក ឲ្យប្អូនពន្ធុក ក្រែងបុណ្យប្អូនភ្ងា ប្រាកដមិនបាន ដូចក្នុងប្រាថ្នា ត្រាស់ស្រេចប្រើថា ហៃយក្ខរាំងរេ ៗ ផ្សិតប្អូនតោមឆាយ ចិត្តចង់ស៊ី

ស្វាយ ចូរអ្នកប្រាសប្រែ ត្រាច់ទៅបច្ចិមៈ និរតិយេ ទិសទក្ខិណេ
អគ្នេយ៍បូព៌ា ។ អញទៅរកពី បុព្វទិសទី ឦសាណឧត្តរ វៀងរាប
ក្រឡាប់ ពាយព្យបច្ចិមា យក្ខពីក្រោបណា ផ្ទុកផ្ទោះហោះទៅ ។ កាល
ក្រោយក្រុងយក្ស សម្តេចហរិវៈ ផ្តែផ្តាំប្អូនទៅ លីលាលះលាក ចេញ
ចាកលំនៅ បន្ទូលហារហៅ សិទ្ធពអស្សយាន ។ ប្រាយប្រាប់អស្សពង្ស
អំពីចំណង់ ព្រះប្អូនកល្យាណ សេះសាតក្រេញក្រាប ខ្ទាបអង្គប្រាណ
ឲនឲ្យស្តេចឈាន ឡើងគង់បរិបូណ៌ ហោះដោយអាកាស ស្ទុះធ្វាស
ប្រសើរផុតគួ ហេតុដោយជវ័ន សេះពន់ពុំយូរ នាំព្រះភូធរដល់
ហេមពាន្ត ។ ស្តេចកេសព្វជ្រោះ សព្វប្រកលង់លុះ ថៃត្រង់ពុំបាន
ស្តែងស្តេចចូលឈប់ នៅអូប់មួយមាន នៅព្រឹក្សាសាន្ត ទ្រង់ផលបុប្ផា ។
នានាងមាត់អូរ មួយមានទឹកហូរ អំពីបព្វតា ស្តេចចុះស្រប់ស្រង់
លាងអង្គអស្សពាហ៍ ស្រេចមកប៉ុនា ក្តេជាតិមួយដំ ។ សេះគេស៊ីស្មៅ
ជុំរាំពខទៅ ថ្ងៃងទៅឯក-ម្នាក់ពីកេសព្វ ទិសគ្រប់ពិតពុំ យង់យល់
ឡើយលំ. ហៃអង្គអាត្មា ។ ហោះទៅចួបចួន ផងគ្នាជាចួន ឲ្យជួយរកគ្នា
សឹងរកពុំបាន ដូចគ្មានប្រាថ្នា ពីព្រោងស៊ុយោ លុះល្ងាចត្រដាក់ ។

រីនាងចន្ទា កាលៈក្រោយយក្សា ទីងព្រះទ្រង់លក្សណ៍ ចរចេញទៅ
ព្រៃ ក្សត្រីព្រួសក្ត្រា ទៅកាន់សំណាក់ អភ័យកុមារ ។ ចរចូលក្នុងស្តូរ
កុមារត្រែកអរ ថ្នាក់ថ្នមដាយា ផ្តែកផ្តិតមេត្រី ដោយក្តីស្នេហា បន្ទូលស្នូរថា

ហៃប្អូនប្រិមប្រិយ ៗ មានមោះប្អូនគេ ហេតុម្ដេចក៏បាត់ លង់ដល់ថ្ងៃបី

ប្រូងបង់តែងតឹង ទន្ទឹងប្អូនស្រី ព្រះរៀមបក្រី ទៅកាន់យក្សា ៗ ញុាំង

ព្រះបងបាន ត្រឡប់វិលថ្កាន ប្រាសាទសុវណ្ណា ឬយក្សពិឃាដ ដន្ទជាតិ

មរណា ឬបានយក្ខជា បរិពារទៀតគន់ ៗ ក្សត្រីបន្ទូល លុតលើកហត្ថា

ទនអភិវន្ទ ទូលថាបពិត្រ មហាក្សត្រសោភ័ណ ព្រះរៀមវិត្ថិត-ទ្ទឹកលើស

លោកផង ៗ ប្រើព្រះជេស្ឋជ័យ ឲ្យទៅក្សិណក្ស័យ ច្រើនគ្រាច្រើនផង

ថាជាទឹងបាន ដូចក្នុងបំណង ប្រែបានសុត្តផង មកជាបរិពារ ៗ

ប្រើទៅកាន់យក្ខ ដូរជាតិអបល័ក្សណ៍ បិត្តហោរមោហា ស្ថានម្តងនឹងក្ស័យ

ដូចគ្គីប្រាថ្នា ប្រែបានយក្សជា បរិពារពុំក្ស័យ ៗ ឥឡូវយកយក្ខ មកនៅ

ពីរនាក់ បម្រើសព្វថ្ងៃ ព្រះបាទក្ខូធរ ពុំបរទៅព្រៃ ព្រោះយក្ខនោះនៃ រក

ផ្លែឈើថ្វាយ ៗ ខ្ញុំនឹកព្រះរៀម ជះទុក្ខក្រំក្រៀម ក្រាំក្រុកក្នុងកាយ ខ្ញុំក្ខូត

ព្រះអង្គ ថាបង់ធីស្វាយ បូរក្សត្រពណ្ណពយ បរបេញទៅរក ៗ ទៅតាំង

យក្ខពីរ លះលៃងមន្ទីរ ទើបខ្ញុំបានមក យល់ព្រះកក្រ្តថ្ងៃ ស្វាមីពន្ទុក សៀយ

អស់ទុក្ខសោក ពីអង្គឥន្ទ្រិយ៍ ៗ បពិត្រក្សត្រថ្ងៃ យើងនេះសមក្ស័យ

ប្រាកដតាំងទេ្វ រិះរកគល់គិច្ច ដូចម្តេចភូមិ ឲ្យរស់ជីវី ខិក្សនៅសុខ

សាទរ ៗ កុមារឆ្លើយថ្កាន ប្អូនអើយបងមាន ក្ការយន្តស្នាងស្នាត

ពីព្រះបិតា ក្សត្រានរនាថ តែងទិងពិឃាដ ដីរតមនុស្សម្នា ៗ យើង

រៀបទុកក្នុង បន្ទប់តែងស្រេង់ បើមហាក្សត្រា ដល់ហើយព្រះអង្គ គង់ស្រង់

កាលណា បូរនាងធ្វើជា គ្រហែមសំដ ៗ ឲ្យត្រូដល់ផាក់ បងនឹងកន្ត្រាក់

ទម្លាក់បក្រី ត្រូវនឹងលំពែង យន្តស្តែងសម្បើ ក្បៀណក្បែយកុំស្រើ គន់
គិតភ័យា ៗ ពីពង្សទ្រង់គិត ព្រមព្រះគំនិត ស្រេចហើយយកក្តារ មក
រៀបទុកក្នុង ទីស្រង់ក្បត្រា សឹកខ្សែពានណា នាំទៅក្នុងសួរ ៗ ស្រេច
នាងលាទៅ គប់ចាំព្រះនៅ សីហៈបញ្ចុរន្ត រំពោធិសត្វ បុរសឲ្យគង់
ស្តេចផ្ទុំក្រោមម-ណ្ឌលម្លប់ព្រឹក្សា ៗ

សុរ្យសាយណ្ហ ទោរទន់ទាបទេរ ទៀតទើបព្រះមហា បុរសតើន
ទ្រង់ ស្រប់ស្រង់គន្ធា ឡើងគង់អស្សពាហ៍ ហៀវហោះត្រេកត្រាប់ ៗ
ដោយដងព្រឹក្សា យោនយានសាខា លតាលូតលេច លំទោនទន់ទន់
ល្ហាសល្ហន់ស្រស់ស្រេច អាស្ចូរត្រះស្តេច រកផលអម្ពា ៗ ទតយល់
ដើមស្វាយ មួយមែកត្រសាយ មែនមានផលា មួយជាប់នាទង
អង្គ្រង់ធ្វើជា សម្បកពាសពារ ដិតជុំពៈក្រៅ ៗ ហេតុបុណ្យមានផ្លែក
មួយចាំនៅមែក បូលហើយដូចនៅ ចិកសម្បកនោះ ស្តេចឆ្ពោះទតទៅ
យល់ផាក់បមទៅ បន្ទូលថាបង ៗ បង់អើយមើលផ្លែក នោះទីងចិកហែក
សប្បុកអង្គ្រង បោតុនេះប្អូនយល់ ប្អូលទូលគន្ធង បើឆ្ពោះចូរបង នាំ
ប្អូនចូលទៅ ៗ ព្រែងអង្គ្រងពុំ ជាប់ខ្ទួស្វាយពុំ វាំងខ្ពង់នោះនៅ សេះ
ស្តាប់នុគ្គារ ក្បត្រាចមទៅ ហិចហោះសំដៅ ចរចូលទៅជិត ៗ ផ្លែក
យល់ចមទៅ គិតភ័យហើរទៅ ព្រះបាទទ្រង់រិទ្ធិ ហែកសម្បកអ-ង្គ្រង
ទ្រង់ពិនិត្យ យល់ផ្លែស្វាយពិត អនេកឧបមា ៗ បេះបានកាលណា
ទ្រង់ត្រឡប់ឆ្ពោះ ទៅកាន់គាព ដល់ស្រេចស្តេចទ្រង់ ឲ្យអង្គអនុជា អនុជ

វន្ទា ទទួលទុកនៅ ៗ អញ្ជើញព្រះអង្គ ឲ្យចរចូលស្រង់ កេះកាយ
ចំពោះ ធ្វើស្មោះស្មានត្រង់ នឹងអង្គចមលោ ស្ដេចចរចូលទៅ នឹងស្រង់
គង្គា ៗ ស្ដេចយល់ក្ដារថ្មក ក្ដារនេះចំឡែក បន្ទូលសួរថា ហៃប្អូនពន្ទក
បានមកពីណា នាងក្រាបវន្ទា ទូលស្នងព្រះអង្គ ៗ ក្ដារនេះស្អាង
ស្អាត នៅក្នុងប្រាសាទ ក្សត្រាទ្រើសទ្រង់ សម្រាប់ទុកជា ក្រឡាណាំ
ស្រង់ ខ្ញុំថ្វាយព្រះអង្គ ជម្រះកាយា ៗ ព្រះស្រីសារពេជ្ញ គង់បរិបូណ៌
ស្រេច ក្សិណនាងធ្វើជា គ្រហែមបន្ទី អភ័យកុមារ ព្រួញជៀងជាក់ជា
បន្ទីក្សត្រ ទាញខ្សែកន្ត្រាក់ កន្ទុះយន្តធ្លាក់ ព្រះបាទចក្រី ទេព
ដែលរក្សា ក្សត្រាធិបតី ផាត់លំពែងខ្ចី ពុំត្រូវព្រះអង្គ ៗ ព្រះអង្គនីរ
ពេក នីរចិត្តក្រេវក្រោធ លីលាឡើងគង់ យកទឹកលុះលាង សារពាង្គ
ព្រះអង្គ ព្រះក្សត្រត្រាស់ទ្រង់ មានមធុរថា ៗ

ឱអញឥតគ្គង ឥតទោសអ្វីផង នឹងអ្នកឯណា មោះមកហ៊ានធ្វើ
អំពើមាយា ឲ្យអញមរណា តើព្រាំងទោសអ្វី ៗ នាងយល់ក្សត្រថ្លៃ
ពុំបានក្សិណក្ស័យ សែងព្រះភារមី ញ័រអង្គរន្ធត់ ស្ងួនស្លុតស្មារតី
រត់រះរឹងខ្ចី ចូលក្នុងប្រាសាទ ៗ សំងំពួនព័ន្ធ ញ័រដួចក្ងួនសត្វ ខ្លាច
ក្ស័យជន្មជាតិ ក្សិណយក្សពីរដល់ អង្គព្រះភូវនាថ ក្រួញក្រាបក្រោមបា-
ទាទើបទូលថា ៗ បពិត្រក្សត្រក្សាន្ត នរណាអាចហ៊ាន ប្រមាទ
ក្សត្រា យើងខ្ញុំសូមរក ចាប់យកបច្ចា- មិត្រមកថ្វាយមហា- ក្សត្រ
ថ្លៃឲ្យបាន ៗ ស្រេចម្នាក់ហោះផ្ដែក- ដីទៅដោយតេជ ដល់បាត
ផាលបាន ម្នាក់ហោះអាកាស វេហាស៍ហៅហាន ពុំយល់វិលក្លាន

ពូជពង្សពុទ្ធទៅ ៗ ចរចូលក្នុងឋាន យង់យល់វេទ្យមាន យក្ខយង់ យោរយៅ ក្រុងជាក្រមោច តូចៗទៀតៗ ក៏តាមវិជ្ជាទៅ លុះចូលក្នុង ស្គរ ៗ យក្ខពីរយល់ជាក់ ប្រែប្រែណាជាយក្ខ ប្រទប់ទះទរ គ្រវីគ្រោធ ធារធាក់ បែកបាក់ល្អិតស្គរ ប្រឹងប្រាណប្រួតប្រែ. ទង់ទះតាញទៅ ៗ ផលហើយយក្ខខ្ចូល តង្សពុទ្ធង្កូល បពិត្រចមបោ ទៅនេះឯងជា ខោបារយោរយៅ ពួនពីងទិត្យនៅ នាក្នុងស្គរមាស ៗ លើប្រាង្គប្រា- សាទ ប្រសើរស្អាងស្អាត ស្រុទ្ធសាតខ្ចុះខ្ចាម ខ្ញុំសុំពិឃាដ ផន្ទជាតវិនាស លះលែងប្រាណប្រាស ប្រាកដផ្ទះ ៗ តោពិសក្តា ហេតុព្រះអង្គជា ពន្ធកសត្តញ ផ្ទះពោពផ ឯងគាបជាត្រូ ព្រះអង្គឥស្សូរ ឃាត់ទៅយក្ខថា ៗ កើយចុះចូរបេ គាស្សូរគោទៅ កុំឲ្យមរណា យក្ខស្ដាប់ហើយគិត ក្នុង ចិត្តថា ចុះប្តូរ ចុកពាំ នេះធ្វើបាន ៗ ពីបម្រាប់ខ្ញុំ មោះប្តូរមកស្ទួន ឯមនុស្សយោរយៅ គ្នាស្ដាយស៊ីសស្ដាយ ពីនាយយើងទៅ បើសម្លាប់ទៅ នោះយល់ជាជា ៗ អ្នកនេះហៅគ្នា ប្រសើរមហាគាប់ មិនឲ្យមរណា ស្តេចស្តាប់ប្រប្រឹម ញញឹមឆ្ងើយថា ហៃព្រះយក្សា ស្តាប់គញឆ្ងើយ រីង ៗ ធម្មតាអ្នកប្រាជ្ញ ប្រាជ្ញប្រុះឯងគាប ពាក្យផ្ដែលខឹង តោះខុស ប៉ុន្មាន ចាប្រាខរពីង អាចគតក៏ហាង កំហុសនោះបាន ៗ ដូចព្រះ កាយជាត់ ជ្រុំក្ដូវាត់ បៀសបេញ ទេងខាន រឹងតាសោ មោហោសា- មាន្យ បើឲ្យមិនបាន ឈ្មះចិត្តខន្តី ៗ នោះលោកពុំហៅ អ្នកប្រាជ្ញជ្រះ ជ្រៅ តាស្សូវកុំបី ឲ្យបង់ផន្ទជាតិ ចុះអ្នកប្រណី គោះទាំងខន្តី ជាតិ

ជាប្រធាន ៗ បើមានព្យ៉ាសឹក មកមិនភ្លុកភ្លឹក ទើបឃើញទះហាន បើ
កាន់អំណត់ អាចអត់នោះបាន ឃើញកាលគ្រាមាន សេចក្តីក្រោធ ៗ
បើឃើញប្រាជ្ញប្រាយ ឃើញកាលដោះស្រាយ អស់អាថ៌ប្រស្នា កម្រ
ក្រក្រៃ ឃើញក្តីមេត្តា យន់យល់កាលគ្រា មានទោសព្រោសប្រាណ ៗ
បើឃើញដឹងគុណ អ្នកមានគុណធ្ងន់ ឃើញកាលគេមាន ទោសតាំង
ទោសស្មើ ថាបើមិនមាន ល្មះហើយនឹងបាន ឃើញកាលឯណា ៗ

យក្ខពីព្រញប្រាណ ទទួលទូន្មាន ទើបមហាក្សត្រា ប្រែព្រះភក្ត្រថ្ងៃ
ជាហៃកុមារ គោទុនាថា មាតាបិតាពេ ៗ គោទុនាមអ្នក ចូរថ្វៃដៀងជាក់
ដោយសច្ចៈតោ គិទ្ធកិទ្ធី នាគីនាគោ យក្ខីយក្ខោ ទេវីទេវោ ៗ
មនុស្សាមនុស្សោ គិទ្ឋងគោ ហេតុម្តេចបានជា អ្នកនៅហិនហោច
ត្រមោចកំព្រា ឥតញាតិកា ល់ាផងពារពង្ស ៗ ចូរហៅសំដែង
ដំណើរទៅឯង ដោយពាក្យពិតត្រង់ អញពុំយកទោស សន្តោសឲ្យគង់
ជីវិតអញចង់ ដឹងដើមអតីតា ៗ

កុមារក្រញក្រាប សំពោស្រពាប ស្រពោនភក្ត្រា សញ្ជឹងសញ្ជប់
ផ្ទប់ព្រះសិរសា លើកព្រះហត្ថា ញាប់ញ័របង្គំ ៗ ទើបទូលទៅថា
បពិត្រព្រះមហា-បុរសខ្ញុំ រួចរស់ជីវិត ព្រោះផ្សិតអង្គម្ចាស់ ព្រោសខ្ញុំសុំ
ជាខ្ញុំបាទា ៗ ទូលស្រេចស៊ុះសព្វ ដំណើរគ្រាន់គ្រប់ ដូចប្រាប់ពីតា
ពីសត្វឥន្ទ្រីយ៍ ឈ្មោលញីមោហា មកផ្ទាញខាត ស្ងប់ស្ងាត់ស្ងួនឈឹង ៗ

ពោធិ៍ប្រសើរ ជ្រាបគ្រប់ដំណើរ បន្ទូលស្បូវនឹង ទៅអើយគិទិត ទៅ
គិតរំពឹង ធ្វើកល់កម្មហ៊ឹង ពិឃាដអញទៅ ៗ ញាំងអញមានគ្គង មាន

ទោសភ្លើង នៃទីងខ្លួនទៅ ឬទៅគិតព្យាន បង់បានប្អូនទៅ អង្គអញឬទៅ
បានរួមគ្នាហើយ ៗ

កុមារទូលថា បពិត្រព្រះមហា-ក្សត្រាត្រាណត្រើយ អញខ្ញុំជួបជាតិ ទីងឈាក់អ៊ីឡើយ ពិតជួញ្ញោះហើយ តាមតែមេត្តា ៗ ក្រែងនាងមានគតិ លុះក្តូរទ័រ ដល់មហាក្សត្រា ក្រែងព្រះពុំប្រោស អត់ទោសករុណា ហេតុនោះបានជា ខ្ញុំគិតពិឃាដ ៗ ឲ្យព្រះអង្គទៅ កាន់ស្ថាន្ថានៅ ទីងយក្សាសាទ គិតឲ្យក្សត្រថ្ងៃ ក្សណក្សយដន្ទជាតិ យល់ក្សត្រ នរនាថ ពុំក្សយជន្មា ៗ បានជាផ្ទើយន្ត ទីងផ្តាច់ជីពជន្ម ព្រះបាទក្សត្រា អញខ្ញុំខូចខុស ជាមនុស្សពាលា ពុំចេះព្រះមហា ក្សត្រាប្រាណ ៗ

ស្តេចបើកទន្ធ្ការ ហៃកាដកុមារ រីឯប្អូនស្រី អង្គអញឲ្យបា យកជា មហេសី តែអញស្រដី ប្រដៅទៅសិន ៗ ទៅឯងបោចិត្ត ទោសទុច្ចរិត ទីងនាំអង្គឥ. ទ្រីយ៍ត្រូតអាចឲ្យ សេកសោយចក្ខុន តីផ្ទាក់តីបឹន ក្រែក្រ រួចផ្ទាយ ៗ ហេតុដោយអំពើ អំពើបង្ហើរ អធម្មកម្មកាយ បំបែកបំបាក់ កំចាត់កំចាយ កំបោកបង់កាយ បង់ភក់អ្នកផង ៗ បំបង់បំបាត់ ជីវិត សព្វសត្វ ហេតុពាក់ព័ន ចង់ឃ្លាបង់ឃ្លាត អស់ញាតិៈឆាឆង ព្រាត់ប្រាស់ ប្អូនបង មាតាបិតា ៗ ចូរប្រែប្រួលចិត្ត កាន់ដោយសុចរិត ធម៌ព្រះពុទ្ធា រក្សាសីលប្រាំ ចង់ចាំដាក់ជា ពិនាក់អាត្មា ទៅជាទនិញ្ញាន ៗ ស្រេចព្រះ បណ្តាំ ខ្ញុំសីលចាំងប្រាំ តាមធម៌បុរាណ កុមារបង្គំ ប្រណម្យស្មានាន សីលចាំងប្រាំបាន ក្ខួចកត់ចាំនៅ ៗ

ពោធិ៍សោភ័ណ ស្តេចទ្រង់ចំអន់ នៃព្រះប្អូនពៅ ត្រាស់ទ្រង់ព្រះស្រួល បន្ទូលហៅហៅ ថានៃហប្អូនពៅ ពាលពេញស្នេហា ៗ បងអកទុកស្ងួន ស្មើចិត្តស្មើខ្លួន ស្មើអង្គរៀមក៏ ស្មានប្អូនស្ងួនគ្រង់ ពីកន្ទុក មិនដឹងឡើយថា ប្អូនគ្រង់តែក្រៅ ៗ ថ្ងៃនេះទើបដឹង ជាប្អូនព្រលឹង បែងបេះជ្រះជ្រៅ កន្ទៀបលាក់កាយ មកកាយប្អូនពៅ បងនឹងឲ្យទៅ មួលស្វាមីមេ ៗ បើបងមាសវិញ បងធ្វើបេះមិញ បងពុំរត់ទេ បងនៅប្រែប្រឹង ពាំងទឹងគេ តាំងតភាល់តែ ក្បែណក្បែរផងគ្នា ៗ ស្តែងស្តេចបន្ទូល ត្រេកទ្រង់ព្រះស្រួល នឹងអង្គអនុជា មច្ចុរក្សាគក្អាយ កេះកាយបពោ ហេតុព្រះទ័យជា ពន្លកពុទ្ធពង្ស ៗ

នាងព្រះស្តេចថ្លែង នុនអៀនអង្គឯង ពុំអាចជំអង់ ដំអឹងអាថា ក្សត្រាវង្ស ចិន្តាពុំចង់ យល់ព្រះកត្ត្រា ៗ យាងទៅតាំងតាល់ នុនអង្គគង់គាល់ បង្គំពថា ពុំទៅទៀបនៃ អភ័យកុមារ ស្តេចស្រួល ត្រាស់ថា នៃហប្អូនធោមធាយ ៗ កុំធ្វើមិនត្រឹម ទិតមកឲ្យទឹម ជិតមកនៅអាយ បងនឹងឲ្យជ័យ ប្រពៃពណ្ណរាយ ឲ្យសុខសប្បាយ មូលមួយផងគ្នា ៗ នាងទិតសន្ទឹម ចូលទៅទន្ទឹម នឹងអង្គកុមារ ពីរពង្សបវរ លើគករអភិរ័ក្ខ ក្រាបទៀបបាទា ព្រះពង្សពោធិ ៗ ស្តេចទ្រង់ញញឹម ប៉ប្រែប៉ប្រឹម ទើបព្រះភូមិ បំពេនព្រះពរ បវរវុឌ្ឍិ អនុជតាំងពី ទទួលព្រះពរ ៗ ពីថ្ងៃនោះទៅ បីអង្គនិត្យនៅ ជា សុខសោះសារ តាំងពីរពង្សក្សត្រ ប្រណិប័ត្តភូធរ ស្មោះស្មើព្រះវរ-មាតាបិតា ៗ

លង់លុះរាត្រី ព្រះពន្ស្រពោធី ចូលទីសេយ្យា សេយ្យាសន៍
ឯកអង្គ នៅក្នុងប្រាង្គប្រា-សាទសិរីវចនា ប្រសើរសក្តិ៍សម ៗ ភ្នក
ទឹកមាតា ខ្សឹកខ្សួលទុក ទារ:ក្រៀមក្រំ ទុះទព្រះមេ តាំងតែកូនក-
ព្រាព្រាត់ចាកចំ បែងបាត់មុខមក ៗ សមព្រះមេមាន តែទុក្ខឥត
ស្រាន្ត ឥតស្រាកវិយោគ សង្រេងសង្រៃ កន្ទេងរិះរក កូនបាត់សំ
សោក ដល់ក្សយជន្មា ៗ ទុះទព្រះគុណ ប្រសើរមហាធ្ងន់ ឥត
ឧបមា អ្នកនៅផ្ទើវត្ត ប្រណិប័ត្តយក្សា ញាំងត្រូវចិត្តា ប្តូមួយពុំ
ត្រូវ ៗ ប្តូយក្ខយកជា អាហារគោត្តា ប្តូព្រះមេនៅ ជាសុខសប្បាយ
លោះលាយពុំស្ងួ គន់គិតកូនកូវ យក្ខយង់មេត្តា ៗ ទេះហេតុហៅ
គៀរ ពុំទិក្សពិទៀរ នៃអង្គអាត្មា អំពីបុព្វជាតិ បង់ឃ្លាតបង់ឃ្លា
ឡេះយើងព្រាត់គ្នា ពុំបានមួយមូល ៗ ពីដើមអញគ្មាន សេនាធា-
ជាន ត្រកាលត្រកូល ឥឡូវអញបាន ទាហានមិត្តមូល គិតគួរ
លើកចូល ទៅកាន់នគរ ៗ សម្លាប់នន្ទី យក្ខយង់រិទ្ធី នោះឯងឡេ
មរណ៍ រួចហើយសមអញ យកពង្ស្រសោយបរ- បូណ៌បានពស្ត្រប្រ-
ជាជនជួបជុំ ៗ ស្តេចរិះរង់សួរ សែនសាយបរិបូណ៌- មីមិញបួនចំ
ពោះតើបពារពី- ណារិសេសស- ម្តេចដឹងដោយជំ- ណើរនៃយោគ
យាម ៗ ចរបួលស្រប់ស្រង់ ជម្រះអស់អង្គ ពិតពីព្រហ៊ាម ប្រដាប់
អង្គក្សត្រ មកុដរត្នអាភម ហូរក្សរន្ទាម សូរងឹកងឹក ៗ ទើបព្រះកូមី
ត្រាស់កាន់ពាជី ថាចូរបង់ចរ ទៅទិសឯលិច ហៅស្តេចពានរ ហើយ

ទៅទត្តរ ហៅស្តេចខ្លាឃ្មុំ ។ ឲ្យប្រមូលពល បរិវារក្រៃលៃ ឲ្យជួប ឲ្យជុំ ឲ្យចូលមកកាន់ ហេមន្តរដ្ឋម្យ យើងនឹងជំនុំ រិះគិតរាជការ ។ សេះក្រាបណាទៅ ប្រាណប្រាប់ហាវហៅ ស្តេចស្វាស្តេចខ្លា សឹងអរ ស្រស់ស្រួល ទទួលអាជ្ញា បបួលយោធា ដោយខ្ជួនស្រពន់ ។ កាល ក្រោយពាជី ទៅទើបពោធី ត្រាស់ប្រើកុម្ភណ្ឌ ទាំងពីរនាក់នោះ ឲ្យ ហោះទៅកាន់ ទាំងពីរកុម្ភណ្ឌ ចូលមកបង្គំ ។ រីឯស្តេចស្វា នូវអង្គ ស្តេចខ្លា បបួលពលជុំ ស្រេចស្រាប់ស្រើបស្រួល ចរចូលបង្គំ ។ ព្រះបាទព្រះបរម ពោធិសម្ភារ ។ ក្តើងព្រះកេត្តិ៍ស្តែង ដូចព្រះចន្ទ្រ ថែង រស្មីពិស្តារ គង់នៅកណ្តាល ពលពាលបរិពារ ដូចដាវតារក[១] បរិវារព្រះចន្ទ្រ ។ អនុជតាំងពីរ ទូនអង្គព្រះសិរ-សាស្វស្តិ៍អភិវន្ទ ស្តេចបើកទ្វារ ពិស្តារស្តែងស្បាន់ ទ្រង់ត្រាស់ទៅកាន់ ជំនុំយោធា ។

អង្គអញបីបំ· ណាងទឹងនាំ នៃអ្នកយាត្រា ទៅពាកណ៌សី បូរី. រដ្ឋ ប្រាសប្រាប់យក្សា ឈ្មោះនន្ទយក្ខ ។ គិតគិតកំណាច កំណើត កៀចកាច ចិត្តពាវអេចលក្ខណ៍ ទ្រុស្តព្រើសពិឃាដ ព្រះបាទទ្រង់ លក្ខណ៍ ព្រះនាមនៃអ្នក កាសិកមហាក្សត្រ ។

កាលណោះព្រះបាទ ចេញទៅប្រពាត ព្រះព្រឹក្សព្រៃស្វាត់ ព្រមអស់សេនា យោធាពលពទ្ធ ក្លាក្លៀវក្លួបក្លាត់ អស់អម្រឹគព្រៃ ។ យក្ខយន្តក្លាយក្លែង ក្លាយក្លាប់អង្គឯង ជាប្រើសមាសវៃ ស្តេចយល់ គួរគាប់ ចូលចាប់ព្រះទ័យ ទៀតគិរិមៈនាមយ័យ ដាយដេញអម្រឹគ ។

(១) ដាវ: ពាក្យសៀម ប្រែថា ផ្កាយ ។ តារក: ពាក្យបាលី ឬ សំស្ក្រឹត ប្រែថា ផ្កាយដែរ ។

ព្រាកព្រាត់ប្រាសពល ដល់ថ្ងៃមណ្ឌល នៃខន្ធយក្សា ប្រែចាប់
ពិហេដ ព្រះបាទបិតា ក្សិណក្ស័យជន្មា ជាចំណីយក្ខ ៗ រួបរៀប
ស៊ីសេះ ៗ មានតម្រិះ តម្រូវចិត្តជាក់ បញ្ចុកបញ្ឆោត បំពោតថាអ្នក
យកខ្ញុំជាកត្ត ផ្អែតតែមួយថ្ងៃ ៗ បើអ្នកចូលចិត្ត តាមខ្ញុំគន់គិត អ្នក
បានផ្អែតផ្អៃ ស៊ីសឹងអាហារ ពិសាឆ្ងាញ់ក្រៃ អ្នកផ្អែតពាល់ក្ស័យ ជី
វិតមរណា ៗ កូនដាពមទៅ ទៀងគន់ខ្ញុំទៅ គ្រប់គ្រងសីមា គ្រប់
មុខមន្ត្រី គ្រង់ស្រីស្រីង្ការ គ្រងនាងវិមលា ជាពជទេពី ៗ ហេតុ
ដំណើរនេះ យក្ខតាមពាក្យសេះ ៗ រួបរឹរ អង្គអសុរកាយ កូនក្លាយ
ឥន្ទ្រីយ៍ ដូចព្រះវរបី តារជ្ឈាជា ៗ គ្រប់គ្រងបុរី គ្រងមុខមន្ត្រី
គ្រងស្នំស្នហា ជាសុខឥតហ្មង គ្រប់គ្រងមាតា អង្គអញនេះជា ទេពី
ស្នេហ៍ស្និទ្ធ ៗ ហើយយក្ខទ្រង់ត្រិះ ឲ្យជាកត្តិសេះ ប្រាំពីរខែពិត
ហេតុបុណ្យពុំក្ស័យ យក្សក័យព្រោះដៀត សេះដឹងគំនិត ក្រែងប្រាប់
អ្នកផង ៗ ហេតុតែបុណ្យផល អង្គអញទៅយល់ ខ្សៀវខ្សឹកប្រាប់
ប្រង អំពីអំពើ ដំណើរទំនង ដំណាលដើមទង អញបានដឹងជាក់ ៗ
សេះឲ្យអញទៅ បញ្ឆោតយក្ខខ្លៅ សុំសេះពីយក្ខ កាលដើមព្រះបាទ
នរនាថទ្រង់សក្តិ ព្រះទ័យស្មោះស្ម័គ្រ ថាឲ្យអស្សយាន ៗ នេះគេប
ព្រះអង្គ បន្ទូលពុំគង់ ពាក្យសត្យប្រតិញ្ញាណ ប្រែយកអស្សពាជី
ដាក់ទ្រង់ពុំបាន ព្រោះព្រះរាជទាន ដូចពាក្យប្ដេជ្ញា ៗ យក្ខស្មាន
ពាក្យពិត ពាក្យពោលសុចរិត យក្ខឲ្យអស្សពាហ៍ ទាំរត់ចេញចាក
លះលាកនគរ ទាំងព្រះមាតា ពុំដឹងសេចក្តី ៗ មកប្រាំខែស្រាន់

យក្សតាមមកទាន់ យក្សកាត់សិរសេ ស៊ីឬមិនដឹង អញនឹងប្អូនស្រី រួច
រត់ឃ្លាតឃ្លី ចូលក្នុងទន្លេជ្រៅ ។ ទេព្ដាបាំងបិទ បាំងកាយអញជិត
យក្សយំចចៃ្រ រកពុំឃល់ខ្លួល វិលវល់ក្រុងក្រៃ អញយល់សេះក្បៀ
អញស្ងួនឲ្យស្មាគើ ។ ព្រះឥន្ទ្រមកប្រោស អង្គអញរួចរស់ ឲ្យអញប្អូន
ស្រី ដើរកេត្រអាល បានក្បាលពជសីហ៍ ស្រេចឥន្ទ្រធិបតី ភ្លាម
នឹងអស្ប្រាហ៍ ។ ពាជីរួចរស់ ជីវិតស្មានស្មោះ បេះបោះរំហាស់
នាំអញមកកាន់ ហេមទ្ទនគព អង្គអញគិតថា នឹងលើកទ័ពទៅ ។
ពិឃាដនៃនន្ទី- យក្សយំទូជិន យកស្រុកនិគ្យនៅ ព្រះស្ដែងនឹងគិត
គំនិតម្ដេចចៅ ត្រើសព្រមតាមទៅ ឬពុំទៅទេ ។

ទាំងប្អូនយក្សា ស្ដេចស្វាស្ដេចខ្លា ទូទាំងពលរេហ៍ ឮព្រះឧង្ការ
ថ្ងៃថ្វាសឹងតែ លើកហត្ថដល់ឯ មណ្ឌលសិរសា ។ ទូលជាបពិត្រ
ព្រះភាទទ្រង់រឹទ្ធិ ជាម្ចាស់លោកា ប្រសើរឆ្នុះថ្វាស សិល្បសាស្ត្រសត្វា
ប្រាជ្ញប្រុសពិស្ដារ ធីការថ្កើងថ្កាន ។ យើងខ្ញុំសឹងតាម ទៅធ្វើសង្គ្រាម
សង្គុណក្សត្រក្សាន្ត វិនទ្ទីយក្ស សិទ្ធសក្ដិហៅហាន យើងខ្ញុំគ្រប់
ប្រាណ ធានាអាសា ។ មិនឲ្យព្រួយព្រះ អង្គអាចពារពះ យុទ្ធ-
យក្សមោហា សាមាឲ្យសើរើ ពុះស៊ីស្គ្រូវក្ដា ទីអាប់នុនអា- នុភាព
នុពល ។ បើដល់ក្រៃក្រុង សូមព្រះអង្គគង់ ជាសុខក្សេមស្កល់
យើងយុទ្ធយកយក្ស អបល័ក្ខណ៍គំហល់ មិនឲ្យជិតដល់ មកព្រះអង្គា ។
ស្ដែងស្ដេចជំនុំ ពលពាលមកជុំ ព្រមព្រះអាជ្ញា អាងអ្នកស្រុះស្រួល
ទទួលអាសា ស្ដេចគុំយោធា អំលុងបីថ្ងៃ ។ ស្រេចរៀបប្រាក់មាស

កែវកងធ្នុះធ្លាស សំពត់អាវស្បៃ សំពាយ ៗ រៀបពយច្រើនក្រៃ ពង
ទ្រព្យព្រះថ្លៃ ព្រះមហាក្សត្រា ៗ យកទៅទីងឲ្យ ទានមនុស្សផង
ដោយ ដែនជនមាតា ទីងទុកនៅអាយ ខូបខាយអាសា ឥតកើ្តឥត
ការ ឥតគេគក្ដី ៗ ស្ដេចឲ្យព្រទាក់ សំពាយមួយម្នាក់ គ្រប់ខ្លួន
សេទី ហើយឲ្យអភ័យ ព្រះថ្លៃបក្រី រួសពនឃាតខ្ញុំ គង់ស្ដេចពានរ ៗ
បេញជាស្រួបស្រប នានាំសែ្ដងស្ដេច ទើបព្រះកូជរ ឲ្យអង្គបន្ទា
អនុជបវរ លីលាបេញចរ គង់ស្ដេចខ្លាឃ្មុំ ៗ បរបេញតានតាប់
ណាស់ណាន់បន្ទាប់ ទៀតទើបព្រះបរម ពោធិសត្ដា ថ្លៃថ្លាឧត្ដម ស្ដេច
គង់សេះសម ក្រោយក្រុងយោធា ៗ កុម្ភណ្ឌទាំងបួន សឹងមុតសឹង
មួន សឹងម៉ាំសឹងមារ សឹងមានដរយោ ពាលោក្លៀវក្លា កាងកាន់ក្រពា
ដែកដោយដៃដ៏រ ៗ ការកាល់ឯក្រោយ បែកបែរខាងម្ដាយ ហែ
ក្សត្រប្រសើរ ទោះដេកទោះដាក់ តំណាក់តំណើរ យក្ខតំណែនធ្វើ
ពេងកជតន្ទា ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ២៩

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាស បើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

ឯអួនថាំងខ្ញាល់ហើយក៏មើលដឹងសេចក្ដីសព្វគ្រប់ ក៏ប្រឡោតទឹងខ្លាំងណាស់ គិតនឹងឲ្យសម្លាប់ហងតែចេញ ។ គួតៅក៏ចូលទៅឃាំងអួនថាំងថា គ្រានេះកងទ័ពលើកចូលដែន ដែលចូលមកជិតណាស់ហើយ ហងតែក៏នៅក្នុងកណ្ដាប់ដៃយើង ដែលលោកនឹងបង្ខំសម្លាប់ចេញនោះមិនគួរទេ សូមឲ្យលោកបង្អង់ឈប់សិនចុះ ត្រូវធ្វើជាមិនដឹងដល់គំនិតអួនសុង យើងសហាររិះគិត ធ្វើការសង្គ្រាមច្បាំងនឹងចូចូឲ្យសំរេចសិន រួចសឹមគិតបាយយកស្រុកគីជីវ ឲ្យបានដោយងាយ អួនថាំងក៏យល់ឃើញត្រូវផង ទើបលើកកងទ័ពទៅដំបន់លីយ៉ង ។

ចូចូបានដឹងដំណឹងដូច្នោះ ក៏លើកកងទ័ពចូលទៅតាំងបន្ទាយជាប់គ្នានឹងបន្ទាយអួនថាំង ៗ ក៏ចាត់តាំងជៀវ ឲ្យឃុំនាំទាហានលើកចេញទៅច្បាំងនឹងចូចូ ៗ ក៏នាំទាហានទៅបញ្ឈរសេះពីមុខបន្ទាយ ហើយឲ្យស៊ីហុងលើក

ទាហានចេញតយុទ្ធនឹងអាំងជៀវបាន ៥ កង ស៊ីហ្វានយកខ្លួនបាក់ត្រូវអាំងជៀវធ្លាក់ពីលើសេះស្លាប់ ។

ចូឆូឃើញបានចំណាប់ ក៏បរពលចូលប្រកាប់ទាហានអួនថាំស្លាប់អស់ជាច្រើន លុះពេលជិតយប់ ចូឆូក៏នាំទាហានចូលបន្ទាយ អួនថាំក៏ឲ្យទាហានឡើងរក្សាសើនជាមាំមួន ហើយធ្វើសំបុត្រឲ្យបរិសេះទៅសូមកងទ័ពអួនស៊ុនលើកមកជួយ ។

អួនស៊ុនឃើញសំបុត្រដូច្នេះ ក៏ប្រឹក្សាទីងសឹមឆៅយថា ត្រូវតែកេណ្ឌទាហាន ៥ ពាន់លើកទៅជួយអួនថាំ ។ បរិសេះចូឆូដឹង ក៏នាំសេចក្ដីនោះទៅជំរាបចូឆូថា ឥឡូវ អួនស៊ុន ឲ្យទាហានលើកមកជួយអួនថាំ ។ ចូឆូដឹងដូច្នោះក៏បាតក្រើលីទៀន, ង៉កជិន ឲ្យលើកទាហានទៅស្កាត់ពាយទាហានអួនស៊ុន ។ លីទៀន ង៉កជិន ក៏លើកទាហានស្រូតទៅនៅចាំកណ្ដាលផ្លូវ បង្ហាប់ទាហានទាំង ៥ ពាន់នោះស្លាប់អស់ ឥតសេសសល់ឡើយ ។

អួនថាំដឹងថាអួនស៊ុនឲ្យទាហាន ៥ ពាន់មកជួយ ហើយទាហានចូឆូលើកទៅស្កាត់ពាយសម្លាប់អស់ដូច្នោះ ក៏ខឹងណាស់ថា អួនស៊ុនមិនលើកមកជួយដោយខ្លួនឯង ដូចពាក្យនិយាយ ក៏ដេរហង់គីជាពាក្យទ្រគោះអសុរោះផ្សេងៗ ។ ហង់គីក៏ថា លោកកុំអាលប្រកាន់សិន ខ្ញុំបាទនឹងឲ្យមានសំបុត្រទៅដល់អួនស៊ុនទៀត ឲ្យលើកកងទ័ពចេញមកខ្លួនឯងឲ្យបាន ហើយហង់គីក៏ធ្វើសំបុត្រសេចក្ដីថា ឲ្យអួនស៊ុនលើកកងទ័ពទៅ

ជួយ លុះធ្វើសំបុត្រហើយ ក៏ជូនទៅអ្នកចាំៗក៏ប្រើបំរើសេះទៅដល់អ្នកសុនៗ

ឯអ្នកសុនឃើញសំបុត្រហើយ ទើបប្រឹក្សានឹងសឹមផោយថា ដែលហានគិតនឹងឲ្យយើងលើកទ័ពទៅជួយអ្នកចាំនោះ អ្នកនឹងយល់ឃើញប្រការម្តេច? សឹមផោយឆ្លើយថា ការដែលលោកបានធ្វើជាចៅហ្វាយស្រុកនេះ គួរតែកំមានសតិបញ្ញា គន់គិតដល់គំនិតយើង ប្រហែលជាគួរតែគិតគ្នានឹងអ្នកចាំ ធ្វើកលឧបាយមកសុំហានគី ទៅជួយគិតការសង្គ្រាម ហើយនឹងលើកគ្រឿងប្រមកវាយយកស្រុកគីដាវ ឥឡូវដែលអ្នកចាំឲ្យហានគីមានសំបុត្រមកសុំកងទ័ពយើងទៅជួយនោះ លោកកុំអាលលើកទៅឡើយ ព្រោះអ្នកចាំមិនអាចតទល់គំនិតគិត នឹងថ្វីដៃប្អូនបានទេ ត្រូវតែយើងនៅស្ងៀមឲ្យអ្នកចាំចាញ់ប្អូនទៅចុះ ទបមាដូចយើងខ្វីដៃប្អូនឲ្យសម្លាប់អ្នកចាំចេញ ។ អ្នកសុនយល់ឃើញត្រូវផង ក៏ធ្វើសំបុត្រតបទៅវិញថា ដែលនឹងឲ្យយើងលើកកងទ័ពទៅជួយនោះ មិនកើតទេ ព្រោះប្អូនកខ្វង់ដែនចូលមកក្នុងស្រុកយើង ហើយ ត្រូវតែយើងរៀបគិតការពារ រក្សាស្រុកទុកឲ្យមាំអ្នកសិន ។ បំរើក៏ទទួលសំបុត្រ ហើយស្រូតទៅឲ្យអ្នកចាំៗ ឃើញសំបុត្រហើយក៏ខឹងណាស់ ទើបចាត់ឲ្យចាប់យកខ្លួនហានគី ទៅប្រហារជីវិត ហើយប្រឹក្សានឹងគួរគោ សុំនបនថា យើងគិតចូលទៅធ្វើពដការជាមួយនឹងប្អូនវិញ ស្រួលជាង ប្រយោជន៍បានសេចក្តីសុខតទៅ ។ គួរគោនឹងសុំនបេងនៅស្ងៀម មិនភានឆ្លើយតបថាម្តេច ។

ឯបំរើសេះ លុះត្រូវដំណើរដូច្នោះហើយ ក៏នាំសេចក្តីនោះទៅប្រាប់អ្នកសុន តាមពាក្យអ្នកចាំប្រឹក្សា ។ អ្នកសុនក៏ពិគ្រោះប្រឹក្សានឹងសឹមផោយថា

ប្រសិនបើ យើងមិនលើកទ័ពទៅជួយអ្នកចាំហើយ អ្នកចាំគង់ទៅនៅទីនឹង ចុះមិនខានឃើញថា ស្រុកយើងក៏គង់ទីទ័លខ្ចប់អន្តរាយ ៗ សឹមផ្តាយយល់ ឃើញត្រូវផង អ្នកស៊ុនក៏ចាត់ប្រើសឹមដៅយទីងសោហ៊ុំ ជានាយទាហាន ឲ្យនៅរក្សាស្រុក ចាត់ប្រើលើកទ័ព ទីងលីសៀម បងប្អូនឲ្យលើកទាហាន ៣ ម៉ឺនទៅជាទ័ពស្រួច អ្នកស៊ុនជាទ័ពហ្លួង ប្រញាប់ដូនលើកចេញទៅ លុះទៅ ដល់ជិតបន្ទាយអ្នកចាំ ក៏ឈប់ទ័ពចាំស្តាប់ការដែលអ្នកចាំធ្វើសឹកទីងចុះ ៗ

ឯអ្នកហ៊ុំទីងកោក័នដឹងដំណឹងហើយ ក៏ប្រមូលទាហានជាកងទ័ព លើកមកតាំងបន្ទាយ ជាំលំជាប់គ្នាពីបន្ទាយអ្នកស៊ុនទៅ ៗ ពេលនោះ មានអ្នកបំរើសម្នាក់ ចូលទៅរំពឹងអ្នកចាំថា អ្នកស៊ុន, អ្នកហ៊ុំ ទីងកោក័ន លើកទ័ពមកជួយ ៗ អ្នកចាំក៏មានអំណរណាស់ មិនបានរំពឹងគិតទីងចូល ទៅនៅខាងក្នុងញ៉េ ហើយឲ្យតាំងបន្ទាយត្រួតមើលកងទ័ពទាំង ៣ កង ដើម្បីទីងធ្វើសង្គ្រាម គង់ដូចខ្លះនោះយ៉ាងម្តេចខ្លះ ៗ

ខណៈនោះ អ្នកស៊ុន, អ្នកហ៊ុំទីងកោក័នក៏លើកទាហានចេញគប្បាំង ទីងកងទ័ពចុះ បាញ់កាំភ្លើងគ្រប់គ្រា តាំងពី ១៧.១៨ ថ្ងៃ ទាហាន ក៏ត្រូវគ្រាប់ ពីការស្លាប់អស់ជាច្រើនណាស់ ៗ លុះគន្ធងមកថ្ងៃ ១ ចុះ ឃើញកល់ការបានចំណាប់ ក៏រៀបចែកកងទ័ពជា ៤ ក្រុម, លើកទៅ វាយទំលាយព្រមគ្នាទាំង ៤ ទិស គ្រប់បន្ទាយ ទាហានទាំង ៣ ប្រកក៏ របួសពីការស្លាប់ខ្លះ ម្នាក់ៗតែងតែគ្នាយទៅផ្សេង ៗ ខ្លះ ចាប់បានខ្លះ ៗ អ្នកចាំ, អ្នកស៊ុន, អ្នកហ៊ុំ ទីងកោក័នឃើញថា ទីងទ្រាំតទល់ពុំបាន

ក៏ចោលបន្ទាយនាំទាហានទាំងឡាយ ដែលសល់នោះ វាយរត់ចេញទៅ ចូចូក៏លើកពលសេនាទាហានដេញតាមទៅ ។

ឯអួនថាំងអួនសុងនោះ ក៏រត់ចូលទៅក្នុងស្រុកគីជីវបាន ហើយឲ្យទាហានឡើងរក្សាសើនបន្ទាយជាមាំមួន តែអួនហ៊ុំទឹងះកាក់នលើកទាហានទៅតាំងបន្ទាយបង្ខាំងតទីងចូចូខាងក្រៅស្រុក ចូចូក៏ឲ្យតាំងបន្ទាយជាប់គ្នា ហើយលើកទៅវាយបន្ទាយអួនហ៊ី, គោក៏នជាច្រើនគ្រា មិនបែក-ៗ គុយកែជំរាបចូចូថា វេលានោះ អួនសៅស្លាប់ទៅហើយ ទាហានដែលយើងចាប់បាននោះ វានិយាយថា បុត្រអួនសៅ ៣ នាក់ ដណ្តើមគ្នាបង្កើតធំ អួនសុងជាប្អូន តាំងខ្លួនជាចៅហ្វាយខេត្រគីជីវ គ្រានេះ ទទួលមានបើកសង្គ្រាមបានជាព្រមគ្នាលើកទ័ពមកច្បាំងជួយគ្នារក្សាស្រុក ប្រសិនបើអស់សឹកសង្គ្រាមហើយ អ្នកទាំង៣ នាក់ ក៏នឹងតាំងដណ្តើមគ្នាកើតជាចំបាំងឡើងពុំខាន ហេតុនេះ សូមឲ្យលោកលះបង់ ស្រុកគីជីវទុកមួយអន្លើសិនចុះ ត្រូវលើកគងទ័ពទៅវាយយកស្រុកកេងជីវ ទីងអាណាខេត្រទិសខាងត្បូង កំចាត់ឡៅប៉ៀវចេញសិន ឯបុត្រអួនសៅ ៣ នាក់នេះ បើឃើញយើងលើកគងទ័ពចេញទៅហើយ គង់ទឹងបណ្តាលជាចំបាំង ដណ្តើមយកស្រុកគ្នាទៅវិញទៅមក កាលណាបើ កំឡាំងខាងណាអន់ថយចុះហើយ សឹមយើងលើក មកច្រូតវាយយកស្រុកគីជីវបាន យ៉ាងស្រួលណាស់ ៗ ចូចូយល់ត្រូវផង ទើបប្រជុំគ្នាលើកគងទ័ពត្រឡប់ទៅបន្ទាយលីយ៉ុង ហើយចាត់ឲ្យការសៀងត្រួតទាហាន នៅរាំងទ័ពក្នុងដំបន់នោះ ចាត់ឲ្យហោហង់លើកទាហានទៅរាំងទ័ព នៅមាត់ទន្លេហាងហោ ឯខ្លួនចូចូ

កំលើកទ័ពចុះទៅខាងផ្លូវអាណាខែត្រទិសខាងត្បូង ៗ ចំណែកអ្នកហ៊ុ
ទឹងគោកន ឃើញបច្ចាលើកទ័ពត្រឡប់ទៅហើយ ក៏មានចិត្តអរណាស់
នាំគ្នាលើកទ័ព ត្រឡប់ទៅស្រុករៀងខ្លួន ៗ

ខណៈនោះ អ្នកជាំដែលនៅក្នុងស្រុកគីជីវ ក៏លបប្រឹក្សាខឹងគួសៅ
ស៊ុនបេងថា ខ្លួនយើងជាបុត្រច្បងអ្នកស៊ុងជាបុត្រទៅ ហើយកើតពីភរិយា
ត្រូចផង តាំងអាយុក៏នៅក្មេងៈសេចក្តី ទុំគំនិតជាងយើងទាំងអស់ ដែលមក
ដាក្តើមធ្វើធំ ក្នុងស្រុកគីជីវនេះ យើងមិនយល់ព្រមផងទេ អ្នកទាំងពីរទឹង
យល់ឃើញប្រការម្តេច ? ខ្លួគារឆ្លើយថា លោកចូរប្រុងប្រៀបសេនា
ទាហានចេញទៅនៅក្រៅស្រុកចុះ ហើយឲ្យទាហានតួនបន្ទប់សងខាង
ផ្លូវទុកឲ្យព្រម រួចឲ្យចូលទៅប្រាប់អ្នកស៊ុង ទឹងសីមផោយថា ខ្លួនលោក
ទឹងរៀបលើកត្រឡប់វិលទៅខែត្រវិញហើយ សូមអញ្ជើញអ្នកស៊ុង ទឹង
សីមផោយ ទៅស៊ីលៀងជាសេចក្តីមេត្រីពប់អាន បើកាលណាអ្នកស៊ុងទឹង
សីមផោយ ទៅដល់កន្លែងនោះហើយ ឲ្យទាហានដែលតួនបន្ទប់នោះ
ចេញឲ្យព្រមគ្នាមកចាប់អ្នកស៊ុង ទឹងសីមផោយសម្លាប់ចេញ ស្រុកគីជីវ
ក៏នឹងបានដល់លោក ៗ អ្នកជាំយល់ឃើញត្រូវ ក៏នាំទាហានចេញមក
តាំងក្រៅស្រុក ហើយរៀបចំទុកតាមវិធី ដែលគិតធ្វើនោះតាមពាក្យ
ខ្លួគារពន្យល់ ៗ ទណ្ឌលអង់ស៊ុវទីប្រឹក្សាអ្នកជាំ មកពីស្រុកសៀងជីវចូល
មកជួប អ្នកជាំក៏សួរសោកដោយសេចក្តីត្រេកអរ ហើយក៏ពណ៌នារឿង
ដែលគិតធ្វើអន្តរាយអ្នកស៊ុងនោះ ឲ្យអង់ស៊ុវស្តាប់ ៗ អង់ស៊ីវឆ្លើយថា
ធម្មតាបងប្អូនទឹងគ្នានោះ លោក ៗ មាប់ដូចដើងដៃទាំងស្តាំទាំងឆ្វេង ហេតុ

ម្តេច លោកមកគិតស្រាល? កាត់ដៃជើងរបស់ខ្លួនហោលដូច្នេះ មិនគួរសោះ កាលបើលោកធ្វើប្រទូស្តកយកាត់បង់ប្អូនចេញដូច្នេះ ខ្ញុំបាទក៏មិនមាន សេចក្តីសប្បាយទេ ដែលលោកនឹងយកអ្នកដទៃ មកធ្វើជាបងប្អូនវិញនោះ តើនឹងមានចិត្តឈឺឆ្អាលប្រាកដនឹងលោក ឬ? លោកមិនគួរនឹងស្តាប់ពាក្យ មនុស្សនាំញុះញង់សោះ ព្រោះមនុស្សគេសនោះ សុទ្ធតែគិតខ្លួន នឹងយល់ បំណាច់មាត់តែ ១ ស្របកនោះ មកជាទីសង្ស័យវែងឆ្ងាយពុំបាន ។

អ្នួនថាបានស្តាប់ហើយ ក៏ខឹងខ្លាំងណាស់ បណ្តេញអង់ស៊ីវ ឲ្យដើរចេញ ពីទីនោះ ហើយបំរើចូលទៅអញ្ជើញអ្នួនសុង នឹងសឹមផោយមកបរិភោគ អាហារតាមពាក្យគួរគៅ ។ អ្នកបំរើក៏ចូលទៅជំរាបអញ្ជើញអ្នួនសុង នឹងសឹម ផោយតាមបង្គាប់ថា អ្នួនថាឲ្យអញ្ជើញលោកទៅស៊ីលៀង ។ អ្នួនសុង ក៏ប្រឹក្សានឹងសឹមផោយថា ដែលអ្នួនថាឲ្យអ្នកមកហៅយើងចេញទៅ បរិភោគអាហារនោះ តើអ្នកយល់ឃើញប្រការម្តេច? សឹមផោយឆ្លើយថា ដែលអ្នួនថាឲ្យមកហៅយើងទៅនោះ ខ្ញុំបាទយល់ថា ជាគំនិតរបស់គួរគៅ ធ្វើកល់ឧបាយទេ បើយើងនឹងចេញទៅវេលានេះ មុខជាកើតអន្តរាយជា ប្រាកដ តែបើយើងនឹងបង្អង់នៅស្ងៀមវិញ អ្នួនថានឹងគួរគៅមុខជាមានគំនិត គិតថែមឡើងទៀត សូមឲ្យលោកលើកទ័ពចេញទៅចាប់អ្នួនថានឹងគួរគៅ សម្លាប់ចេញវេលានេះ ទើបស្រុកយើងអស់ចំរូងចំពាសតទៅ ។ អ្នួនសុង យល់ឃើញត្រូវ ក៏ប្រមូលទាហានបាន ៥ ម៉ឺន ចេញទៅក្រៅស្រុក ។

ឯចំណែកអ្នួនថា ឃើញអ្នួនសុងលើកទ័ពចេញមកជាក្បួនពិជ័យ

សង្គ្រាមដូច្នោះ យល់ថាអ្នកស៊ុនដឹងដល់ឧបាយនៃខ្លួន អ្នកចាំក៏ពាក់គ្រោះ
ឡើងសេះ កាន់ខ្លួននាំទាហានចេញទៅ ហើយស្រែកហៅអ្នកស៊ុនថា ឯង
ជាមនុស្សអកតញ្ញូរយសណាស់ ហ៊ានយកថ្នាំពិសបន្ទុំឲ្យបិតាបរគោត
ពាល់អនិច្ចកម្ម ហើយតាំងខ្លួនឡើងធ្វើជាធំ សម្រេចរាជការក្នុងខែត្រគឺជាវ
ឲ្យអញឡើងស្លាប់បង្គាប់ឯងជាប្អូនទឹកដោះនៅមាត់ដូច្នេះ ជាគួរហើយឬ ?

អ្នកស៊ុនឮហើយខឹងណាស់ បរសេះដេញទាហានឲ្យចូលតយុទ្ធនឹង
អ្នកចាំជាពន្ទឹក អ្នកចាំទ្រាំកម្លាំងនឹងអ្នកស៊ុន មិនបានក៏បរសេះនាំទាហាន
ទាំងពួងរត់ទៅ អ្នកស៊ុនក៏ដេញកាប់សម្លាប់ទាហានអ្នកចាំស្លាប់អស់ជា
ច្រើន លុះទឹងតាមអ្នកចាំទៅទៀតឃើញថា មិនទាន់ហើយក៏លើកទ័ព
ត្រឡប់ចូលមកស្រុកវិញ ៗ អ្នកចាំដឹងថាអ្នកស៊ុនលើកទ័ពទៅវិញ ក៏ឈប់
ទ័ពនៅទីនោះ ហើយគិតនឹងលើកទ័ពទៅសងសឹកអ្នកស៊ុន ទើបឲ្យ
ធៀមផេកលើកទាហានជាកងមុខ ( ទ័ពស្រួច ) ខ្លួនឯងនោះជាកងហ្លួង
( ទ័ពធំ ) ធ្វើត្រឡប់ទៅនឹងចាប់យកខ្លួនអ្នកស៊ុន ៗ

អ្នកស៊ុនដឹងសេចក្ដីដូច្នោះ ក៏ប្រមូលទាហានលើកមកច្បាំងនឹងអ្នក
ចាំវិញ ធៀមផេកក៏បរសេះចេញទៅមុខទាហាន ហើយស្រែកហៅអ្នក
ស៊ុនជាពាក្យជេរប្រទេចគោះផ្សេងៗ អ្នកស៊ុនបានស្ដាប់ដូច្នោះ ក៏ខឹងណាស់បរ
សេះចេញទៅប្រយុទ្ធគ្នានឹងធៀមផេក លើកដៃស្រែកហាមឃាត់អ្នកស៊ុន
ថា ដែលលោកនឹងចេញទៅគនឹងធៀមផេកនោះមិនគួរទេ ទុកឲ្យខ្ញុំបាទ
នឹងសូមយកអាសា ចេញទៅដោយខ្លួនឯង ហើយលើកដៃបរសេះចេញទៅ

ប្រយុទ្ធគ្នានឹងនៀមផេកបាន ៤ ថ្ងៃ លីកង៍យកខ្លួនចាក់ត្រូវនៀមផេក ធ្លាក់ពីលើសេះស្លាប់ អួនថាំឃើញទាហានខ្លួនរៃខ្សីរែតដូច្នោះ ក៏បរសេះ នាំទាហានរត់ទៅចូលស្រុកពេងង្ហួនគួនជាស្រុកចំណុះ ក៏តាំងឲ្យសេនាទាហានឡើងត្រួតត្រាក្បាលសើនបន្ទាយជាមាំមួន ៗ

ចំណែកអួនស៊ុងក៏លើកទាហានដេញតាមទៅឃើញដូច្នោះ ហើយតាំងឲ្យពយកងទ័ពឡោមព័ទ្ធជុំវិញស្រុកនោះ គ្រប់គយទាំង ៣ ទិស ៗ គួតៅក៏និយាយនឹងអួនថាំថា ដែលយើងនឹងតាំងទ័ពនៅក្នុងស្រុកពេងង្ហួនគួននេះតទៅមិនបានទេ ព្រោះស្រុកនេះមិនសូវមានស្បៀងអាហារបរិបូណ៌ ទាំងទាហានអួនស៊ុង ក៏ក្លៀវក្លាមានចិត្តកំរើក សូមឲ្យលោកមានសំបុត្រទៅដល់ចូឆូ សុំចុះចូល ឲ្យចូឆូលើកទ័ពមកវាយយកស្រុកគីជីវ កាលណាបើចូឆូលើកមក អួនស៊ុងក៏នឹងលើកទ័ពទៅតទល់នឹងចូឆូខាងណោះ សឹមយើងលើកចេញទៅវាយខ្នងពីក្រោយ មុខជាអួនស៊ុងនឹងចុះសំការ ជាប្រាកដ ឯចូឆូដែលលើកទ័ពមកនោះ ជាផ្លូវឆ្ងាយដាច់ស្រយាលមិនមានស្បៀងអាហារ បើសិនណាជាយើងនឹងរិះគិត ត្រឡប់ធ្វើសង្គ្រាមនឹងចូឆូក៏នឹងមានជ័យជំនះដោយងាយ ដែលខ្ញុំបានជំរាបនេះឃើញថា បានការទាំងសងខាង ៗ អួនថាំយល់ឃើញត្រូវ ទើបប្រឹក្សាថា អ្នកបានឃើញនរណាមានគំនិតគិតគ្រាន់បើ នឹងប្រើឲ្យកាន់សំបុត្រទៅឲ្យចូឆូ ៗ គួតៅទើបថា ស៊ុនគីជាចៅហ្វាយស្រុកពេងង្ហួនគួន ជាមនុស្សមានស្មារតីប្រាជ្ញា ហើយត្រូវជាប្អូនស៊ុនបេងផង សូមលោកចាត់ប្រើឲ្យកាន់សំបុត្រទៅចុះ មុខជាចេះនិយាយឲ្យចូឆូលើកទ័ពមកបាន ៗ

អួនចាំធ្វើសំបុត្រ សេចក្តីថា ខ្ញុំបាទអួនចាំសុំចំណុះចុះចូលតំនាប់មកមហាឧបរាជ សូមឲ្យមហាឧបរាជ លើកកងទ័ពមកជួយកំចាត់អួនសុងដែលប្រព្រឹត្តទុច្ចរិតចេញ ខ្ញុំបាទនឹងក់យជាទ័ពសន្ទប់ខ្ទប់ពីម្ខាង បើសម្រេចការហើយ ខ្ញុំបាទក៏សូមចូលធ្វើការស្វាមីភក្តិ នឹងលោកតទៅ លុះតែងស្រេចហើយ ក៏ប្រគល់ឲ្យស៊ុនភីកាន់ចេញទៅ ហើយផ្តាំថា អ្នកចូររិះគិតរកគំនិតនិយាយ ឲ្យប៊ូឆ្មលើកទ័ពមកជួយកុំឲ្យខាន រួចប្រគល់ទាហាន ៣ ពាន់ ឲ្យស៊ុនភីនាំទៅទំលាយទ័ពអួនសុង ដើម្បីនឹងចេញទៅឲ្យបានៗ ស៊ុនភីទទួលសំបុត្រហើយ ក៏លាទៅនាំទាហានវាំង ៣ ពាន់ ការទំលាយចេញទៅផុតកងទ័ពអួងសុង ស៊ុនភីក៏ខំប៉ះសេះទៅរកប៊ូឆ្ម ខាងទិសឯត្បូងតែម្នាក់ឯង ។

ឯប៊ូឆ្មបានលើកទ័ពទៅដល់ស្រុកសេប៉េងគួន ដែនស្រុកកេងជីវទៀវបៀវជីងហើយក៏តែណ្ហទាហានប្រគល់ឲ្យទៀវពីលើកចេញទៅតតាំងច្បាំងនឹងកងទ័ពប៊ូឆ្ម ។ ខណៈនោះ ទទួលស៊ុនភីទៅដល់កងទ័ពប៊ូឆ្ម ទាហានប៊ូឆ្ម ក៏នាំខ្លួនទៅជួបនឹងប៊ូឆ្មៗ ទទួលយកសំបុត្រពីស៊ុនភីមកមើលដឹងសេចក្តីហើយ ក៏ប្រឹក្សានឹងសេនាទាំងពួងថា អួនចាំមានសំបុត្រមកអង្វរគេ សូមចំណុះចុះចូលយើង តើអ្នកទាំងពួងនឹងយល់ឃើញប្រការម្តេច? ធៀយ៉ុកជំរាបថា ត្រោះនេះ ឃើញថា អួនចាំនឹងបរាជ័យចាញ់អួនសុងហើយ បានជាមានសំបុត្រមកសុំចំណុះចុះចូលលោក ប្រាថ្នានឹងឲ្យលោកលើកទ័ព ទៅជួយកំចាត់អួនសុងចេញ តែលោកកុំអាលជឿទុកចិត្តឡើយ ។

លីយ៉ែយទឹងម៉ាន់ថង់ឆ្លើយថា ពីថ្ងៃមុន លោកលើកកងទ័ពមកប្រាថ្នានឹងកំចាត់ឡាវបៀវ ដែលលោកនឹងត្រឡប់ទៅជឿកាន់យកសំដីខាងអួនថាំ ហើយនឹងលើកទ័ពត្រឡប់ទៅវិញនោះ មិនគួរសោះ ៗ ស៊ុនហ៊ុរឆ្លើយថា ដែលអ្នកទាំង ៣ នាក់និយាយមកនោះ ខ្ញុំមិនយល់ព្រមផងទេ ព្រោះផែនដីសព្វថ្ងៃនេះ កំពុងតែកើតចលាចល អាណាខេត្រទាំងពួងសុទ្ធតែប្រកាន់ មិនចង់ចំណុះចុះចូលទៅខាងណា ដូចឡាវបៀវដែលបានជាធំគង់ខេត្រកេងជីវនោះ មានស្រុកតូចជាចំណុះច្រើនដំបន់ក៏មែន តែថាឡាវបៀវនោះ មានដម្រេះប្រាជ្ញាតិចណាស់ មិនបានគិតឲ្យអាណាខេត្ររបស់ខ្លួន រីកធំទូលាយចេញទៅទៀត ឯអួនសៀវកៃខ្សែជីវិតទៅហើយ តែនៅមានកូនចៅផៅសន្ដានជាច្រើន ស្រុកចំណុះធំ ៗ ក៏មានដល់ ៤ មណ្ឌល ស្រុកចំណុះតូច ៗ ក៏ច្រើនដំបន់ ទាំងពលសេនាទាហានក៏មានច្រើនរាប់រយម៉ឺនបាយ បើកូនចៅផៅសន្ដានអួនសៀវ នៅជាប្រក្រតីនឹងគ្នា ក៏មិនមានអ្នកដទៃនឹងទៅញាំញីបានឡើយ ឥឡូវ អួនថាំនឹងអួនសុងទាស់ទែងគ្នា អួនថាំឲ្យមកលន់តួទោស អង្វរលោកហើយ ទោះបីជាសេចក្ដីកល់១បាយយ៉ាងណា ក៏ឃើញថាបានការខាងយើងហើយ សូមឲ្យលោកលើកកងទ័ពទៅជួយអួនថាំចុះ ដើម្បីនឹងកំចាត់អួនសុនចេញ រួចបីមយើងរិះគិត កំចាត់អួនថាំទៀត ក៏សឹងបានដោយងាយ ៗ

(មានត)

# រឿងហ្សាឌិក

លោកវុលតែរនិពន្ធ

## លោក ប៉ាយ-ប៊ុក រៀបរៀង

(តចប់)

គេមិនអាចលាក់បាំងបិទបាំង នូវសេចក្តីអនុគ្រោះនៃព្រះមហាក្សត្រចំពោះលោកហ្សាឌិកបានឡើយ ។ ព្រោះថា បណ្តាមហាជននៅទ្វីបអាស៊ី ព្រះបាទណាបុស្សន៍ ព្រះមហាក្សត្រ កោះសេរន៍ឌីប ជាព្រះមហាក្សត្រមានព្រះរាជចរិយាល្អផងគេ បើកាលណាទ្រង់ធ្វើព្រះរាជសន្ទនាការនឹងបុគ្គលណា ; បុគ្គលនោះ មិនលែងមានចិត្តភក្តីចំពោះព្រះអង្គឡើយ ។

ព្រះមហាក្សត្រអង្គនេះ ទ្រង់មានតែពួកសេវកាមាត្យ តែងតែចូលគាល់ហ្វៅ ដើម្បីសរសើរព្រះអង្គ ព្រមទាំងរិះរកនូវមធ្យោបាយគ្រប់យ៉ាង ដើម្បីនឹងបោកប្រាសព្រះអង្គ លួចព្រះរាជទ្រព្យ ។ ទ្រង់មានព្រះរាជបដិគ្គាហកៈមួយ តែងតែប្រព្រឹត្តបទទុច្ចរិតនេះៗ ទ្រង់បានផ្លាស់ប្តូរព្រះរាជបដិគ្គាហកៈជាមេឃ្លាំងព្រះរាជទ្រព្យនេះ ជាច្រើនលើកច្រើនសារតែទ្រង់មិនអាចប្រែគន្លងទម្លាប់អាក្រក់ ដែលត្រូវបែងព្រះរាជទ្រព្យ ជាពីរផ្នែក, ផ្នែកតិចជាងគេ ត្រូវបានទៅព្រះមហាក្សត្រ, ផ្នែកច្រើនជាងគេ ត្រូវបានទៅមេឃ្លាំងព្រះរាជទ្រព្យ ។ មានមួយថ្ងៃ; ព្រះបាទណាបុស្សន៍ ទ្រង់បានប្រឹក្សាជាមួយនឹងលោកហ្សាឌិក អំពីរឿងនេះថា លោកដែលចេះដឹងនូវវិជ្ជាគ្រប់បែបគ្រប់យ៉ាង តើលោកអាចរិះរកនូវមធ្យោបាយអ្វីមួយ ដើម្បីនឹងតាំងមេឃ្លាំងព្រះរាជទ្រព្យណាមួយ កុំឲ្យវាលួចព្រះរាជទ្រព្យបានឬទេ ?

លោកហ្គូឌិតក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា:

សូមទ្រង់ព្រះមេត្តាប្រោស ការនេះងាយណាស់, បុគ្គលណាដែលសុំធ្វើជាមេឃុំនឹងព្រះរាជទ្រព្យ, សូមព្រះអង្គទ្រង់ត្រាស់បង្គាប់ ឲ្យរាំទាំងអស់គ្នា ។ អ្នកណាដែលទឹងរាំស្រាលសមរម្យជាងគេ អ្នកនោះពិតជាបុរសសុចរិតពិតត្រង់; សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតបទៅនឹងលោកហ្គូឌិតថា : អ្នកឯងពោលពាក្យនេះ គឺពាក្យឡកចំអក, ហើយមធ្យោបាយដែលស្វែងរកមេឃុំសុចរិតបែបនេះ ជាមធ្យោបាយ គួរឲ្យខ្ញុំអស់សំណើចពន់ពេកណា ! លោកយល់ថា អ្នកណាដែលរាំល្អជាងគេ, អ្នកនោះ ជាមេឃុំសុចរិតហើយប៉ុនប្រសប់ជាងគេ ។

លោកហ្គូឌិតក៏ក្រាបបង្គំទូលតបព្រះមហាក្សត្រវិញថា "ទូលព្រះបង្គំជាខ្ញុំ មិនបានយល់ថា ជាមេឃុំប៉ុនប្រសប់ជាងគេទេ, ទូលព្រះបង្គំជាខ្ញុំគ្រាន់តែថាជាមេឃុំសុចរិតជាងគេ" ។

លោកហ្គូឌិត ក្រាបបង្គំទូលព្រះមហាក្សត្រណាប៉ុស្សន៍ ដោយពាក្យប្រៀបធៀបជាអនេកបរិយាយ តាល់តែទ្រង់ជឿជាក់ថា លោកហ្គូឌិតមានអានុភាពអាចកំបាំងអ្វីប្លែក ដែលជាលក្ខគោល សម្រាប់សំគាល់ពួកមេឃុំ ។

លោកហ្គូឌិត ក្រាបបង្គំទូលតបព្រះមហាក្សត្រវិញថា "ទូលព្រះបង្គំជាខ្ញុំ មិនចូលចិត្តខាងមន្តអាគមឬតែអ្វីប្លែកៗ ស្មារព្យ៉ាបារះទេ មនុស្សមានបុញ្ញានុភាពទិនសៀវភៅ ដែលមានការអាចកំបាំង, ទូលព្រះបង្គំជាខ្ញុំស្អប់ជា

យាំងក្រៃលែង ។ បើព្រះអង្គទ្រង់ព្រះរាជានុញ្ញាត ឲ្យទូលព្រះបង្គំជាខ្ញុំពិសោធមើល ក្នុងរឿងនេះ, ព្រះអង្គនឹងទ្រង់ជ្រាបជាអវសានថា ការអាថ៌កំបាំង ជាវត្ថុសាមញ្ញ ហើយមានសភាពងាយបំផុត ។

ព្រះបាទណាបុស្សង់ទ្រង់មានរាជហឫទ័យនឿងឆ្ងល់ថា ការអាថ៌កំបាំងនោះជារបស់ងាយបំផុត, ទ្រង់ក៏មានព្រះរាជបន្ទូលតបទៅលោកហ្វូឌិតវិញថា: "ចូរលោកធ្វើតាមចិត្តចុះ" ។

លោកហ្វូឌិត ក្រោយដែលបានទទួលព្រះបរមរាជឱង្ការ ក៏ចាត់ក្នុងថ្ងៃនោះ ឲ្យធ្វើព្រះរាជចុតហ្មាយផ្សាយ ក្នុងព្រះនាមព្រះមហាក្សត្រថា ឈ្មោះណាចង់ធ្វើជាមេឃ្លាំងព្រះរាជទ្រព្យ នៃព្រះបាទណាបុស្សង់ជាព្រះរាជបុត្រព្រះបាទណាស្យូណាប , ត្រូវស្លៀកពាក់ខោអាវព្រៃស្រាល ។ចូលមកនៅថ្ងៃទីមួយនៃព្រះបន្ទូលក្រពើ, ឯមហាប្រាសាទព្រះអង្គ ។

ពួកមុកកំចំនួន ៦៤ នាក់ក៏ចូលទៅឯមហាប្រាសាទ តាមកំណត់ពេល ។ គេបានចាត់ឲ្យពួក ក្នុងមកកាន់ព្រះបន្ទប់នោះ ដែលជាពេនបាំ ។ តែព្រះរាជបន្ទប់នោះ មានទ្វារបិទជិត, ដើម្បីនឹងទៅកាន់ព្រះបន្ទប់នោះ ត្រូវដើរកាត់ថ្នល់មួយធំងងឹត ។ មានអាញ់សាលាម្នាក់ ទទួលភារៈកាន់នាំបេក្ខជនទាំងឡាយ ទៅកាន់ម៉ឺនោះ ហើយ គេទុកឲ្យនៅទីនោះមួយស្របក់ ទើបបញ្ចូលឲ្យទៅចូលព្រះរាជបន្ទប់ ពេនកំជាអវសាន ។

ព្រះមហាក្សត្រ ទ្រង់បានពិភាក្សាជាមួយលោកហ្វូឌិត, បានយកព្រះរាជទ្រព្យមកគរទុក នៅម៉ឺនោះជាច្រើន ។

កាលពួកបេក្ខជនទាំងឡាយ មកដល់ព្រះរាជបន្ទប់ពេនកំនោះហើយ

ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យពួកនោះពាំ ។ ពួកអ្នកពាំគឺពាំធ្ងន់ដើរផង ហើយមិនសមរម្យផង, ពួកនេះមានក្បាលឱន, ត្រគាកធ្ងន់, ដៃជាប់ទៅនឹងឆ្អឹងជំនីរ . . . . . . . ។

លោកហ្វ្រាឌិត ពោលពាក្យខ្សឹប ៗ ថា ទុះហ៎! សុទ្ធតែពួកអាចោរពាលសាមាន្យ ។

បណ្តាពួកអ្នកពាំទាំងនោះ មានអ្នកពាំម្នាក់ ពាំទៅតាមចង្វាក់ភ្លេងសមរម្យ ឈានដើរហើស ក្បាលងើយមើលទៅលើ, កខ្លួនដើរត្រង់ស្រួល, ដៃលាតសន្ធឹងសម, ដងខ្លួនត្រង់ . . . . . . . ។

លោកហ្វ្រាឌិត ក៏ពោលថា "ទុះហ៎! មេឃ្លាំងសុចរិត, ។

ព្រះមហាក្សត្រទ្រង់តើនឡើង ស្ទុះទៅឱបអ្នកដែលពាំស្រាលសមរម្យនោះ, ហើយប្រកាសតែងតាំងអ្នកនោះ ជាមេឃ្លាំងព្រះរាជទ្រព្យ ។ ទ្រង់ត្រាស់បង្គាប់ឲ្យគេធ្វើទណ្ឌកម្ម ចំពោះពួកអ្នកពាំទាំង ៦៣ នាក់ ព្រោះពួកនេះ កាលអាជ្ញាសាលានាំមកកាន់យ៉ាងនោះ, រាស្រក់ព្រះរាជទ្រព្យជាក់ហោប៉ៅអាវខោ ធ្ងន់ដើរស្ទើរមិនរួច ។ ព្រះបមកពទ្រង់ព្រះគ្រោធខ្លាំងថា ចំពោះធម្មជាតិមនុស្ស, បណ្តាពួកពាំទាំង ៦៤ នាក់, មានចោរពាលទុច្ចរិត ដល់ទៅ ៦៣ នាក់, ហើយព្រះអង្គទ្រង់បានសម្មតនាមយ៉ាងនោះថាជាយ៉ាអកុសល ។

បើនៅប្រទេសប៉ែស, គេយកអ្នកពាំង ៦៣ នាក់ទៅធ្វើទណ្ឌកម្មជាយ៉ាងទុក្រិដ្ឋ (យកឈើស្រួចចាក់ពោះ ឲ្យធ្លាយពោះវៀន); នៅប្រទេសឯទៀត គេអាចឲ្យតុលាការសម្រេចសងព្រះរាជទ្រព្យ ដែលលួចនោះ

ឲ្យបានចំនួនលើសបីជង់ទៅទៀត , ហើយព្រះរាជទ្រព្យទាំងនោះមិនបាច់ចូលទៅក្នុងព្រះឃ្លាំងទេ, គឺចូលទៅក្នុងហោប៉ៅចៅក្រម; នៅព្រះរាជអាណាចក្រឯទៀត, ពួកទាំង ៦៣ នាក់ពួតដៃគ្នាធ្វើពាក្យតវ៉ាទៅជាប្រចួន, ហើយត្រូវអ្នកកាំម្នាក់ដែលកាំសមរម្យជាងគេ ទៅជាមានទោសទៅវិញ ។

តែនៅកោះសឺរ៉ង់ឌីប, ពួកអ្នកកាំទាំង ៦៣ នាក់ត្រូវពិន័យជាប្រាក់បន្តិចបន្តួច គ្រាន់តែឲ្យបានកើន ចំនួនព្រះរាជទ្រព្យនៅក្នុងព្រះឃ្លាំង ព្រោះព្រះបាទណាបុស្សង់ជាមហាសប្បុរស . . . . . . . ។

លំដាប់តអំពីនេះ, មិនឃើញមានរឿងរ៉ាវអ្វីទៀត ។ ចំពោះលោកហ្វ្រាឌិគនេះ, ខ្ញុំបានស្រាវជ្រាវរកឯកសារសព្វគ្រប់ហើយគ្មាន, សូមបញ្ចប់រឿងលោកហ្វ្រាឌិគត្រឹមប៉ុណ្ណេះ ។

## កំណាត់និងប្រវត្តិការណ៍

# ដំណើរទស្សនាការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រុងភ្នំពេញ

រៀបរៀងដោយ ជា-ទង់

សាស្ត្រាចារ្យទទួលភារៈខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

(តមក)

---

សហរដ្ឋអាមេរិកទាំងមូល មានទំហំផ្ទៃដី ចំនួន ២.៩៧៧. ១២៨ ម៉ាយល៍ ៤ ជ្រុង (ការ៉េ) ។ ប្រទេសនេះ មានព្រំប្រទល់ខាងជើងនឹងប្រទេសកាណាដា, ខាងត្បូងទល់នឹងប្រទេសមិកស៊ិក ខាងកើតទល់នឹងមហាសមុទ្រប៉ាស៊ីហ្វិក, ខាងលិចទល់នឹងមហាសមុទ្រអាត្លង់ទិក ។ នៅមានភូមិភាគ ២ កន្លែងទៀត ដែលមិនទាន់ចាប់បញ្ចូលជារដ្ឋនៅឡើយ គឺកោះហាវ៉ៃ និងអាឡាស្កា ។ សហរដ្ឋអាមេរិក សព្វថ្ងៃមានប្រជាជនទាំងអស់ ប្រមាណពី ១៦០ ទៅ ១៦៥ លាននាក់ ។

របៀបគ្រប់គ្រងប្រទេស ខ្ញុំពុំអាចដឹងបានដោយសព្វគ្រប់ទេ តែបានដឹងខ្លះៗ ថា សហរដ្ឋអាមេរិក មិនមានស្តេចសោយរាជ្យទេ មានតែប្រធានាធិបតី ដែលហៅតាមសំដីគេថា President ១ រូប ដែលប្រជារាស្ត្របោះឆ្នោតតាមស្ម័គ្រចិត្ត រើសយកតែមួយរូប បណ្តាបេក្ខជនពីររូបតំណាងគណបក្សពីរ គឺគណៈបក្សសាធារណរដ្ឋ និងគណៈបក្សប្រជា-

ធិបតេយ្យ ក្នុងរវាង ៤ ឆ្នាំម្ដង ជាអ្នកអភិបាលរក្សាសហរដ្ឋទាំងមូល ។ លោកប្រធានាធិបតី នៃសហរដ្ឋ មានអនុប្រធានាធិបតីមួយរូប ជាគូ-ឈ្មួយ ហើយនឹងមានលេខាធិការ (Secretary) ជាច្រើនរូបទៀត ធ្វើការជាមួយផង; លេខាធិការមួយ ៗ មានអនុលេខាធិការ (Assistant Secretary) ច្រើនរូបទៀតជាគូឈ្មួយជួយសម្រេចកិច្ចការគ្រប់យ៉ាង, ហៅរួមទាំងប្រធានាធិបតីនិងអនុប្រធានាធិបតី, លេខាធិការ, អនុលេ-ខាធិការទាំងអស់ ថា រដ្ឋាភិបាលសហរដ្ឋ (United States Governement) មានទីសំណាក់ការនៅវ៉ាស៊ីនតុនឌីស៊ី ដែលគេស្គាល់ថាជាធានីនៃសហរដ្ឋ ។

ក្នុងសហរដ្ឋអាមេរិក មានប្រជាជនច្រើនជាតិ ច្រើនសាសន៍ លាយចំរុះគ្នា ខ្លះមានសញ្ជាតិដើមជា រុស្ស៊ី, ហាកិង, អល្លឺម៉ង់, ជប៉ុន, ចិន, អេស្ប៉ាញ៉ុល អហ្វ្រិក ។ ល ។ រួមចូលជាតិជាអា-មេរិកាំង ។ ខ្លះមានជាតិដើម ជាអាមេរិកាំងស្រេចស្រាប់តែម្ដង ។ បានព្រថា ជនជាតិទាំងឡាយណាក៏ដោយ ឲ្យតែកើតក្នុងសហរដ្ឋ នឹងទៅជាពលរដ្ឋអាមេរិកាំង ក្នុងពេលដែលខ្លួនមានអាយុ ១៨ឆ្នាំ ។ ហេតុដូច្នេះ ជនជាតិនេះមានពណ៌សម្បុរ សាច់ ឈាម ក្លក មុខ មាត់ ប្លែក ៗ គ្នា អាចកំណត់សំគាល់បានថា គាត់ច្រើនជាតិ ច្រើនសាសន៍មែន ៗ ប៉ុន្តែ បើទុកជា-ច្រើនជាតិ ច្រើនសាសន៍យ៉ាងនេះក៏ដោយគេហៅជនជាតិនេះថាជាតិអា-មេរិកាំង មាន ២ យ៉ាង គឺអាមេរិកាំងស នឹងអាមេរិកាំងខ្មៅ ដែលគេហៅ នីគ្រោ Negro ។

ប្រជាជនអាមេរិកាំងទាំងអស់ ទាំងប្រុសទាំងស្រី សុទ្ធសឹងតែជាប្រជាជាតិមានសិទ្ធិ, សេរីភាពនិងសមត្ថភាពបរិបូណ៌ មានចំណេះវិជ្ជា ការចេះដឹងគ្រប់គ្រាន់ អាចប្រើប្រាស់នូវសិទ្ធិនិងសេរីភាព ដែលខ្លួនមាន ឲ្យបានម៉ត់ចត់ត្រឹមត្រូវ តាមក្របខ័ណ្ឌ ដែលមានគ្រាទុកក្នុងច្បាប់ផ្សេង ៗ និងក្នុងរដ្ឋធម្មនុញ្ញរបស់ជាតិគេ ។ គេគោរពប្រតិបត្តិច្បាប់ណាស់ ច្បា់ហាមមិនឲ្យធ្វើអ្វី គេមិនហ៊ានធ្វើបំពានច្បាប់ឡើយ គេធ្វើតែអំពើណាដែលច្បាប់អនុញ្ញាតឲ្យធ្វើ ។

សហរដ្ឋអាមេរិក តាំងតែពីដណ្តើមយកឯករាជ្យភាព និងអធិបតេយ្យ បានមកនៅក្នុងកណ្តាប់ដៃខ្លួនវេលាណា ប្រជាពស្រ្តទាំងសាកល មានយោបល់ស្របគ្នា សាមគ្គីមេកំឡាំងគ្នាជាប់ ខំការពាររក្សាឯករាជ្យរបស់ខ្លួន មិនឲ្យធ្លាក់ទៅក្នុងកណ្តាប់ដៃបរទេស បានដោយងាយឡើយ គឺដោយសារតែសេចក្តីព្រមព្រៀងគ្នា ស្តាប់បង្គាប់គ្នា មានឆន្ទៈស្របគ្នា នេះឯងហើយបានជាគេអាចកសាងប្រទេសជាតិគេ ឲ្យបានចំរើនរុងរឿងជាអាទ្យប្រទេសមួយ ក្នុងលោកនេះ ។

ក្នុងដំណើរទស្សនាសហរដ្ឋចំនួន ២ ខែកន្លះ យើងបានសង្កេតឃើញខ្លះ នូវខសំខាន់ ៗ ដែលប្រជាជនអាមេរិកាំងប្រតិបត្តិ ដើម្បីសេចក្តីចំរើនប្រទេសជាតិ គឺ

១ ប្រជាជនអាមេរិកាំង មានសេចក្តីស្អប់ខ្ពើមសេចក្តីថោកទាបនិងភាពល្ងង់ខ្លៅ មិនចង់ឲ្យប្រទេសជាតិរបស់ខ្លួន ធ្លាក់ទៅក្នុងកណ្តាប់ដៃបរទេសណាមួយឡើយ, មានស្មារតីដឹងខ្លួន មានសាមគ្គីព្រមព្រៀងគ្នា

គោរពប្រតិបត្តិច្បាប់របស់រដ្ឋ របស់សហរដ្ឋពុំមានខះញៀន មិនហ៊ានបំ-ពានច្បាប់សូម្បីកន្ទិចស្តួត; ការគោរពប្រតិបត្តិ តាមច្បាប់របស់រដ្ឋនេះ ហើយជាករណីយកិច្ចដ៏វិសេសបំផុតរបស់គេ ។

២ – មន្ត្រីអ្នកកាន់អំណាចនីតិប្រតិបត្តិទាំងឡាយ ជាអ្នកប្រើអំណាចរៀងខ្លួន គឺជាមានសមត្ថភាពគ្រប់គ្រាន់ ក្នុងមុខក្រសួងរបស់ខ្លួន គេមិនលើកលែងទោសត្រាប្រណីទេ តែកាលណាធ្វើខុសច្បាប់ ។ ច្បាប់ទាំងឡាយបិតនៅពីខាងលើ នៃប្រជាជនទាំងអស់ ទោះនាម៉ឺនមុខមន្ត្រី ទោះរាស្ត្រប្រជា ឧទាហរណ៍ថា "ក្នុងទីក្រុង ច្បាប់ចរាចរណ៍ក្រុង អនុញ្ញាតឲ្យបររថយន្ត ២៥ ម៉ាយល៍ ក្នុង ១ ម៉ោង, បើជនណាមួយបរហួសពីកំរិតល្បឿននេះ ប៉ូលិសបញ្ជាម៉ូតូតាមក្រាម កៀនឡានឡើងលើចិញ្ចើមថ្នល់ក្បែត ចេញសំបុត្រលក្ខពិន័យ ១ រំពេច ឲ្យទាន់ចិត្ត" ។ ប៉ូលិសក្រុង មានអំណាចខ្លាំងជាទីបំផុត អាចផ្ដន្ទាទោសបាន តាមនាទីរបស់ខ្លួន ។ ប្រជាជនទូទៅ ខ្លាចប៉ូលិសគោរពគ្រប់គ្នា ។ គេមិនមែនខ្លាចជនអ្នកធ្វើជាប៉ូលិសទេ គឺគេខ្លាចច្បាប់របស់ប៉ូលិស ។ មានរឿងមួយខ្ញុំ តែបានសេចក្ដីថា "មានកាលយប់មួយនោះ ស្ងាត់ណាស់ហើយ, មិនមែនជាម៉ោងប៉ុន្មានឲ្យប្រាកដទេ តែនៅក្នុងថ្នល់មានឡានបើកមួយ ១ ... នៅត្រង់ផ្លូវបែកជាបួន គេដាក់ភ្លើងបំពាក់សំរាប់ផ្លូវ មនុស្សដើរក្ដី ឡានក្ដី, ព្រោះគេជាព្រះគុណព្រះពោធិវង្ស របស់យើង លោកទតមើលពីបន្ទប់ផ្ទះសំណាក់ទៅ ឃើញឡានមួយឈប់ស្ងៀមកណ្ដាលថ្នល់ លោកឆ្ងល់ ម៉េចបានជាគេមិនបរទៅ ? ក្នុង

ពេលនោះ លោកបានឃើញបន្ទាន់គ្នា នូវភ្លើងក្រហមខ្មៅ ដែលជាសញ្ញាថាឈប់កុំទៅ លោកដឹងថា ឥ! គេគោរពច្បាប់ភ្លើងក្រហមរបស់គេ, លោកមានតុកដីកាថា លោកបន្តការចាំលបមើល តើមានអ្នកណាមួយហ៊ានបំពានច្បាប់ភ្លើងក្រហមទេ បើឈប់ស្ងាត់ដូច្នេះ? គ្មានសោះ! ព្រឹកឡើង លោកមានតុកដីកាប្រាប់ខ្ញុំថា ហឺ! ស្រុកនេះ គេគោរពច្បាប់សំពប់ដ្បិមែនហើយ! សូម្បីក្នុងទីស្ងាត់ក៏គេមិនហ៊ានបំពានច្បាប់គេដែរ! លោកទើបមានតុកដីកាពយរឿងនេះប្រាប់ខ្ញុំ និងអ្នកឯទៀតជាច្រើនៗ និទាននេះមិនជាពិរោះទេ ព្រោះមិនសូវកំសត់ តែមានប្រយោជន៍គួរឲ្យសរសើរដល់ជនជាតិគេ បំពោះការគោរពច្បាប់នេះ ។

អំពីជីវភាពនៃប្រជាជន_ ជីវភាពនៃជនជាតិអាមេរិកាំងទាំងឡាយ សឹងដូចជាជីវភាពនៃជនជាតិឯទៀតដែរ ប៉ុន្តែជនជាតិនេះសម្បូរដោយគ្រឿងសម្ភារៈ សំរប់សំរួលជីវភាពរបស់គេ ឲ្យប្រព្រឹត្តទៅដោយស្រួលជាងជនឯទៀតខ្លះ (ដោយស្មាន) ។ គ្រឿងបក្រ គ្រឿងម៉ាស៊ីនគ្រឿងអគ្គិសនី ដែលស្រុកគេមានទាំងប៉ុន្មាន បានធ្វើឲ្យជីវភាពរបស់ជនជាតិគេ រស់នៅស្រស់ញញឹមប្រិមប្រិយ ។ អ្នកស្រុកអាមេរិកាំងមានរបៀបចិញ្ចឹមជីវិតប្លែកគ្នាដូច្នេះ :

១- ធ្វើស្រែចំការ: ដាំពោត, សណ្ដែក, ស្រូវ, ថ្នាំ និងបន្លែបន្លាផ្សេងៗ ដូចជា ប៉េងប៉ោះ, ត្រសក់, ដំឡូង និងផ្លែឈើឯទៀតជាច្រើន ;

២- ធ្វើការរាជការក្នុងក្រសួងផ្សេងៗ,

៣- ធ្វើរបរពាណិជ្ជកម្ម,

៤- ធ្វើការស៊ីឈ្នួលផ្សេងៗ (កម្មករ) ។

អ្នកធ្វើស្រែចំការ មានគ្រឿងស៊ីខ្លួនរស់ បណ្ដុះនៅ សំរាប់ សំរួលការរបរគេខ្លះ មិនបួរទៀបកំឡាំងការងារពេកទេ ។

ឯអ្នកធ្វើការរាជការវិញ ប្រហែលជាមិនប្លែកគ្នាប៉ុន្មាន អំពីអ្នករាជការនៃប្រទេសឯទៀតឡើយ ។

ចំណែកខាងរបរពាណិជ្ជកម្ម និងឧស្សាហកម្ម ជារបរធំបំផុត ក្នុងសហរដ្ឋ ។ មានសមាគម, ក្រុមហ៊ុនសហករជំនួញធំៗ ច្រើនណាស់ មិនឈ្នះនឹងរាប់ ឲ្យសព្វគ្រប់បានឡើយ ខ្ញុំគ្រាន់តែលើកឧទាហរណ៍ខ្លះៗ ដូចជាសមាគមអាកាសយាន, អយស្ម័យយាន, ឡានធំៗ រត់ឈ្នួលដឹកនាំអ្នកដំណើរពីកន្លែងមួយ,ទៅកន្លែងមួយ សមាគមជំនួញក្នុងប្រទេស ក្រៅប្រទេស,សមាគមខាងឧស្សាហកម្ម ធ្វើគ្រឿងចក្រ និងម៉ាស៊ីនផ្សេងៗ ខាងផ្នែកសិក្សា មានសមាគមផ្សេងៗ បង្កើតវិទ្យាល័យ មហាវិទ្យាល័យពាសពេញប្រទេស ។ល។ ខាងផ្នែកសង្គមកិច្ច មានសមាគមបង្កើតមន្ទីរព្យាបាលរោគ ជាច្រើនអនេក ។

(មានត)

# ព្រះរាជដំណើរសម្ដេចព្រះឧបយុវរាជ
# ទៅកាន់កោះសិរីលង្កា ក្នុងពិធីបុណ្យពុទ្ធជយន្តិ

លោក ក៉យ.ប៊ុក រៀបរៀង

(តមក)

## ថ្ងៃព្រហស្បតិ៍ទី ១៤ កុម្ភៈ

ម៉ោង ៨ សម្ដេចព្រះឧបយុវរាជនរោត្តមសីហនុ ទ្រង់បានធ្វើព្រះរាជដំណើរ ចេញពីទីក្រុងកូលម្ប ព្រមទាំងរដ្ឋមន្ត្រីក្រសួងវប្បធម៌, មន្ត្រីក្រុមពិធីសារនិងព្រះរាជបរិវារ ដើម្បីទៅកាន់ទីក្រុងគ័ល្ល ៗ នៅតាមផ្លូវនៃព្រះរាជដំណើរ ធម្មបទីបបរិវេណមហាវិហារ បានរៀបចំទទួលសម្ដេចជាឧឡារិក សម្ដេចបានទ្រង់ធ្វើព្រះរាជអំណោយចំនួន១០០០ រូបិយនៅវត្តនេះ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងប្រទេសកម្ពុជា ទ្រង់បានសព្វព្រះរាជហឫទ័យ ព្រះរាជទានព្រះរាជអំណោយ សាងសាលាបុណ្យមួយខ្នងដែរ ៗ លំដាប់តមក វត្តសោភរាជមហាវិហារ ក៏បានទទួលសម្ដេចជាអធិកអធម ទាំងគ្រហស្ថ ទាំងបព្វជិត រាប់ពាន់នាក់ ៗ ក្នុងពេលនោះ សម្ដេចទ្រង់បានទទួលព្រះរាជកិត្តិយស ស្ដេចយាងទៅបញ្ចុះបឋមសិលាឫក្ស នៅសាលាមួយថ្មី ហើយទ្រង់បានព្រះរាជទាននូវព្រះអំណោយ ១០០០ រូបិយ ចំពោះវត្តសោភរាជមហាវិហារ ៗ

លុះដល់ម៉ោង ១១ និង ១៥ នាទី, សម្ដេចបានយាងទៅដល់ទីក្រុងគ័ល្ល ៗ លោកចៅហ្វាយក្រុងនិងលោករដ្ឋមន្ត្រី ក្រសួងសិក្សាធិការជាប្រតិភូនៃរដ្ឋាភិបាលសិរីលង្កា ទៅរង់ចាំទទួលសម្ដេចដោយសេចក្ដីគោរព ៗ

លំដាប់តមក, មានការរៀបពិធីទទួលអភិសេកជាផ្លូវការ ចំពោះសម្តេច នៅសណ្ឋាគារក្រុង ជាព្រះរាជកិត្តិយស ។

ថ្ងៃរសៀល, សម្តេចទ្រង់យាងទៅបញ្ចុះបឋមសិលាឬគ្រឹះ មន្ទីរសំណាក់ការនៃសមាគមយុវពុទ្ធសាសនិក ហើយទ្រង់បានព្រះរាជទាននូវព្រះអំណោយ ១០០០ រូបិយទៀត ចំពោះសមាគមនេះ ។

រូបប្រធានក្រុមប្រឹក្សាក្រុងគល័ម្ព នៃខេត្តខាងទក្សិណប្រទេសសិរីលង្កា បានថ្លែងសន្ទរកថាមួយ ទទួលសេចក្តីអំណរ ចំពោះសម្តេចព្រះឧបយុវរាជ ។ ទ្រង់បានថ្លែងព្រះសន្ទរកថាតបទៅវិញថា:

"ព្រះឱវាទនៃព្រះបរមសម្ពុទ្ធជាម្ចាស់ ដែលព្រះអង្គទេសនាប្រដៅ ហើយដែលយើងប្រព្រឹត្តប្រតិបត្តិតាម ដើម្បីនឹងបំបាត់ ឬ បន្ថយនូវសេចក្តីទុក្ខលំបាកគ្រប់យ៉ាង នៃពិភពលោកក្នុងសម័យបច្ចុប្បន្ន . . . ។

ថា:

"ព្រះពុទ្ធសាសនាបានធ្វើ ឲ្យស្ថានភាពនយោបាយកម្ពុជរដ្ឋ ឲ្យកាន់តែមានទ្រង់ទ្រាយជាក់ច្បាស់ឡើង . . . . . . . . . . . . . ."។

ថា:

ស្ថានភាពនេះ គឺ អព្យាក្រឹតភាព ពិតប្រាកដ រវាងពួកទាំងពីរក្រុម ដែលធ្វើឲ្យពិភពលោកបែកបាក់គ្នា គឺ ឋិតនៅជាកណ្តាល អាចចូលទៅប្រាស្រ័យ នឹងពួកទាំងពីរក្រុមបាន ឥតមានទាស់ ។ ពោលយ៉ាងដូច្នេះ គឺថាមិនមែនជាឋិតនៅកណ្តាលទទេ , នោះគឺ បង្កើតក្រុមមួយជាថ្មី មានគំនិតអព្យាស្រ័យ ផ្ទុយស្មោះនឹងប្រទេសដទៃនោះឡើយ, ហើយ

ខ្ញុំគិតថា ប្រទេសសិរីលង្កា អាចនឹងមានយោបល់ដូចគ្នា នឹងប្រទេសកម្ពុជា ចំពោះបញ្ហានោះ . . . . . . . . . . . . . . . . . . . . ។

-ថា "ខ្ញុំសូមបញ្ជាក់ថា ព្រះពុទ្ធសាសនា ជាឧសថមួយដ៏ប្រសើរ សម្រាប់តែនូវបញ្ហាសង្គម គតិនិយម នឹងនយោបាយ ឲ្យកាន់តែចំរើនឡើង បញ្ហាដែលធ្លាក់ចរិយាមនុស្សទាំងឡាយ ឲ្យត្រូតជាប់ហេតុមកដល់សម័យបច្ចុប្បន្ន" ។

លំដាប់តមក, លោកសម-ញាណ អធិបតីពុទ្ធិកសមាគមកម្ពុជរដ្ឋ អនុប្រធាន ក្រុមប្រឹក្សាព្រះរាជាណាចក្រប្រទេសកម្ពុជា បានថ្លែងសុន្ទរកថាមួយដែរ ។

រួច, សម្តេចព្រមទាំងព្រះរាជបរិវារ ទ្រង់ស្តេចយាងទៅគោរពព្រះអដ្ឋិព្រះអរហន្តមោគ្គលិបុត្តតិស្សត្ថេរ ។ លុះដល់ម៉ោង ២១ សម្តេចទ្រង់យាងវិលត្រឡប់មកកាន់ទីក្រុងកុលម្បូវិញ ។

## ថ្ងៃទី ១៥ កុម្ភៈ

សម្តេចទ្រង់បានស្តេចយាងទៅធ្វើព្រះរាជប្រាស្រ័យ ដោយមេត្រីភាព ចំពោះលោក ស៊ែរ-ហ្សូន-កូតឺឡាវ៉ា អតីតរដ្ឋមន្ត្រីទីមួយ នៃប្រទេសសិរីលង្កាព្រមទាំងលោកសាន-យុន រដ្ឋមន្ត្រីទីមួយប្រទេសកម្ពុជា នឹងលោកសឺន-សាន ។

លំដាប់តមក ទ្រង់បានស្តេចយាងទៅកាន់គេហដ្ឋាន នៃលោកបណ្ឌូរនអ៊ីកេ រដ្ឋមន្ត្រីទីមួយសម័យបច្ចុប្បន្ន ។

ពេលរសៀល សម្តេចទ្រង់យាងទៅធ្វើព្រះរាជទស្សនាការ នៅ

មហាវិហារទុបទុត្តរមាយាទនិសាលារៀន នៅទីនោះ ហើយទ្រង់បានព្រះរាជទានព្រះអំណោយ ១០០០ រូបិយ ចំពោះវត្តនេះ និង ៣០០ រូបិយ ចំពោះភិក្ខុខ្មែរមួយរូប ដែលជាសមណនិស្សិតនៅសាលានេះ ។

លំដាប់តមក, មានពិធីរៀបចំទទួលសម្តេចដ៏ឧឡារិក នៅសណ្ឋាគារក្រុងកុលម្បូ, ដោយក្រុមប្រឹក្សាក្រុង ជាអ្នកចាត់ចែង ។ ក្នុងពេលនោះ សម្តេចទ្រង់បានធ្វើសន្និសីទពត៌មាន បញ្ជាក់អំពីការគមនាគម ជាច្រើន រវាងប្រជារាស្ត្រទាំងពីរ ហើយទ្រង់ក៏បានសំដែងសេចក្តីអរគុណចំពោះប្រជារាស្ត្រ នៃក្រុងកុលម្បូ ដែលបានរៀបចំទទួលទ្រង់និងគណៈប្រតិភូខ្មែរ ដ៏ឧឡារិក ។

សម្តេចទ្រង់បានប្រកាសថា: អាកប្បកិរិយានៃសហភាពសូវៀត និងប្រទេសចិនប្រជាមានិត ទៅកាន់ប្រទេសកម្ពុជា គឺត្រូវ នៅជាប្រកបដោយមេត្រីភាព, ព្រោះដែលប្រទេសកម្ពុជា បានកាន់នយោបាយអព្យាក្រឹត ។ ចំពោះជំនួយខាងសេដ្ឋកិច្ច និងបច្ចេកទេស, ទ្រង់បានបញ្ជាក់ថា មានប្រទេសជាតិប្រកបដោយមេត្រីភាព ដូចជាប្រទេស-បារាំង, សហរដ្ឋអាមេរិក, ប្រទេសចិនប្រជាមានិត, សហភាពសូ-វៀត, ក៏ជួយប្រទេសកម្ពុជា ខាងផ្នែកកសិកម្ម, ការអប់រំ និងសុខភាព ។

ទ្រង់មានបន្ថែមថា, "ក្រោយដែលកងទ័ពបារាំង ចេញពីប្រទេសកម្ពុជាពី គ.ស. ១៩៥៣, ប្រទេសទាំងពីរ ក៏បានប្រាស្រ័យគ្នាទាក់ទង ដោយមេត្រី, ហើយប្រទេសបារាំងបានជួយប្រទេសកម្ពុជា ឲ្យកំពង់

នាក់មួយ ដែលទីឯបង្ហើយក្នុងឆ្នាំមុខ" ។ ទ្រង់បានពោលតទៅទៀតថា:

"សហរដ្ឋអាមេរិក បានជួយខាងគ្រឿងសស្ត្រាវុធ, ប្រទេសចិនប្រជាមានិត, ខាងពេទ្យសហ្គហកម្ម, សហភាពសូវៀតខាងការស្ថាបនានូវមន្ទីរពេទ្យបាលពេត នៅរាជធានីភ្នំពេញ ។

ក្នុងពេលនោះ, ពិតមែនតែមានភ្លៀងបង្អុរមកខ្លាំង, ក៏ប្រជា-រាស្ត្រនៅទីក្រុង ទាំងបុរសទាំងស្ត្រី ស៊ូទ្រាំឈរស្តាប់ព្រះសង្កថាសម្តេចតាល់តែចប់សព្វគ្រប់ ។

## ថ្ងៃសៅរ៍ ទី ១៦ កុម្ភៈ

ម៉ោង ៧ និង ៣០ នាទី, សម្តេចទ្រង់យាងចេញពីទីក្រុងកុលម្បូទៅកាន់ទីក្រុងកន្ឌី ។ នៅតាមរយៈផ្លូវនៃព្រះរាជដំណើរ, ទ្រង់បានស្តេចយាងទៅធ្វើព្រះរាជទស្សនាការ នៅមហាវិទ្យាល័យកុលម្បូ ព្រមទាំងព្រះរាជបរិពារ ។

លុះសម្តេចយាងទៅដល់ទីក្រុងកន្ឌី, ទ្រង់បានសោយព្រះស្ងោយនៅមហាសណ្ឋាគារ "គីងប៉ាវីយ៉ុង" ។ គេបានរៀបចំទទួលសម្តេចជាឱឡារិក ដោយមានក្បួនដង្ហែដ៏វែងពួករបាំ, ព្រះសង្ឃជាច្រើនមកហែទ្រង់ទៅកាន់មហាវិហារចង្កូមកែវ ។ ព្រះចង្កូមកែវនេះ បានដំកល់នៅក្នុងព្រះកោដ្ឋ ដែលរចនាដោយសុវណ្ណដ៏វិចិត្រ លោកចៅអធិការក៏បានថ្វាយនូវចង្កូមកែវព្រះសម្មាសម្ពុទ្ធមកសម្តេច ដោយព្រះទ័យសោមនស្ស ជាយ៉ាងក្រៃលែង ។ សម្តេចទ្រង់បានធ្វើព្រះអំណោយនូវព្រះពុទ្ធរូបធ្វើពី

មាស ២ អង្គ, ពោធិព្រឹក្សមាស ១ ដើម, ប្រាក់ ១ ដើម, ចិញ្ចៀនមួយវង់ និងប្រាក់ ១០០០ រូបិយ ។

លុះដល់ម៉ោង ១៥ និង ៣០ នាទី, មានពិធីទទួលសម្ដេច ឯសាលាក្រុងកន្ទី ជាយ៉ាងឧឡារិក ។ ក្នុងពេលនោះ, សម្ដេចទ្រង់បានថ្វាយនូវព្រះសង្ខ័ជាមួយ ជាកាសាអង់គ្លេសព្រះទានពរស័ក្ដិសាធុការទៅលោកចៅហ្វាយក្រុង ហើយទ្រង់បានបញ្ជាក់អំពីព្រះរាជតំណើរព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ មកកាន់ទីក្រុងនេះ ពីអតីតកាល ព្រមទាំងសរសើរថា ទីក្រុងនេះបិតនៅជាមជ្ឈដ្ឋានដ៏គ្រប់គ្រង សម្រាប់ផ្សាយនូវពន្លឺប្រាជ្ញា ទៅគ្រប់ទិសានុទិស ឲ្យបានក្សេមក្សាន្តរុងរឿង ។

លំដាប់តមក, សម្ដេចទ្រង់យាងទៅធ្វើព្រះរាជទស្សនាការនៅតំបន់ប៉ោលមហាវិហារ និងប៊ុសិល្ហវមហាវិហារ ដែលមានពិធីរៀបចំទទួលព្រះអង្គជាយ៉ាងសំប៊ើមអស្ចារ្យ តាមរបៀបពិធីសាបុកណ នៃប្រទេសស៊ីលង្កា ។ លុះដល់ប៊ុសិល្ហវៈមហាវិហារ ពួកមហាជនទាំងប្រុសទាំងស្រីកំនាំគ្នាសុះទាំងអស់គ្នា រាប់ម៉ឺននាក់ ដើម្បីចង់ឃើញសម្ដេច ។ តែដោយក្រុមនគរបាលឃាំងរារាំង មិនឲ្យចូលមកបាន, ក៏អាក់ខានលែងបានចូលទៅជិតព្រះអង្គ ។

## ថ្ងៃអាទិត្យទី ១ ពិកុម្ភៈ

ពេលព្រឹក, សម្ដេចព្រះឧបយុវរាជ ទ្រង់ស្ដេចយាងទៅដាំព្រឹក្សជាតិមួយដើម នៅសណ្ឋាគារ "គីងប៉ារីយ៉ុន" រួចទ្រង់បានធ្វើព្រះរាជ.

ទស្សនាការ ចំពោះមហាវិហារប៊ីកខ្ទីន មានអស៊ុវិហារជាដើម ដែលពីអតីតកាលមានព្រះត្រៃបិដក, ធ្លាប់តែផ្សាយមាត់ទទេ, ឥឡូវនេះ ទើបនឹងមានគម្ពីរសរសេរជាលាយលក្ខណ៍អក្សរជាដម្បូង ។ ក្នុងពេលនោះ, សម្តេចទ្រង់ស្តេចយាងទតពិព័រណ៍សមាគមសិល្បៈ និងពិពិធភណ្ឌស្ថានទីក្រុងកន្ឌី ។

ពេលរសៀល ដល់ទ្រង់ស្តេចយាងវិលត្រឡប់ មកកាន់ទីក្រុងកុលម្បូវិញ, ទ្រង់បានដាំព្រឹក្សជាតិមួយដើមទៀត នៅឧទ្យានបេរ៉ាទេនិយ: ។

ម៉ោង ១៩ លោករដ្ឋមន្ត្រីទី១ ប្រទេសសិរីលង្កា បានរៀបចំទទួលជាឧឡារិក ចំពោះសម្តេច និងព្រះរាជបរិពារ ។

## ថ្ងៃចន្ទ ១៨ កុម្ភៈ

សម្តេចទ្រង់ស្តេចសម្រាកព្រះកាយពល ព្រមទាំងព្រះរាជបរិពារទ្រង់ស្តេចយាងចេញពីទីក្រុងកុលម្បូ ដោយព្រះទីនាំងអាកាសយានពិសេស នៅថ្ងៃអង្គារទី ១៩ កុម្ភៈ ឆ្ពោះមកកាន់រាជធានីភ្នំពេញ ។

សម្តេចទ្រង់យាងមកដល់ស្ថានីយ៍អាកាសយាន ពោធិចិនតុង នៅថ្ងៃពុធទី២០ កុម្ភៈ ១៩៥៧ ម៉ោង ១៨ និង១៥ នាទី ។

សន្និសីទនៃបណ្ឌិតវិស្សាទអេក្លាត

ធ្វើនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ

លោក ង៉យ-ប៊ុក រៀបរៀង

(តចប់)

---

## ៥. ការទាក់ទងគ្នាទៅវិញទៅមកនៃការសិក្សាខាងព្រះពុទ្ធ-សាសនានិងការសិក្សាឯទៀត ៗ ក្នុងការអប់រំ ខាងព្រះពុទ្ធ-សាសនា ។

<u>ការទាក់ទងគ្នាទៅវិញទៅមក</u> ខាងការសិក្សាព្រះពុទ្ធសាសនា និងការសិក្សាឯទៀត ដែលមិនមែនជាព្រះពុទ្ធសាសនា គឺវិជ្ជារៀន ជាវិធីសំខាន់នៃការរៀន និងការបង្រៀន ខាងការសិក្សាអំពីព្រះពុទ្ធសាសនា សមគួរយកមកពិចារណា ជាពិសេសនៅទីនេះផង ។ ដូចបានថ្លែងពីមុនមកហើយ មុខវិជ្ជាទាំងអស់ ឬផ្នែកនៃការចេះដឹង ដែលចាត់ទុកជាមានប្រយោជន៍ ដើម្បីសិក្សាធម៌ និងសង្គមមនុស្សជាតិនិងគេ ដែលមាននៅជុំវិញ បង្កើតឲ្យមានសម្មតិដ្ឋានដ៏ត្រឹមត្រូវ សម្រាប់ការសង្កេតពិនិត្យខាងព្រះពុទ្ធ-សាសនា ។ ទោះបីយ៉ាងណាក៏ដោយ បញ្ហានេះកើតឡើងជាញឹកញយថា វិធីសិក្សាមិនមែនជាព្រះពុទ្ធសាសនា អាចទាក់ទងជាមួយនឹងការសិក្សា ខាងព្រះពុទ្ធសាសនាយ៉ាងណាទៅ គឺថារបៀបនៃការសិក្សា មិនមែនជាព្រះពុទ្ធសាសនានោះ អាចបំពេញសេចក្តីត្រូវការដល់

ការសិក្សាខាងផ្លូវសាសនាយ៉ាងណា នឹងរឿងពីរនៃការសិក្សាមិនមែនជា ព្រះពុទ្ធសាសនានោះ អាចជួយបន្ថែមចំណេះវិជ្ជា ឲ្យបានយល់ខាងផ្លូវព្រះពុទ្ធសាសនាយ៉ាងណា ក្នុងអតីតកាល គោលបំណងជាមូលដ្ឋាននឹងគំនិតរួមនៃការសិក្សា ខាងផ្លូវសាសនាបានបង្កការប្រើការសិក្សាផ្សេងៗ នឹងការប៉ុនប្រសប់ ឬវិជ្ជាបច្ចេកទេស សម្រាប់បណ្តុះបណ្តាលការសិក្សាខាងផ្លូវព្រះពុទ្ធសាសនា ដែលមាននៅក្នុងប្រភេទនៃវិជ្ជាសមោធាន របស់ធម៌នឹងការសំដែងសូត្រ នៃធម៌ ៗ ទោះបីយ៉ាងណាក៏ដោយ ក្នុងសម័យបច្ចុ-ប្បន្ននេះ ភាពសាំញ៉ាំ ការដាក់ឲ្យមានភាពជាទីក្រុង នឹងការឲ្យកាន់តែជាគ្រហស្ថ ដែលមានចំនួនកាន់តែច្រើនឡើង ក្នុងជីវភាពទំនើបនៅលើផែនដីទូទៅនោះ ត្រូវការចំណេះវិជ្ជាពិតប្រាកដជាមូលដ្ឋាន សម្រាប់អំពីជីឈ្មាសវៃ ហើយព្រមទាំងមុខវិជ្ជា មិនមែនជាព្រះពុទ្ធសាសនា ក៏ត្រូវដាក់បញ្ចូលទៅក្នុងវិជ្ជាបង្រៀន ខាងផ្លូវព្រះពុទ្ធសាសនាផង ៗ មុខវិជ្ជាបែបនេះ កើតមានឡើងដោយអនុវត្តទៅ លើជីវភាពទំនើបច្រើនជាងការសិក្សាធម៌ ហើយរឿងវែងតែមានការទាក់ទង ដោយត្រឹមត្រូវជាមួយនឹងគោលបំណង ជាមូលដ្ឋានខាងការសិក្សាព្រះពុទ្ធសាសនា មុខវិជ្ជាទាំងនេះអាចសន្មតបានថាជា ស្ថានភាព មិនសមគួរយកមកបង្រៀន ខាងការសិក្សាព្រះពុទ្ធសាសនា ៗ ដូច្នេះ អ្នកដឹកនាំព្រះសង្ឃខ្លះនៅទ្វីបអាស៊ី ភាគអគ្នេយ៍បានបញ្ចេញសំឡេងរិះទៀន ដល់ការសិក្សាខាងផ្លូវព្រះពុទ្ធសាសនាបែបទំនើប ហើយបានដាស់តឿនថា មិនគួរសិក្សាទេ គ្រាន់តែគួរពិនិត្យសង្កេតមើលប៉ុណ្ណោះ ពួកនេះមានសេចក្តីបារម្ភ ខ្លាចក្រែងការសិក្សាខាងផ្លូវព្រះ

ពុទ្ធសាសនា ទប់ការសិក្សាពុំមែនជាព្រះពុទ្ធសាសនាមិនឈ្នះ ហើយធម៌ត្រូវបដិសេធចោលឬត្រូវរំលំបាត់បង់ទៅ ដោយហេតុដូច្នេះ ព្រះសង្ឃក៏អាចទៅជាកាន់គេចគ្រហស្ថវិញ ហើយនាំឲ្យមានការសាបសូន្យទៅបន្តិចម្តង ៗ ការយល់ឃើញបែបនេះហៅថា "ប្រពៃណីនិយមលើសលុបហួសប្រមាណ" គួរឲ្យប្រុងប្រយ័ត្នយ៉ាងខ្លាំង ជាពិសេសដោយការរកហេតុផល ឲ្យបានឃើញជាក់ច្បាស់ ។ ការយល់ឃើញខុសពីបែបនេះ ដែលហៅថា "និយមសម័យថ្មីហួសពេក" នោះពុំបានពិនិត្យឲ្យច្បាស់លាស់ ដោយគ្រាន់តែទទួលថា ការអប់រំខាងផ្លូវព្រះពុទ្ធសាសនាត្រូវតែធ្វើ ឲ្យទំនើបឲ្យខាងតែបានដើម្បីឲ្យនៅមានជីវិតបិតនៅ ក្នុងពិភពលោកក្នុងសម័យបច្ចុប្បន្ននេះបាន ។ ដូច្នេះ ករណីនេះអាចបណ្តុះបណ្តាលការខ្វែងយោបល់ នៃពួកអ្នកនិយមការអប់រំ ដែលគិតថា ពុំមែនជាក្បួនចាំបាច់នៃទស្សនវិជ្ជា ខាងការអប់រំដ៏សមគួរ សម្រាប់វិជ្ជាស្ថាននៃព្រះពុទ្ធសាសនាឡើយ ។

ប្រសិនបើសព្វថ្ងៃនេះ បានពិនិត្យពិចារណា ឲ្យត្រឹមត្រូវនូវស្ថាន-ការណ៍ នៃពុទ្ធិកសិក្សាគង់នឹងបានឃើញថា ការដោះស្រាយនៃស្ថានការណ៍នោះ មិនមែនពឹងផ្អែកទៅលើក្រុម "អ្នកប្រកាន់ប្រពៃណី ហួសប្រ-មាណ" ឬទៅលើក្រុម "អ្នកប្រកាន់តាមសម័យថ្មី ហួសប្រមាណ" ទេ ប៉ុន្តែ ត្រូវស្វែងរកការចេះដឹងដ៏ជ្រៅជ្រះ នូវគោលបំណងដើម មុខវិជ្ជា ហើយនឹងនូវវិធីនៃពុទ្ធិកសិក្សា ។

បើគាត់ទាំងអស់ ដែលជាប់ទាក់ទងយល់ថា គោលបំណងដើមនៃ

ការសិក្សាព្រះពុទ្ធសាសនា ការសិក្សាធម៌របស់ព្រះសង្ឃ និងរបស់សង្គម ត្រូវការសេចក្តីពេញចិត្ត ក្នុងការសិក្សាព្រះពុទ្ធសាសនាផ្សេង ៗ គ្នា ដើម្បីបំពេញការកិច្ចរបស់ខ្លួន គប្បីចូលចិត្តថា ការសិក្សាឲ្យបានយល់នូវមុខវិជ្ជាផ្សេងៗនោះ ត្រូវអាស្រ័យលើវិធីសិក្សា ដែលបានលទ្ធផលល្អនិងសេចក្តីស្រួលក្នុងការសិក្សា ហើយត្រូវយល់ថា របៀបសិក្សាតាមប្រពៃណីនិយម និងការនិយមបែបសិក្សាតាមសម័យថ្មី គ្រាន់តែជាសម័យទាក់ទងគ្នា ក្នុងសេចក្តីចំរើននៃការសិក្សា ខាងផ្លូវព្រះពុទ្ធសាសនាប៉ុណ្ណោះ បើដូច្នោះរឿងទាំងអស់នេះ ត្រូវតែដោះស្រាយឲ្យស្រួលបួល ដោយការបញ្ចូលវិជ្ជាសិក្សាមិនមែនជាព្រះពុទ្ធសាសនា ចូលក្នុងវិជ្ជាសិក្សា ខាងផ្លូវព្រះពុទ្ធ-សាសនា ក្នុងបទរៀនសម្រាប់ពុទ្ធិកវិទ្យាល័យ ឬដាក់វិជ្ជាខាងព្រះពុទ្ធ-សាសនាដែលជ្រើសរើសត្រឹមត្រូវ ហើយឲ្យជាបទរៀនក្នុងវិទ្យាល័យដែលមិនមែនជាពុទ្ធិកៈ ។

វិជ្ជាខាងផ្លូវលោកនិងខាងផ្លូវសាសនា ដែលគេទទួលស្គាល់ថាជាប់ទាក់ទងគ្នាទៅវិញទៅមកនោះគឺ វិជ្ជាខាងភាសា ខាងប្រវត្តិសាស្ត្រ ខាងសង្គមសាស្ត្រ អាទិទេពសាស្ត្រ ខាងសាសនា ខាងទស្សនវិជ្ជា ខាងសិល្បសាស្ត្រ វិទ្យាសាស្ត្រ ខាងរូបនិយម វិជ្ជាខាងសារមន្ទីរនិងខាងបណ្ណាល័យ ។ ការបញ្ចូលមុខវិជ្ជាទាំងអស់នេះ ទៅក្នុងពុទ្ធិកសិក្សាក្នុងពុទ្ធិកវិទ្យាល័យ អាចនឹងជ្រើសរើសតាមផ្នែកវិជ្ជាភាសាសាស្ត្រ ដូចតទៅនេះ ទី ១ ការពិចារណាពីបញ្ហាភាសានៃពុទ្ធិកសិក្សា ។ ទី ២ ការចេះដឹង ខាងបណ្ណាល័យ ស្ដីពីវិជ្ជាភាសា ។ ទី ៣ ការយល់ន័យនិងទំហំ

របស់វិជ្ជាភាសា ។ ទី ៤ ការចេះដឹង ខាងវិធីនៃវិជ្ជាភាសា ។ ទី ៥ ការប្រើប្រាស់វិជ្ជាភាសា ដើម្បីរៀនបំណេះវិជ្ជា ខាងផ្លូវសាសនា ដូចជាប្រើវិជ្ជាភាសា ដើម្បីពន្យល់និងបកប្រែគម្ពីរសាស្ត្រ ខាងពុទ្ធសាសនា ដូចជាប្រើវិជ្ជា ខាងបាលីភាសា ដើម្បីជំនួយការតាក់តែង រវាងពុទ្ធិកវិជ្ជា និងអពុទ្ធិកវិជ្ជា ។ ប្រសិនបើ ការតាក់តែងនៃពុទ្ធិកសិក្សា និងអពុទ្ធិកសិក្សា ធ្វើឡើងបាន កម្មវិធីនៃការសិក្សានៅពុទ្ធិកវិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យនឹងអាចត្រឡប់ទៅ ជាចង្កោមវិជ្ជាមួយ ដែលមានទស្សនវិជ្ជាជាត្រីមុខ ហើយបញ្ញាប្រពៃណីនិយម ប្រឆាំងនឹងសម័យនិយម មិនអាចនឹងរាំងរាការចំរើន នៃពុទ្ធិកសិក្សាក្នុងលោកបានឡើយ ។

## ៦_ សេចក្តីសន្និដ្ឋាន

ការពិចារណាចំពោះពុទ្ធិកសិក្សា អាចសន្និដ្ឋានយ៉ាងខ្លីដូចតទៅនេះ: គោលបំណងធំគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសង្គមមនុស្ស អាចឃើញ អាចថ្លែងបាន អាចយល់ និងអាចសម្រេចបាន សម្រាប់មនុស្សគ្រប់រូប មុខវិជ្ជាដ៏សំខាន់គឺធម៌និងការស្គាល់ នូវសង្គមមនុស្ស និងមជ្ឈដ្ឋានជុំវិញសង្គមមនុស្សនោះ ត្រូវតែឲ្យមានការតាក់តែង និងគោលបំណងខាងលើនោះ ។ របៀបសិក្សានិងរបៀបបង្រៀន ទោះបីតាមប្រពៃណីក៏ដោយ តាមសម័យក៏ដោយ ត្រូវតែតម្រូវតាមមុខវិជ្ជា ហើយនិងត្រូវតែបំពេញ តាមគោលបំណងឲ្យបានសម្រេច ។ ការតាក់តែងនៃវិជ្ជាទាំងអស់ នៅក្នុងបទរៀនខាងផ្លូវព្រះពុទ្ធសាសនា អាចធ្វើឲ្យចំរើនឡើង

បាន អាចធ្វើឲ្យយល់ ដោយជាក់ច្បាស់នូវវិជ្ជានោះ ទើងអាចនាំឲ្យសម្រេច

គោលបំណងទាំងអស់ បានដោយឆាប់ ។

ដូច្នេះ ពុទ្ធិកសិក្សាក្នុងសម័យបច្ចុប្បន្ននេះ អាចនឹងជួយរៀបចំបុគ្គល

គ្រប់រូប ព្រះសង្ឃនឹងសង្គមមនុស្ស ឲ្យបានប្រកបដោយជីវភាពល្អរស់

ទៅអនាគតកាល ។

សន្និសីទនេះ បានបញ្ចប់ទៅពេលម៉ោង ១៦,៤០ នាទី ។

លំដាប់តមក, សម្តេចសង្ឃនាយកគណៈមហានិកាយ បានថ្លែង

នូវសន្ថរជាមួយ ពណ៌នាថា:

"ការសិក្សាក្នុងព្រះពុទ្ធសាសនានេះ, ភិក្ខុសង្ឃ បានទទួលនូវទៅ

ទេសនាគ្រប់ផ្នែកអាកម នៃព្រះរាជអាណាចក្រទាំងមូល, តែដែលគួរឲ្យ

សរសើរលោកវិស្សាទនេះ ព្រោះលោកពិតជាអ្នកពហុគុណ ដែលមានកិត្តិ-

នាមល្បីល្បាញ ក្នុងសកលលោក ហើយជាអ្នកប៉ិនប្រសប់ ខាងពន្យល់

បំភ្លឺការសិក្សា ក្នុងព្រះពុទ្ធសាសនា ដោយបញ្ជាក់គ្រឿងប្រយោជន៍ នៃការ

សិក្សានេះ ទៅអនាគតនឹងមធ្យោបាយផ្សេង ។ ដែលធ្វើឲ្យការសិក្សា

ចម្រើនតាមលំដាប់ ព្រមទាំងការសិក្សាព្រះពុទ្ធសាសនា នៅនានាប្រទេស

ផ្សេងទៀត ដោយសេចក្តីពិស្តារ ។

ជីវប្រវត្តិ

បណ្ឌិត វិស្សាទ អេ.ក្ឆាត ១០០៦ ២-ធ្នូមេ

ស្ទូឈិក្លាយ៉ា.ម៉ាជិ

# សេតាក្ប៉ា.គុ

## ឆ្ក្យប៉ុន

លោកកើតនៅ ភីនតូវ៉ៃ ប្រទេសកាណាដា បេ.សេ.នៅថ្ងៃទី ២៩ ខែឧសភាឆ្នាំ ១៩១៤ ជាតិអាមេរិកាំង ធ្វើអាពាហ៍ពិពាហ៍មង្គល ក្នុងឆ្នាំ-១៩៥២ មានបុត្រ ២ បានបរិញ្ញាបត្រខាងអក្សរសាស្ត្រ B.A. អំពីមហា-វិទ្យាល័យ ពីស៊ីទីគូខ [illegible] វិទ្យាស្ថានម៉ៀនតេល នៃមហាវិទ្យា-ល័យហាវ៉ៃក្នុងឆ្នាំ ១៩៣៧-១៩៣៩ បានបរិញ្ញាបត្រមហាបណ្ឌិតM.A. ក្នុងឆ្នាំ ១៩៤០ ជាបុគ្គលិកនៃមូលនិធិ រ៉ុកហ្វេល្លើរ មហាវិទ្យាល័យ ពេនស៊ីលវ៉ានៀ ក្នុងឆ្នាំ ១៩៤៦-១៩៤៧ បានទទួលបរិញ្ញាបត្រមហា-បណ្ឌិតខាងទស្សនវិជ្ជា Ph.d. ពីវិទ្យាល័យ ថៃរ៉ែន ក្នុងឆ្នាំ ១៩៥១ ជាសាស្ត្រាចារ្យ បង្រៀនខាងវិទ្យាសាស្ត្រនយោបាយ នៅមហាវិទ្យាល័យហាវ៉ៃ ឆ្នាំ ១៩៣៦-១៩៣៧ ជាអ្នកសំដែងអំពីការសិក្សាភាសាជប៉ុន A.S.T.P. នៅមហាវិទ្យាល័យ ពេនស៊ីលវ៉ានៀ ឆ្នាំ១៩៤៤-១៩៤៦ ជាអ្នកសំដែងកិច្ចការ នៅក្នុងបូព៌ាប្រទេស នៅមហាវិទ្យាល័យ ហាវ្រនហាប-គិន ជាគ្រូបង្រៀនការសាកន្ទរជាតិជាន់ខ្ពស់ "ក្រុងវ៉ាស៊ីង.តុនដេ.សេ-" ក្រោយឆ្នាំ១៩៥២ ជាបាន់ហ្វានក្រុមផែនការណ៍មូលនិធិអាស៊ីសាន់ហ្វ្រាន់ស៊ីស្កូ ក្នុងឆ្នាំ១៩៥៤-១៩៥៦ ជាទីប្រឹក្សាពិសេស ក្នុងឆ្នាំ-១៩៥៦ ។ ជាសាស្ត្រាចារ្យបង្រៀនផ្នែកការបរិយាយសេចក្ដី នៅមហា-វិទ្យាល័យឝូតានី មហាវិទ្យាល័យ រ៉ៃរ៉ុក និងមហាវិទ្យាល័យខាងស្ត្រី

ក្សត្ត ក្នុងឆ្នាំ១៩៥៣-១៩៥៤ ជាអ្នកធ្វើដំណើរទៅសំដែងសុន្ទរកថានៅគ្រប់ប្រទេស ដែលខ្លួនទៅទស្សនា ក្នុងឆ្នាំ១៩៥៧ បានទទួលគ្រឿងឥស្សរិយយស ច្បូឈុ ពីពុទ្ធសាសនិក ជប៉ុន នៅហ្វីឡាដេលហ្វៀ. ឆ្នាំ១៩៤៦ គ្រឿងឥស្សរិយយសឈើឆកន.ឈុ នៅឡូសអែនជែលេស ឆ្នាំ១៩៥០ គ្រឿងឥស្សរិយយស ថេរវាទ ពីពុទ្ធសាសនិកថៃ នៅក្រុងបាងកកឆ្នាំ១៩៥៦ ។ គ្រឿងឥស្សរិយយស ថេរវាទ ពុទ្ធសាសនិកភូមា នៅក្រុង រង្គូនឆ្នាំ១៩៥៦ USMC ឆ្នាំ១៩៤១-១៩៤៥ ជាវរសេនីយទោ “សមាជិក”ជាសមាជិកសមាគតអាមេរិកាំងខាងបូព៌ាជាសមាជិកការសិក្សាទ្វីបអាស៊ី ជាសមាជិកសមាគម· សៀម ជាសមាជិកសមាគម ជប៉ុន សម្រាប់ការសិក្សា ឥណ្ឌៀ និងព្រះពុទ្ធសាសនា “វិជ្ជាដែលបានសិក្សា” ប្រវត្តិសាស្ត្រនៃបរមត្ថ វិជ្ជាខាងព្រះពុទ្ធសាសនា ប្រវត្តិសាស្ត្រនៃគំនិតខាងនយោបាយអាស៊ី ប្រវត្តិសាស្ត្រពុទ្ធសាសនាមជ្ឈិមកៈ “រឿងដែលបានសរសេរ” ឥទ្ធិពលព្រះពុទ្ធសាសនា លើគំនិតខាងនយោបាយនិងស្ថាប័ន ឥណ្ឌៀ និង ជប៉ុន ឧត្តមគតិ ខាងផ្លូវនយោបាយនៃព្រះពុទ្ធ·សាសនា:ជីវប្រវត្តិនិងសេចក្តីសង្ខេប ឧត្តមគតិ ខាងផ្លូវនយោបាយនៃព្រះពុទ្ធសាសនាការសិក្សា អំពីព្រះពុទ្ធសាសនាក្នុងសង្គម ។

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

*អគ្រាណីក* (អគ្រ + អណីក) នបុំ. រណសីរ, សមរភូមិ ។ *អគ្រាណិក្យ* នបុំ. ទ័ពស្រួច ។ *អគ្រេទិធិឞូ* ស្ត្រី. ប្អូនស្រីដែលការមុនបងស្រី ។ *អគ្រេទិធិឞុ* បុំ. ឪពុកដែលរៀបចំការកូនស្រីប្អូនមុនកូនស្រីបង ។

*អគ្រេ-ភូ* គុ. ដែលកើតមុន, ដែលមានមុនគេ ។

អគ្រស្ត (អ + គ្រស្ត) គុ. ដែលមិនទាន់លេប ។

អគ្រាមីណ គុ. ដែលមិនមែនជាក្រាមជន ដែលមានថោរីភាព, ដែលភក់ទាក់ ។

អគ្រាម្យត្វ នបុំ. ភាពមិនមែនជាក្រាមជន, ថោរីភាព ។

អគ្រាហ្យ គុ. ដែលបុគ្គលកាន់យកមិនបាន, ដែលបុគ្គលមិនគប្បីស្គាល់ ។

អគ្រិម គុ. ជាឯក, ដែលនៅមុនគេ ។

អគ្រ្យ គុ. ជាមេ, ប្រសើរ, ចាស់; ពិសេស ។ *—តបស* បុំ. នាមតាបស ។

អឃ៍ ក្រិ. ប្រព្រឹត្តទៅខាងខុស ។

អឃ គុ. លាមក, ដែលមិនបរិសុទ្ធ, ថោកទាបជាងវណ្ណៈខ្លួន; ។នបុំ. សេចក្តីមិនបរិសុទ្ធ, សភាពមិនបរិសុទ្ធ, ទោស, ទុក្ខ ។ *—ក្ឫត* គុ. ដែលធ្វើឲ្យលាមក, អ្នកធ្វើឲ្យលាមក ។ *—ឃ្ន ឬ - នាគក* គុ. អ្នកបំបាត់នូវទោសឬសេចក្តីទុក្ខ ។ *—ឃ្នស ឬ នាគស* បុំ. នាមព្រះវិស្ណុ ។ *—មឝណ* គុ. "លាងបាប" ឈ្មោះបទសូត្រក្នុងគម្ពីរវេទ (ពួកព្រាហ្មណ៍ប្រើសូត្ររាល់ថ្ងៃ) ។ *—វិឃាតកត្ឫ* ក.ន. អ្នកធ្វើនូវកិរិយាកំចាត់បង់នូវបាប ។ *—វិនាឝិន*

## សេចក្ដីជូនដំណឹង

## អំពីទស្សនាវដ្ដី កម្ពុជសុរិយា ផ្សាយចេញអំពីពុទ្ធសាសនបណ្ឌិត្យ

ទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ ១៩៥៧ ដែលអស់លោក-អ្នក បានចុះឈ្មោះជាវមកនោះនឹងចប់ត្រឹមខ្សែលេខ ១២ ខាងមុខនេះហើយ ។ យើងសូមថ្លែងអំណរគុណយ៉ាងក្រៃលែង ចំពោះអស់លោក អ្នកដែលបានចុះឈ្មោះជាវទាំងនោះ ហើយយើងសង្ឃឹមថា អស់លោក-អ្នកនឹងចុះឈ្មោះជាវទស្សនាវដ្ដី ដែលយើងកំពុងរៀបរៀង នឹងប្រមូលផ្សំរឿងរ៉ាវនឹងបោះពុម្ព ក្នុងឆ្នាំ ១៩៥៨ តទៅទៀត ។ កិច្ចដែលអស់លោក-អ្នកបានចុះឈ្មោះជាវច្រើនឡើង ៗ នេះ ឈ្មោះថា បានជួយបំពេញករណីយកិច្ចចំពោះប្រទេសជាតិ ផ្នែកខាងសាសនានឹងអក្សរសាស្ត្រ ។

តាមការណ៍ពិត ទស្សនាវដ្ដី កម្ពុជសុរិយានេះ ជាទស្សនាវដ្ដីផ្លូវការ ផ្សាយចេញនូវរឿងរ៉ាវផ្នែកសាសនា នឹងអក្សរសាស្ត្រ ទុកដូចជាប្រទីបសម្រាប់បំភ្លឺប្រជាជនរួមជាតិ ឲ្យមានបញ្ញាចក្ខុ មើលឃើញច្បាស់នូវសេចក្ដីវិនាស នឹងសេចក្ដីចំរើន ក្នុងផ្លូវលោក នឹងផ្លូវធម៌ ព្រមទាំងពង្រីកអក្សរសាស្ត្រជាតិ ឲ្យរីកធំទូលាយតាមសម័យ ជាកុិយេ្យាកាព ។

រឿងរ៉ាវសម្រាប់ចុះ ក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ ១៩៥៨ ដូចមានរាយមាតិកា តទៅនេះ ៖

## ផ្នែកសាសនា

១. ជំណឿផ្សេង ៗ ខាងព្រះពុទ្ធសាសនា;

២. ធម្មទេសនា ដែលមានអត្ថសេចក្តី ៗ;

៣. សីលធម៌របស់ព្រះពុទ្ធសាសនា;

៤. ការជ្រើសរើសប្រែព្រះសូត្រ ដែលមានសេចក្តីគួរជឿ និងជាផ្លូវប្រតិបត្តិ ។

## ផ្នែកអក្សរសាស្ត្រ

១. គោលចារឹកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងកាព្យឃ្លោងចាស់ ៗ ឬថ្មីៗ;

២. ឯកសារ (រឿងរ៉ាវសំខាន់ ៗ ដូចសិលាចារឹកជាដើម);

៣. រឿងសាមកុក នៅតែបោះពុម្ពតទៅទៀត គ្រាតែចប់;

៤. សុភាសិតផ្សេង ៗ របស់ជាតិយើង និងនានាជាតិ;

៥. រឿងព្រេងខ្មែរ ឬ រឿងព្រេងរបស់នានាជាតិ,

៦. រឿងទំនៀមទម្លាប់ខ្មែររបស់គណៈកម្មការទំនៀមទម្លាប់ខ្មែរ។ល។

ហេតុនេះ អស់លោក-អ្នកដែលមានបំណងនឹងជាវ ទស្សនាវដ្ដី កម្ពុជសុរិយា ប្រចាំឆ្នាំ១៩៥៨ សូមប្រញាប់ផ្ញើនាមនិងទីលំនៅ ឲ្យទាន់កុងខែធ្នូ ឆ្នាំ ១៩៥៧ ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យភ្នំពេញ (Monsieur le Secrétaire Général de l'Institut-Bouddhique Phnôm-Penh ព្រមទាំងដំឡៃជាវប្រចាំឆ្នាំចំនួន ២៣០រៀលផង ។

ពុទ្ធសាសនបណ្ឌិត្យ